ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

កូវ ប៊ុន្ថា
KOV BUNTHA

# ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ
# ករណីសិក្សា៖ ខេត្តតាកែវ

The Implementation of Curriculum in High Schools, Takeo Province
Case Study:  Takeo Province

## និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ
## ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ភ្នំពេញ ២០២០

# ក្រសួងអប់រំ យុវជន និងកីឡា
**Ministry of Education Youth and Sport**

## វិទ្យាស្ថានជាតិអប់រំ
**National Institute of Education**

## កូវ ប៊ុន្ថា
**KOV BUNTHA**


# ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ
# ករណីសិក្សា៖ ខេត្តតាកែវ

The Implementation of Curriculum in High Schools, Takeo Province
Case Study:  Takeo Province

## និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ
## ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

## សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត ឈាង សទ្ធាត

## ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

កូវ ប៊ុន្ថា
KOV BUNTHA

# ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ
# ករណីសិក្សា៖ ខេត្តតាកែវ

The Implementation of Curriculum in High Schools, Takeo Province
Case Study:  Takeo Province

គណៈកម្មការវាយតម្លៃនៃការការពារថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ថ្ងៃទី    ខែ     ឆ្នាំ២០២០

**និក្ខេបបទនេះត្រូវបានវាយតម្លៃដោយ៖**

____________________ ប្រធានគណៈកម្មការ

____________________ គ្រូវាយតម្លៃទី១

____________________ គ្រូវាយតម្លៃទី២

____________________ គ្រូវាយតម្លៃទី៣

____________________ សមាជិក

____________________ សមាជិក

____________________ លេខាកត់ត្រា

**ឯកភាពដោយ៖**

**តំណាងក្រសួងអប់រំ យុវជន និងកីឡា**

**ឯកឧត្តមបណ្ឌិត ជ័យ  សារិន**

**នាយកវិទ្យាស្ថានជាតិអប់រំ**

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ កូវ ប៊ុន្នា សូមបញ្ជាក់ថានិក្ខេបបទដែលមានចំណងជើង **«ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ»** ករណីសិក្សាវិទ្យាល័យចំនួន៣ ក្នុងខេត្តតាកែវ សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។

ស្នាដៃនេះពុំទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាត ឬចុះបញ្ជីឯកសារយោងឡើយ ។ និក្ខេបបទស្រាវជ្រាវ និងចងក្រងខាងលើនេះពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**កូវ ប៊ុន្នា**

# ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យដឹកនាំនៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ សូមបញ្ជាក់ថា បេក្ខជនឈ្មោះ **ភួច ប៊ុន្ធា** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ ក្រោមប្រធានបទ «**ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ**» ប្រាកដមែន។ កន្លងមក ប្រធានបទនៃនិក្ខេបបទនេះ មិនមានប្រើប្រាស់សម្រាប់បញ្ចប់ការសិក្សាដទៃទៀតឡើយ។ ខ្ញុំពិតជាបានចូលរួមដឹកនាំ និងជួយរៀបចំការសេរសេរនិក្ខេបបទនេះឡើងពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

**សាស្ត្រាចារ្យដឹកនាំ**

**បណ្ឌិត ឈាង សទ្ធាត**

# លិខិតបញ្ជាក់

**បណ្ឌិត ឈាង សទ្ធាត** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា៖**

លោក **ភួង ម៉ុន្ណា** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ពិតជាបានចុះធ្វើកម្មសិក្សាប្រតិបត្តិនៅវិទ្យាល័យចំនួន៣ ក្នុងខេត្តតាកែវ ដូចខាងក្រោម៖

| ល.រ | ឈ្មោះសាលារៀន | ភូមិ | ឃុំ | ស្រុក |
|---|---|---|---|---|
| ១ | វិទ្យាល័យ ហេង សំរិន ព្រៃល្វា | ព្រៃល្វាលិច | ព្រៃល្វា | ព្រៃកប្បាស |
| ២ | វិទ្យាល័យ អង្គអណ្ដែត | ព្រៃចំបក់ | តាំងយ៉ាប | ព្រៃកប្បាស |
| ៣ | វិទ្យាល័យ ហ៊ុន សែន ១មិថុនា | ជំរៅ | ពារាម | បាទី |

ការចុះធ្វើកម្មសិក្សាប្រតិបត្តិនេះ គិតចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដើម្បីបំពេញល័ក្ខខ័ណ្ឌកម្មវិធីបណ្ដុះបណ្ដាល វគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

**សាស្ត្រាចារ្យដឹកនាំ**

**បណ្ឌិត ឈាង សទ្ធាត**

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកសាស្ត្រាចារ្យដឹកនាំ **បណ្ឌិត ឈាង សឡាត** ដែលបានត្រួសត្រាយបង្ហាញផ្លូវ បំផុសស្មារតី ផ្តល់ជាគំនិតលើកទឹកចិត្តដល់រូបខ្ញុំបាទជាប្រចាំ និងបានពិនិត្យ ព្រមទាំងកែសម្រួលលើកិច្ចការស្រាវជ្រាវមួយនេះ ប្រកបដោយ ការទទួលខុសត្រូវ និងវិជ្ជាជីវៈខ្ពស់ ទាំងខ្លឹមសារ និងរចនាបថ។

សូមថ្លែងអំណរគុណជាអនេក ចំពោះមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ជាពិសេស **លោក នុត មូរ៉ា** អនុប្រធានការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល ដែលបានជំរុញ និងលើកទឹកចិត្តដល់រូបខ្ញុំបាទរហូតមក ក្នុងការបន្តការសិក្សាលើជំនាញឯកទេសមួយនេះ។

បន្ទាប់មកទៀត ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រុមគ្រួសាររបស់ខ្ញុំបាទ ជាពិសេសភរិយារបស់ខ្ញុំ ដែលបានផ្តល់ឱកាសឱ្យរូបខ្ញុំបានបន្តការសិក្សារហូតចប់សព្វគ្រប់។

ខ្ញុំបាទសូមថ្លែងអំណរគុណផងដែរចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតវគ្គបណ្តុះបណ្តាលនេះឡើង តាមរយៈវិទ្យាស្ថានជាតិអប់រំ ក្នុងការផ្តល់ឱកាសឱ្យរូបខ្ញុំបានបន្តការសិក្សាលើជំនាញដ៏មានសារៈសំខាន់នេះ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរ ចំពោះលោកនាយក នាយករង លោកគ្រូអ្នកគ្រូឧទ្ទេសនៃវិទ្យាស្ថានអប់រំ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមចំណែកឱ្យវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនេះបញ្ចប់ជាស្ថាពរ ដោយភាពជោគជ័យក្រៃលែង។

សូមថ្លែងអំណរគុណផងដែរ ចំពោះមិត្តរួមជំនាន់ទាំងអស់ ដែលបានចូលរួមផ្តល់ជាគំនិត យោបល់ និងឯកសារពាក់ព័ន្ធផ្សេងៗ ទាំងក្នុងការសិក្សា និងការស្រាវជ្រាវរហូតដល់ទីបញ្ចប់។

ជាចុងក្រោយ សូមថ្លែងអំណរគុណចំពោះ លោកនាយក នាយករង និងលោកគ្រូអ្នកគ្រូនៃសាលាគោលដៅទាំងបី ក្នុងខេត្តតាកែវ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់ទិន្នន័យ តាមរយៈការបំពេញកម្រងសំណួរស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទនេះឡើង។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

**បេក្ខជនស្រាវជ្រាវ**

**ភួង ប៊ុន្ណា**

# មូលន័យសង្ខេប

ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់ៗពីរគឺ ទីមួយរកឱ្យឃើញពីប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលានៅកម្រិតវិទ្យាល័យ និងទីពីរចង់ដឹងពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន នៅកម្រិតមធ្យមសិក្សាទុតិយភូមិផងដែរ។ អ្នកស្រាវជ្រាវបានកំណត់យកគណៈគ្រប់គ្រងចំនួន៩នាក់ និងគ្រូបង្រៀនចំនួន៩០នាក់ ដែលកំពុងបង្រៀនពីថ្នាក់ទី១០ ដល់ទី១២ ពីវិទ្យាល័យចំនួន៣ ក្នុងខេត្តតាកែវ។ ឧបករណ៍ស្រាវជ្រាវដែលប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ ជាកម្រងសំណួរដែលត្រូវបានរៀបចំឡើងជាពីរប្រភេទគឺ ប្រភេទទីមួយ ប្រើប្រាស់សម្រាប់នាយក នាយករង និងប្រភេទទីពីរ សម្រាប់គ្រូបង្រៀន ដោយមានទាំងសំណួរបែបទម្រង់បិទ និងសំណួរបែបទម្រង់បើក។ ការវិភាគទិន្នន័យ បង្ហាញជាតម្លៃមធ្យម(M) គម្លាតស្តង់ដារ(SD) និងផ្តោតលើការបកស្រាយលើសំណួរទម្រង់បើក។

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា នាយកវិទ្យាល័យបានយកចិត្តទុកដាក់ខ្ពស់លើការដឹកនាំការអនុវត្តកម្មវិធីសិក្សា ដោយលទ្ធផលបង្ហាញថា នាយកសាលាមានការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ ក្នុងកម្រិតល្អណាស់ ខណៈដែលការគ្រប់គ្រងនិងដឹកនាំការបង្រៀន ការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងការសហការនិង ទំនាក់ទំនងស្ថិតក្នុងកម្រិតល្អអាចទទួលយកបាន។ បើទោះបីជាការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងសាលាទទួលបានលទ្ធផលល្អយ៉ាងណាក៏ដោយ ក៏ការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់ពួកគាត់បានជួបនូវបញ្ហាលំបាកមួយចំនួនដូចជា ការខ្វះគ្រូបង្រៀនតាមឯកទេសមួយចំនួនផ្នែកមធ្យមសិក្សាទុតិយភូមិ ខ្វះបន្ទប់រៀន គ្រូបង្រៀនមួយចំនួនតូចខ្វះមនសិការវិជ្ជាជីវៈដោយមិនសូវយកចិត្តទុកដាក់លើការងារបង្រៀន និងមិនមាន បន្ទប់បំពាក់សម្ភារ បរិក្ខារសម្រាប់ អនុវត្តមុខវិជ្ជាICTជាដើមដែលសុទ្ធសឹងជាបញ្ហាត្រូវដោះស្រាយជាចាំបាច់។ ចំណែកការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀនកម្រិតវិទ្យាល័យផ្នែកមធ្យមសិក្សាទុតិយភូមិវិញ អ្នកស្រាវជ្រាវបានរកឃើញថា គ្រូបង្រៀនបានអនុវត្តបានល្អ ទាំងការអនុវត្តកម្មវិធីសិក្សា ការរៀបចំដំណើរការបង្រៀន ចំណេះដឹងលើជំនាញរបស់ពួកគាត់ក៏សមស្រប វិធីសាស្ត្របង្រៀន និងការពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ទន្ទឹមនឹង ការអនុវត្តបានល្អនេះ គ្រូបង្រៀនក៏បានជួបនូវបញ្ហាប្រឈមមួយចំនួនដែល បានស្នើសុំដំណោះស្រាយផងដែររួមមាន ស្ទើរតែគ្រប់មុខវិជ្ជាមានម៉ោងសិក្សាតិចតែខ្លឹមសារមេរៀនវែង ខ្វះសៀវភៅសិក្សាគោល សិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រនិងអវត្តមានច្រើន គ្រូមិនទទួលបានការបណ្តុះបណ្តាលលើបច្ចេកទេសវិធីសាស្ត្របង្រៀនថ្មីៗ ខ្វះសម្ភារឧបទេស និង ខ្វះសម្ភារនិងបន្ទប់ពិសោធន៍ ជាដើម។

# តារាងមាតិកា

**សេចក្តីប្រកាសរបស់បេក្ខជន** .................... i
**ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ** .................... ii
**លិខិតបញ្ជាក់** .................... iii
**សេចក្តីថ្លែងអំណរគុណ** .................... iv
**មូលន័យសង្ខេប** .................... v
**ជំពូកទី១** .................... ១
**សេចក្តីផ្តើម** .................... ១
១.១.សាវតារ .................... ១
១.២.បញ្ហានៃការស្រាវជ្រាវ .................... ៤
១.៣.គោលបំណងនៃស្រាវជ្រាវ .................... ៧
១.៤.សំណួរស្រាវជ្រាវ .................... ៧
១.៥.សម្មតិកម្ម .................... ៧
១.៦.សារៈសំខាន់នៃការស្រាវជ្រាវ .................... ៨
១.៧.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ .................... ៨
១.៨.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .................... ៨
**ជំពូកទី២** .................... ១០
**រំលឹកទ្រឹស្តី** .................... ១០
២.១.និយមន័យ .................... ១០
២.១.១.ការអនុវត្ត .................... ១០
២.១.២.កម្មវិធីសិក្សា .................... ១០
២.១.៣.ការអនុវត្តកម្មវិធីសិក្សា .................... ១១
២.២.និយមន័យពាក់ព័ន្ធ .................... ១២
២.២.១.ប្រសិទ្ធភាព .................... ១២
២.២.២.ដឹកនាំ .................... ១៣
២.២.៣.រង្វាយតម្លៃ .................... ១៣
២.៣.ឯកសារកម្មវិធីសិក្សា .................... ១៣
២.៣.១.គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា .................... ១៣

២.៣.២.ក្របខណ្ឌកម្មវិធីសិក្សា ....... ២០
២.៤.ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា ....... ២៤
២.៥.ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ....... ២៦
២.៦.បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សាកន្លងមក ....... ៣៣
**ជំពូកទី៣** ....... ៣៦
**វិធីសាស្ត្រស្រាវជ្រាវ** ....... ៣៦
៣.១.ការរៀបចំស្រាវជ្រាវ ....... ៣៦
៣.២.វិធីសាស្ត្រប្រមូលទិន្នន័យ ....... ៣៦
៣.៣.ការជ្រើសរើសសំណាក ....... ៣៧
៣.៤.ឧបករណ៍ស្រាវជ្រាវ ....... ៣៨
៣.៥.កម្រងសំណួរ និងគោលបំណង ....... ៣៨
ក.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ....... ៣៨
ខ.កម្រងសំណួរសម្រាប់គ្រូបង្រៀន ....... ៣៩
៣.៦.ការវិភាគទិន្នន័យ ....... ៣៩
**ជំពូកទី៤** ....... ៤១
**លទ្ធផល និងការពិភាក្សា** ....... ៤១
៤.១.ការវិភាគទិន្នន័យលើកម្រងសំណួរទី១ ....... ៤១
៤.១.១.ព័តមានទូទៅរបស់អ្នកចូលរួម ....... ៤១
៤.១.២.ការដឹកនាំអនុវត្តកម្មវិធីសិក្សា ....... ៤២
៤.២. ការវិភាគទិន្នន័យលើកម្រងសំណួរទី២ ....... ៥១
៤.២.១.ព័តមានទូទៅរបស់អ្នកចូលរួម ....... ៥១
៤.២.២.ការអនុវត្តកម្មវិធីសិក្សា ....... ៥៣
**ជំពូកទី៥** ....... ៦៧
**សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍** ....... ៦៧
៥.១.សេចក្តីសន្និដ្ឋាន ....... ៦៧
៥.២.សំណូមពរ ....... ៦៨
៥.២.១.ក្រសួងអប់រំ យុវជន និងកីឡា ....... ៦៨

៥.២.២.មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ........................................................ ៦៩
៥.២.៣.គណៈគ្រប់គ្រងសាលារៀន ............................................................. ៦៩
៥.២.៤.ប្រធានក្រុមបច្ចេកទេស ................................................................... ៦៩
៥.២.៥.គ្រូបង្រៀន .........................................................................................៧០
៥.២.៦.អាណាព្យាបាលសិស្ស ......................................................................៧០
៥.៣.អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ......................................................៧០
**ឯកសារយោង**.......................................................................................................៧២
**ឧបសម្ព័ន្ធ** .......................................................................................................៧៥

# បញ្ជីតារាង


| ល.រ | តារាង | ទំព័រ |
|---|---|---|
| ២.១ | បំណែងចែកម៉ោងសិក្សា សម្រាប់កម្មវិធីសិក្សាជាតិ (២០០៥-២០០៩) | ១៦ |
| ២.២ | របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១០ | ១៧ |
| ២.៣ | របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១១-១២ | ១៨ |
| ២.៤ | របាយមុខវិជ្ជា និងម៉ោងសិក្សាសម្រាប់ថ្នាក់វិទ្យាសាស្រ្ត និងវិទ្យាសាស្រ្តសង្គម តាមឯកសារណែនាំ | ១៩ |
| ២.៥ | របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្រ្ត | ២២ |
| ២.៦ | របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្រ្តសង្គម | ២៣ |
| ៣.១ | ចំនួនសំណាក | ៣៨ |
| ៤.១ | ចំនួនគណៈគ្រប់គ្រងគិតតាមភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ | ៤១ |
| ៤.២ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត | ៤២ |
| ៤.៣ | កម្រិតនៃការអនុវត្តសកម្មភាពលម្អិតតាមផ្នែកទាំងបួន នៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា របស់នាយកសាលា | ៤៤ |
| ៤.៤ | កម្រិតនៃការអនុវត្តសកម្មភាព លើប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា | ៤៧ |
| ៤.៥ | ចំនួនគ្រូបង្រៀនគិតតាមភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍បង្រៀន និងមុខវិជ្ជាកំពុងបង្រៀន | ៥១ |
| ៤.៦ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត | ៥៣ |
| ៤.៧ | កម្រិតនៃការអនុវត្តសកម្មភាពលម្អិតតាមផ្នែកទាំងប្រាំ នៃកាអនុវត្តកម្មវិធីសិក្សា របស់នាគ្រូបង្រៀន | ៥៥ |
| ៤.៨ | កម្រិតនៃការអនុវត្តសកម្មភាព លើប្រសិទ្ធភាពនៃកាអនុវត្តកម្មវិធីសិក្សា | ៥៩ |

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១.សារៈសំខាន់

ជាទូទៅការអប់រំមានន័យពីរយ៉ាង។ តាមន័យទូលាយ ការអប់រំគឺសំដៅលើការមាន ឥទ្ធិពលទៅលើការកសាងសមត្ថភាពខាងរូបរាងកាយ ខាងអត្តចរិត បញ្ញា ស្មារតី និងសតិបញ្ញា របស់មនុស្ស ។ ក្នុងន័យនេះការអប់រំគឺគ្មានទីបញ្ចប់ឡើយ។ យើងរៀនពីបទពិសោធន៍របស់យើងអស់មួយជីវិត ។ ក្នុងន័យបច្ចេកទេសរបស់វា ការអប់រំគឺជាដំណើរការដែលកើតមាននៅក្នុងសង្គមតាមរយៈ សាលារៀន និងស្ថាប័នផ្សេងៗទៀត ដើម្បីបន្ត និងរចនានូវមរតកវប្បធម៌ ពុទ្ធិ តម្លៃ និងជំនាញពីជំនាន់មួយទៅជំនាន់មួយទៀត (ប៉ាន់ វុត្ថា ២០០៦)។ តាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បោះពុម្ពឆ្នាំ១៩៦៧ បានផ្តល់និយមន័យនៃពាក្យ"អប់រំ" ថា ហាត់ចិត្ត; បង្វឹកចិត្ត; ជួសជុលចំពោះវិជ្ជាឬកិរិយាមារយាទ, ហ្វឹកហាត់ឲ្យស្ទាត់ជំនាញជាងមុន, កែឲ្យបានល្អប្រពៃជាងមុនជាលំដាប់; ខំប្រឹងបំពេញឧបនិស្ស័យឲ្យបរិបូណ៌, ខំកសាងសន្សំបុណ្យកុសលរក្សាទុកពុំឲ្យមានហ្មង, មិនឲ្យមានថ្នាំងថ្នាក់។

តួនាទីនៃការអប់រំគឺរៀបចំឥរិយាបថមនុស្សឱ្យបានល្អ ដើម្បីឱ្យគេគោរពច្បាប់ មានភាពស្មោះត្រង់ ស្រឡាញ់ស្តេច និងប្រទេសរបស់ខ្លួន (ស៊ិន សេងហុក ២០១៩)។ ប្រធានបទនៃការអប់រំ គឺមនុស្សពីព្រោះមានតែមនុស្សទេដែលអាចមាននូវការអប់រំ ឯសត្វ មិនមានទេ។ មនុស្សឋិតនៅក្នុងការប្រែប្រួល ពីព្រោះមនុស្សមិនទាន់ក្លាយជាមនុស្សពេញលេញ ហើយរបៀបនៃការទទួលស្គាល់ថាមនុស្សពេញលេញ គឺមានតែតាមរយៈការអប់រំតែមួយគត់។ ដំណើរការអប់រំមានន័យថា (means) មិនគ្រាន់តែមានការចាប់ផ្តើមប៉ុណ្ណោះទេ តែក៏ទាមទារឱ្យមានគោលដៅចុងបញ្ចប់ផងដែរ (end) ហើយការប្រែក្លាយនេះគួរតែបញ្ចប់ត្រឹម "ជា...(to be)"។ ហេតុនេះហើយ តើអ្វីដែលយើងរំពឹងថាជាគោលដៅ ឬចុងបញ្ចប់នៃការអប់រំ? ក្នុងន័យពិតប្រាកដរបស់វាគឺជាដំណើរការនិងការប្រែក្លាយគោលដៅ ឬទីចុងបញ្ចប់របស់មនុស្ស ដើម្បីធ្វើឱ្យគេក្លាយខ្លួនទៅជាមនុស្សពិត (real man) (ប៉ាន់ វុត្ថា ២០០៦)។

ដើម្បីឱ្យពលរដ្ឋរបស់ប្រទេសខ្លួនក្លាយទៅជាពលរដ្ឋពេញលេញ ប្រកបដោយចំណេះដឹង ជំនាញ និងឥរិយាបថល្អ ប្រទេសនីមួយៗលើសកលលោកតែងតែយកចិត្តទុកដាក់លើវិស័យអប់រំ ជាពិសេសការរៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សា ក្នុងគោលបំណងកសាងធនធានមនុស្សដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន។ ជាក់ស្តែងការអប់រំនៅកម្ពុជាត្រូវបានគ្រប់គ្រង ដោយរដ្ឋតាមរយៈក្រសួងអប់រំនៅថ្នាក់ជាតិ និងដោយមន្ទីរអប់រំនៅថ្នាក់ខេត្ត។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃ

ព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការរហូតដល់បច្ចុប្បន្ន ដោយព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលចែកចេញជា១៧ជំពូក និង១៦០មាត្រា ក្នុងនោះមាន៤មាត្រាបាន កំណត់ពាក់ព័ន្ធនឹងការអប់រំ គឺមាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃជំពូកទី៦ ស្តី អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច។ ត្រង់មាត្រា ៦៧ ចែងថា " រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោល ការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។ រដ្ឋគ្រប់គ្រង គ្រឹះស្ថានសិក្សា និងថ្នាក់សិក្សាសាធារណៈ និងឯកជននៅគ្រប់ភូមិសិក្សា"។ ដោយឡែក ត្រង់ មាត្រា២៣ នៃច្បាប់ស្តីពីការអប់រំ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ នា សម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ហើយប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម ចុះ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ក្នុងប្រយោជន៍លម្អិតច្បាប់នានាដោយ ផ្អែកលើរដ្ឋធម្មនុញ្ញ ដើម្បីឱ្យ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់លើវិស័យអប់រំ បានចែងថា "ក្រសួងទទួលបន្ទុក វិស័ យអប់រំត្រូវកំណត់ជាក់លាក់នូវកម្មវិធីសិក្សាគោលសម្រាប់ការអប់រំចំណេះទូទៅ ដែលមាន លក្ខណៈជាកាតព្វកិច្ច សម្រាប់អនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់នៅព្រះរាជាណាចក្រ កម្ពុជា។ ការអប់រំសីលធម៌ និងពលរដ្ឋវិជ្ជា ការអប់រំឱ្យចេះរួមរស់ជាមួយគ្នា ការអប់រំដើម្បីសន្តិភាព ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយចីរភាព ការអប់រំឱ្យចេះគោរពវប្បធម៌ផ្សេងៗ និងតម្លៃប្រពៃណី ត្រូវកំណត់ជាធាតុសំខាន់នៃកម្មវិធីសិក្សាគោល។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ ក្របខ័ណ្ឌលម្អិតនៃកម្មវិធីសិក្សា សម្រាប់អនុវត្តនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជា"។

តាមរយៈសៀវភៅកម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរ កម្រិតមធ្យមសិក្សាទុតិយភូមិ របស់ក្រសួងអបរំ យុវជន និងកីឡា បោះពុម្ព២០១៨ ត្រង់សេចក្តីផ្តើមទំព័រទី១ បានរៀបរាប់ថា ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់កម្មវិធីសិក្សា ជាបន្តបន្ទាប់ច្រើនលើកច្រើន គ្រាមកហើយ។ ដំណាក់កាលទី១ ចាប់ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៦ ក្រសួងអប់រំ យុវជន និង កីឡា បានអនុវត្តប្រព័ន្ធអប់រំ១០ឆ្នាំ គឺនៅបឋមសិក្សា៤ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និង មធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ដំណាក់កាលនេះ វិស័យអប់រំយើង បានប្រមែប្រមូលអ្នកចេះដឹង ដែលនៅសល់ពីការសម្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើជាគ្រូបង្រៀន ដោយអនុវត្ត គោលការណ៍ អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ។ ដំណាក់កាលទី២ ចាប់ពីឆ្នាំ១៩៨៧ដល់ឆ្នាំ១៩៩៦ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែ ទម្រង់ប្រព័ន្ធអប់រំចំណេះទូទៅ ដោយប្តូរពីប្រព័ន្ធអប់រំ១០ឆ្នាំ មកអនុវត្តប្រព័ន្ធអប់រំ១១ឆ្នាំ គឺនៅ បឋមសិក្សា៥ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ក្នុងដំណាក់ កាលនេះ យើងបានធ្វើការកែលម្អបន្ថែមលើរបាយម៉ោងសិក្សា និងខ្លឹមសារសំខាន់ៗ មួយ

ចំនួន ជាពិសេសបានពង្រឹងនិងពង្រីកទៅលើផ្នែកភាសាខ្មែរនិងអក្សរសាស្ត្រជាតិខ្មែរ។ ដំណាក់កាលទី៣ ចាប់ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៤ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ដោយបានប្ដូរពីប្រព័ន្ធអប់រំ១១ឆ្នាំ មកអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ គឺនៅបឋមសិក្សា៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ។ ក្នុងដំណាក់កាលនេះ បានកែសម្រួលលើ ទម្រង់ មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត។ ដំណាក់កាលទី៤ ចាប់ពីឆ្នាំ២០០៥ដល់ឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ និងបានធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សាជាបន្តបន្ទាប់ថែមទៀតគឺ សិស្សសិក្សាតាមជម្រើសមុខវិជ្ជា និងសិក្សាតាមបណ្ដុំមុខវិជ្ជា មានបណ្ដុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ដំណាក់កាលទី៥ នៅក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់មួយលើកទៀត គឺបានអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មីគ្រប់មុខវិជ្ជា ព្រមទាំងបានបន្ថែមមុខវិជ្ជាមួយចំនួនទៀត។ ក្នុងដំណាក់កាលនេះ បានកែសម្រួលលើទម្រង់មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត សំដៅធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ននិងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត ព្រមទាំងធ្វើឱ្យស្របតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចសង្គម និងវប្បធម៌ ក្នុងតំបន់និងអន្តរជាតិ។

ក្នុងសៀវភៅកម្មវិធីសិក្សាលម្អិតអក្សរសាស្ត្រខ្មែរខាងលើ ត្រង់ទំព័រដដែល បានបន្ថែមថា ការកែទម្រង់កម្មវិធីសិក្សា ជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ចសង្គម និងវប្បធម៌កម្ពុជាក្នុងសម័យបច្ចុប្បន្ន និងស្របពេលដែលពិភពលោកមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ទស្សនវិជ្ជាថ្មី មានទំនោរកំណត់បញ្ចូលលទ្ធផលសិក្សា ជាគោលបំណងចម្បងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សាបានធ្វើឱ្យមានការផ្លាស់ប្ដូរទស្សនៈ គោលគំនិត គរុកោសល្យ និងវិធីសាស្ត្របង្រៀន។ ការកែទម្រង់កម្មវិធីសិក្សា ជាផ្នែកមួយនៃកំណែទម្រង់វិស័យអប់នៅកម្ពុជា ដែលក្រសួងអប់រំ យុវជន និងកីឡាមានចក្ខុវិស័យ កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនលើផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំដោយមានគោលនយោបាយចំនួនពីរគឺ (១)ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត និង(២)ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹងនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបាន គឺត្រូវពឹងផ្អែកទៅលើសរសរស្ដម្ភទាំង៥មាន (១)ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថាន (៣)

ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវាយតម្លៃសិក្សាដូចជាការប្រឡង វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និង(៥)ការកែទម្រង់ឧត្តមសិក្សា។

រាល់ពេលមានការកែប្រែកម្មវិធីសិក្សាម្តងៗ ក្រសួងអប់រំតែងតែបានធ្វើការផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការតាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាលដល់មន្ត្រីជាន់ខ្ពស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជាមន្ត្រីមន្ទីរអប់រំ មន្ត្រីអប់រំស្រុក នាយកសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមួយចំនួន។ លើសពីនេះទៅទៀតក្រសួងក៏បានបោះពុម្ពសៀវភៅឬឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីចែកចាយ និងបានផ្ទុកឯកសារទាំងនោះលើគេហទំព័ររបស់ក្រសួងផងដែរ។ ក៏ប៉ុន្តែទោះបីក្រសួងបានប្រកាសដាក់ឱ្យប្រើប្រាស់យ៉ាងណាក៏ដោយ ក៏វិទ្យាល័យទាំងឡាយនៅក្នុងប្រទេសកម្ពុជាមិនទាន់បានអនុវត្តបានទាំងស្រុងនោះទេ ពោលគឺត្រូវមានចំណារឯកភាពលើមន្ទីរលើសេចក្តីណែនាំ ឬប្រកាសនោះទៀតទើបសាលារៀនអាចអនុវត្តបាន។ បន្ទាប់ពីទទួលបានចំណារពីមន្ទីរអប់រំហើយ នាយកឬគណៈនាយកចាប់ផ្តើមចាត់ចែងរៀបចំកិច្ចប្រជុំជាមួយប្រធានក្រុមបច្ចេកទេសគ្រប់មុខវិជ្ជាទាំងអស់ និងណែនាំឱ្យប្រធានក្រុមបច្ចេកទេសផ្សព្វផ្សាយដល់សមាជិកក្រុម ដោយប្រធានក្រុមបច្ចេកជាអ្នកគាំទ្រត្រួតពិនិត្យ និងតាមដានការអនុវត្តនេះ។ ចំពោះលោកគ្រូអ្នកគ្រូដែលជាអ្នកអនុវត្តផ្ទាល់នៅក្នុងថ្នាក់រៀន ត្រូវប្រើប្រាស់សៀវភៅសិក្សាគោល សៀវភៅគ្រូ បំណែងចែកកម្មវិធីសិក្សា និងសម្ភារឧបទ្ទេសក្នុងការបង្រៀនប្រចាំថ្ងៃរបស់ពួកគាត់។ រាល់ការលំបាក និងបញ្ហាប្រឈមទាំងឡាយ ដែលលោកគ្រូ អ្នកគ្រូជួបប្រទះក្នុងការអនុវត្តកម្មវិធីសិក្សាត្រូវបានលើកឡើងក្នុងអង្គប្រជុំក្រុមបច្ចេកទេសជារៀងរាល់ខែ និងធ្វើរបាយការណ៍ជូនគណៈនាយក បន្ទាប់មកគណៈនាយករាយការណ៍ និងសំណូមពរទៅមន្ទីរ ហើយមន្ទីរក៏បញ្ជូនបន្តទៅក្រសួងដើម្បីដោះស្រាយបញ្ហានោះ ប៉ុន្តែរាល់ការលំបាកដែលបានលើកឡើងហាក់គ្មានការឆ្លើយតបតាមតម្រូវការនោះឡើយ (លឹម កិត្យា ២០១៨)។

## ១.២.បញ្ហានៃការស្រាវជ្រាវ

ផ្អែកលើសៀវភៅស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនរបស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០១៦ ត្រង់ទំព័រទី១០បានលើកឡើងថា លោកគ្រូ អ្នកគ្រូត្រូវមានចំណេះដឹងស៊ីអំពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់និងបង្រៀនខ្លឹមសារមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សានោះឱ្យបានល្អ ដោយលោកគ្រូ អ្នកគ្រូអាចគូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗនៃកម្មវិធីសិក្សាដែលត្រូវបង្រៀនឱ្យបានច្បាស់លាស់មុននឹងបង្រៀន ដើម្បីបង្ហាញថាខ្លួនបានយល់ខ្លឹមសារនោះបានត្រឹមត្រូវល្អ។ តែគួរឱ្យស្តាយ បើយើងពិនិត្យមើលលទ្ធផលនៃការសិក្សា

របស់អ្នកស្រាវជ្រាវឈ្មោះ លឹម កិត្យា ដែលបានរកឃើញក្នុងនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ខ្លួន ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ ឯកទេសការគ្រប់គ្រងនិងផែនការអប់រំ នៅវិទ្យាស្ថានជាតិអប់រំ លើប្រធានបទ "ចំណេះដឹង និងទស្សនៈគ្រូបង្រៀនវិទ្យាល័យចំពោះកម្មវិធីសិក្សា" ដែលបានធ្វើឡើងនៅវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៨កន្លងទៅថ្មីៗនេះបានបង្ហាញថា ប្រហែល៩០ភាគរយនៃលោកគ្រូ អ្នកគ្រូមានចំណេះដឹងតិចតួចលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ឬក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាគោល ស្តង់ដារកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត។ លោកគ្រូ អ្នកគ្រូចំនួន៨២ភាគរយយល់ច្រឡំពាក្យកម្មវិធីសិក្សាទៅនឹងបំណែងចែកមេរៀន ដែលត្រូវបង្រៀនក្នុងមួយឆ្នាំសិក្សាដោយរៀបរៀងចេញពីសៀវភៅសិក្សាគោល។ លើសពីនេះទៅទៀត ពួកគាត់យល់ឃើញថាការអភិវឌ្ឍកម្មវិធីសិក្សាថ្មី គឺសំដៅលើការកែប្រែឬផ្លាស់ប្តូរសៀវភៅសិក្សាគោលថ្មី។ ហើយការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព គឺសំដៅលើការបញ្ចប់មេរៀនដែលមានក្នុងសៀវភៅសិក្សាគោល ឬបំណែងចែកមេរៀន ដែលត្រូវបង្រៀនប្រចាំឆ្នាំដែលបានកំណត់ហើយសិស្សមានគុណភាព ឬលទ្ធផលសិក្សាល្អទៀត ប៉ុន្តែ ៨៧ភាគរយនៃពួកគាត់ (លោកគ្រូ អ្នកគ្រូ) បានឱ្យតម្លៃទៅលើការបង្រៀនទាន់បំណែងចែកមេរៀន ឬផែនការបង្រៀនប្រចាំឆ្នាំ ជាជាងគុណភាពទៅវិញ ដោយសារខ្លាចទទួលការស្តីបន្ទោសពីថ្នាក់លើ។

តែទោះជាយ៉ាងណា នេះជាករណីសិក្សាមួយដ៏តូចប៉ុណ្ណោះមិនមែនសំដៅលើក្របខណ្ឌថ្នាក់ជាតិឡើយ ប៉ុន្តែក៏ជាចំណុចគួរឱ្យព្រួយបារម្ភផងដែរសម្រាប់ចំណេះដឹងរបស់គ្រូបង្រៀនកម្ពុជាទូទៅទាក់ទងនឹងកម្មវិធីសិក្សា ពីព្រោះពួកគាត់ជាអ្នកអនុវត្តផ្ទាល់នូវកម្មវិធីសិក្សាដែលក្រសួងដាក់ឱ្យ។ គ្រូបង្រៀនគឺជាមនុស្សសំខាន់បំផុតក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា ដោយពួកគាត់ត្រូវប្រើប្រាស់ចំណេះដឹង បទពិសោធន៍និងជំនាញវិជ្ជាជីវៈរបស់គាត់ ម្យ៉ាងទៀត គាត់ជាមនុស្សមានទំនួលខុសត្រូវខ្ពស់ក្នុងការណែនាំកម្មវិធីសិក្សាទៅដល់សិស្សក្នុងថ្នាក់រៀន (Carl A., 2009)។ ទោះបីកម្មវិធីសិក្សាល្អប៉ុណ្ណាក៏ដោយ ប្រសិនបើគ្រូបង្រៀនមិនបានអនុវត្តប្រកប ដោយប្រសិទ្ធភាពនោះទេ យើងនឹងមិនអាចសម្រេចឱ្យបាននូវវត្ថុបំណងរបស់កម្មវិធីសិក្សានោះទេ។ ដូចនេះដើម្បីអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពលុះត្រាតែលោកគ្រូ អ្នកគ្រូដែលជាអ្នកអនុវត្តនៅក្នុងថ្នាក់រៀនផ្ទាល់បានយល់ដឹងពីវត្ថុបំណង ខ្លឹមសារមេរៀន វិធីសាស្ត្រ និងបច្ចេកទេសក្នុងការបង្រៀន និងវិធីសាស្ត្រក្នុងការវាយតម្លៃសមត្ថភាពសិស្សបានល្អ ហើយត្រូវអនុវត្តនៅក្នុងដំណើរការបង្រៀនរបស់គាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កម្មវិធីសិក្សាផងដែរ (Gurol, 2004)។ ដើម្បីធានាឱ្យការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនត្រូវតែធ្វើកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវ និងប្រាស្រ័យទាក់ទងជាមួយប្រធានក្រុមបច្ចេកទេស

ជាញឹកញាប់ និងទៀងទាត់ដើម្បីទទួលបានដំបូន្មាន និងជំនួយបច្ចេកទេស។ ការអប់រំផ្តោតលើលទ្ធផល គឺជាកម្មវិធីសិក្សាថ្មីដើម្បីធានាថាការអនុវត្តប្រកប ដោយប្រសិទ្ធភាព លុះត្រាតែគ្រូបង្រៀនយល់ដឹងពីវាឱ្យបានច្បាស់និងមានសម្ភារសិក្សា និងជំនួយក្នុងការបង្រៀន ឱ្យបានគ្រប់គ្រាន់ (Carl A. , 1997) ។

ដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងរបស់កម្មវិធីសិក្សា នាយកសាលាមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀន។ ជាក់ស្តែងតាមរយៈសៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ របស់នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ បោះពុម្ពឆ្នាំ២០១៦ ត្រង់ទំព័រ៦៧ បានសរសេររៀបរាប់ពីភារកិច្ចរបស់នាយកសាលាទាក់ទងនឹងការងារបច្ចេកទេសគរុកោសល្យថា នាយកសាលាមានភារកិច្ចពិនិត្យ និងសម្រេចលើការរៀបចំកាលវិភាគ និងបែងចែកកម្មវិធីសិក្សាសម្រាប់ការបង្រៀន និងរៀន ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់តាមមុខវិជ្ជា ផ្គត់ផ្គង់សៀវភៅសិក្សាគោល ឯកសារនិងសម្ភារផ្សេងៗ និងជំរុញការបញ្ចប់កម្មវិធីសិក្សាគ្រប់ថ្នាក់និងគ្រប់មុខវិជ្ជាប្រកបដោយគុណភាព។

កម្មវិធីសិក្សាថ្មីដែលបានផ្លាស់ប្តូរពីកម្មវិធីសិក្សាផ្តោតលើខ្លឹមសារ មកជាកម្មវិធីសិក្សាដែលផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងពីការរៀនដោយទន្ទេញចាំមាត់មកជាការបង្ហាញលទ្ធផលសិក្សា មានបញ្ហាជាច្រើនបានកើតឡើងដូចជា គ្រូបង្រៀនមិនបានបណ្តុះបណ្តាលត្រឹមត្រូវ និងសមស្របនូវកម្មវិធីសិក្សាថ្មី ខ្វះខាតធនធាននិងការគាំទ្រពីរដ្ឋាភិបាល។ ការអនុវត្តកមម្មវិធីសិក្សាមានការរំខានពីថ្នាក់លើ ដោយមូលហេតុថាពួកគេតែងតែធ្វើការផ្លាស់ប្តូរជាញឹកញាប់នូវកម្មវិធីសិក្សា។ ការកើនឡើងនូវកិច្ចការរដ្ឋបាលគឺជាផ្នែកមួយនៃបញ្ហាប្រឈមផងដែរ។ លើសពីនេះទៅទៀត អ្នកគ្រប់គ្រងមិនបានបណ្តុះបណ្តាលត្រឹមត្រូវក្នុងការគ្រប់គ្រងឬគាំទ្រក្នុងការផ្លាស់ប្តូរកម្មវិធីសិក្សានោះទេ (Spady, W. and Marshall, k., 1991)។ ជាក់ស្តែងតាមរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ ទំព័រទី៦៦ ចំណុចទី៣ ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការអប់រំបច្ចេកទេស និងកែលម្អកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅបានលើកឡើងពីបញ្ហា ជាច្រើនដែលបានជួបប្រទះពេលអនុវត្តកម្មវិធីសិក្សានៅកម្រិតសាលារៀន ដោយលោកគ្រូ អ្នកគ្រូមិនអាចអនុវត្តកម្មវិធីសិក្សា បានពេញលេញ បណ្តាលមកពីកត្តាមួយចំនួនដូចជាកត្តាគ្រោះធម្មជាតិ និងហានីភ័យផ្សេងៗ ការឈប់សម្រាកក្រៅផ្លូវការ និងការបំពេញភារកិច្ចរបស់គ្រូនៅមានកម្រិត ការប្រើវិធី-សាស្រ្តបែបទន្ទេញចាំមាត់នៅតែកើតមាន កង្វះខាតអ្នកសម្របសម្រួលកម្មវិធីសិក្សាកម្រិតថ្នាក់ស្រុកនៅតែជាបញ្ហាចោទនៅឡើយ ការយល់ដឹងទាក់ទងទៅនឹងគោលនយោបាយកម្មវិធី

សិក្សានៅមានកម្រិតទាបក្នុងចំណោមគ្រូបង្រៀនទាំងអស់ និងការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា នៅមានកម្រិតនៅឡើយ។ ដោយឡែកតាមរយៈការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ សៀវភៅផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ ទំព័រទី១៨ ត្រង់បញ្ហាប្រឈមបានលើកឡើងថា គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្រ្ត បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទ្ទេស រោងជាង ស្របតាមកម្មវិធីសិក្សានៅឡើយទេ។

ទោះបីជាមានការលើកឡើងពីស្ថានភាព និងបញ្ហាប្រឈមនានានៃការអនុវត្តកម្មវិធីសិក្សាយ៉ាងណាក៏ដោយ ក៏ពុំទាន់មានការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅទៅលើប្រសិទ្ធភាពនៃការដឹកនាំការអនុវត្ត និងប្រសិទ្ធភាពការអនុវត្តកម្មវិធីសិក្សាបានយ៉ាងណានៅឡើយទេនៅកម្រិតវិទ្យាល័យ ស្របពេលដែលកម្មវិធីសិក្សារបស់ប្រព័ន្ធអប់រំកម្ពុជាមានការកែប្រែជាញឹកញាប់ ដើម្បីឱ្យដើរទាន់សម័យកាលអភិវឌ្ឍនៃសង្គមក៏ដូចជាក្នុងបរិបទតំបន់ និងពិភពលោកផងដែរ។

## ១.៣.គោលបំណងនៃស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់ចំនួនពីរគឺ៖

១. រកឱ្យឃើញពីប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលានៅកម្រិតវិទ្យាល័យ។

២. រកឱ្យឃើញពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យ។

## ១.៤.សំណួរស្រាវជ្រាវ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ អ្នកស្រាវជ្រាវត្រូវដោះស្រាយលើសំណួរចំនួនពីរគឺ៖

១. តើការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលានៅវិទ្យាល័យមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ?

២. តើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅវិទ្យាល័យមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ?

## ១.៥.សម្មតិកម្ម

- នាយកសាលានៅវិទ្យាល័យដឹកនាំការអនុវត្តកម្មវិធីសិក្សាបានល្អ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ឆ្លើយតបតាមស្តង់ដារនាយកសាលារៀន។

○ ការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅវិទ្យាល័យ មានលក្ខណៈល្អប្រសើរ ដែលអាចជួយឱ្យសិស្សទទួលបានពិតប្រាកដនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងលទ្ធផលសិក្សាល្អ។

## ១.៦.សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងបង្ហាញអ្នកអានពីប្រសិទ្ធភាព នៃការដឹកនាំការអនុវត្តរបស់នាយកសាលា និងការអនុវត្តផ្ទាល់នូវកម្មវិធីសិក្សារបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យ ថាតើមានប្រសិទ្ធភាពយ៉ាងណាខ្លះ និងបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងអំឡុងពេលដឹកនាំការអនុវត្តរបស់នាយក និងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ដើម្បីក្លាយជាប្រយោជន៍ដល់ការកែលម្អចំណុចខ្វះខាតក្នុងការអភិវឌ្ឍកម្មវិធីសិក្សាថ្មីបន្តទៅមុខទៀត។ សង្ឃឹមថាស្នាដៃស្រាវជ្រាវនេះអាចជាឯកសារជំនួយ ឬជាទុនដល់អ្នកសិក្សាជំនាន់ក្រោយ ក្នុងការក្រេបយកចំណេះដឹងទាក់ទងនឹងកម្មវិធីសិក្សា និងការអនុវត្តកម្មវិធីសិក្សា ឬទុកជាគម្រូសម្រាប់អ្នកស្រាវជ្រាវក្រោយៗទៀត។

## ១.៧.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះ ត្រូវបានធ្វើឡើងនៅដើមឆ្នាំសិក្សា២០១៩-២០២០ និងនៅវិទ្យាល័យចំនួន៣ប៉ុណ្ណោះក្នុងខេត្តតាកែវ ព្រោះអាស្រ័យលើកត្តាពេលវេលា និងធនធាន។ ការស្រាវជ្រាវនេះ ផ្តោតតែលើការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលា និងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យប៉ុណ្ណោះ មិនផ្តោតលើអ្វីក្រៅពីនេះឡើយ។ អ្នកស្រាវជ្រាវនឹងធ្វើការប្រមូលទិន្នន័យតាមរយៈការផ្តល់កម្រងសំណួរបែបបរិមាណវិស័យ និងគុណវិស័យពីគណៈគ្រប់គ្រង (នាយក នាយករង) និងគ្រូបង្រៀនគ្រប់មុខវិជ្ជាទាំងអស់លើកលែងតែគ្រូបង្រៀនមុខវិជ្ជាមួយចំនួនដូចជា សិល្បៈ កសិកម្ម កីឡា ពោងជាងជាដើម ដោយសារមុខវិជ្ជាទាំងនេះមិនមានសៀវភៅសិក្សាគោលច្បាស់លាស់ និងធ្វើឡើងត្រឹមកម្រិតថ្នាក់ទី១០ដល់ទី១២ប៉ុណ្ណោះ។ ការស្រាវជ្រាវនេះនឹងធ្វើការប្រមូលទិន្នន័យពីគណៈគ្រប់គ្រងចំនួន៩នាក់ និងគ្រូបង្រៀនចំនួន៥០នាក់។

## ១.៨.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជា៥ជំពូក ដែលជំពូកទី១ជាសេចក្តីផ្តើម មានបង្ហាញពីសាវតារ បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សម្មតិកម្ម សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី២ ជាការរំលឹកទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ មានបង្ហាញពីនិយមន័យនៃពាក្យនិងឃ្លាគន្លឹះនៃប្រធានបទ និងនិយមន័យពាក់ព័ន្ធមួយចំនួនដូចជា ការអនុវត្ត កម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា ប្រសិទ្ធភាព ការដឹកនាំ និងរង្វាយតម្លៃ។ លើសពីនេះទៅទៀត នឹងមានលើកយកឯកសារពាក់ព័ន្ធនឹងកម្មវិធីសិក្សាចំនួន២រួមមាន គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា និងក្របខណ្ឌកម្មវិធីសិក្សា។ ទ្រឹស្តីពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយក និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ក៏ត្រូវបានលើកយកបង្ហាញក្នុងជំពូកនេះផងដែរ។ ដោយឡែក ក៏មានរៀបរាប់នូវបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធីសិក្សាដែលបានជួបប្រទះកន្លងមក តាមរយៈស្នាដៃស្រាវជ្រាវ និងឯកសារផ្សេងៗទៀត។

ជំពូកទី៣នៃកិច្ចការស្រាវជ្រាវនេះ គឺវិធីសាស្ត្រនៃការស្រាវជ្រាវ ដោយមានរៀបរាប់ពីការរៀបចំការស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរនិងគោលបំណង និងការវិភាគទិន្នន័យ។

ជំពូកទី៤ មានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ ចែកចេញជាពីរផ្នែក ដែលឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរនៅក្នុងជំពូកទី១។ ផ្នែកទី១ជាការវិភាគទិន្នន័យលើកម្រងសំណួរទី១ និងផ្នែកទី២ជាការវិភាគទិន្នន័យលើកម្រងសំណួរទី២ ដែលផ្នែកនីមួយៗមានទម្រង់ដូចគ្នា រួមមានតារាងបង្ហាញព័ត៌មានស្តីពីអ្នកចូលរួមឆ្លើយសំណួរ តារាងបង្ហាញទិន្នន័យបែបបរិមាណវិស័យស្តីពីកម្រិតនៃការអនុវត្តសកម្មភាព និងមានការបកស្រាយ ព្រមទាំងពិភាក្សាលើទិន្នន័យតាមតារាងនីមួយៗធៀបនឹងទ្រឹស្តីផ្សេងៗ និងមានបង្ហាញពីបញ្ហាប្រឈមនិងសំណូមពរនានារបស់អ្នកឆ្លើយតបផងដែរ។

ជំពូកទី៥ ជាជំពូកចុងក្រោយបង្ហាញពីការសន្និដ្ឋាន សំណូមពរ និងអនុសាសន៍ផ្សេងៗរបស់អ្នកស្រាវជ្រាវ ទុកសម្រាប់អ្នកស្រាវជ្រាវបន្តក្រោយៗទៀត។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១.និយមន័យ

### ២.១.១.ការអនុវត្ត

*ការអនុវត្ត* មកពីពាក្យ "ការ" ផ្សំជាមួយពាក្យ "អនុវត្ត" មានន័យស្មើនឹងពាក្យ "អនុវត្តន៍" ដែរ ដែលមានន័យថា ការប្រព្រឹត្តតាម, ការធ្វើតាម, ការបណ្តោយតាម នេះបើយោងទៅតាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត។

តាមរយៈវចនានុក្រម Cambridge Dictionary បានផ្តល់និយមន័យរបស់ពាក្យ *ការអនុវត្ត ( Implementation)* ថាជាសកម្មភាពនៃការចាប់ផ្តើមប្រើប្រាស់គម្រោងឬប្រព័ន្ធអ្វីមួយ។

*ការអនុវត្ត ( Implementation)* គឺជាសកម្មភាពនៃការដាក់ចូលជាធរមាន ឬការបំពេញការងារ ដែលផ្តល់និយមន័យតាមរយៈ Dictionary.com។

តាម Merriam-Webster Dictionary *ការអនុវត្ត ( Implementation)* គឺជាទង្វើឬឧទាហរណ៍ នៃការអនុវត្តអ្វីមួយ ដំណើរការនៃការធ្វើឲ្យអ្វីមួយសកម្មឡើង ឬមានប្រសិទ្ធភាព។

### ២.១.២.កម្មវិធីសិក្សា

តាមសទ្ទានុក្រមក្នុងសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ឆ្នាំ២០១៦ ត្រង់ទំព័រទី២៦ បានផ្តល់និយមន័យ*កម្មវិធីសិក្សា* គឺជាក្របខណ្ឌអនុវត្តចំណេះដឹង និងបទពិសោធដែលមានឡើងដើម្បីអភិវឌ្ឍដល់សិស្សានុសិស្សឱ្យមានចំណេះដឹង ជំនាញ និងលក្ខណៈសម្បត្តិដែលបានកំណត់ទុក។ កម្មវិធីសិក្សាប្រៀបដូចជាផែនទីកំណត់ទិសដៅនៃការអភិវឌ្ឍដល់សិស្សានុសិស្សឱ្យឈានដល់មាត្រដ្ឋាននៃការរៀនសូត្រដែលជាគោលដៅ និងមានការវាយតម្លៃ ការស្វែងយល់ ដើម្បីឱ្យជ្រួតជ្រាបពីការវិវឌ្ឍទៅមុខនៃសិស្សានុសិស្សម្នាក់ៗ ក្នុងការអភិវឌ្ឍដើម្បីឈានដល់ស្តង់ដារដែលបានកំណត់ទុក។

តាមរយៈអត្ថបទស្រាវជ្រាវរបស់ឯកឧត្តម កង ឱម (បណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំ) ជាសាស្ត្រាចារ្យវិទ្យាសាស្ត្រអប់រំ និងជាជំនួយការនៃរាជបណ្ឌិត្យសភាកម្ពុជា នៅលើវែបសាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា បានចុះផ្សាយកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩កន្លងទៅ បានផ្តល់និយមន័យនៃពាក្យ *កម្មវិធីសិក្សា* ជា មុខវិជ្ជាសិក្សាទាំងឡាយដែលបានផ្តល់ឲ្យដោយស្ថាប័នអប់រំណាមួយ។ *កម្មវិធីសិក្សា* ជាមុខវិជ្ជាសិក្សាពេញលេញមួយដែលបានផ្តល់ឲ្យដោយសាលារៀន ចំណែកឯមុខវិជ្ជាសិក្សាវិញជាកម្មវិធីពេញលេញតាមមុខវិជ្ជាមួយ។ លោកបានបកស្រាយបន្ថែមថា *កម្មវិធីសិក្សា* មកពីពាក្យឡាតាំង

*Currere* ដែលមានន័យថា *រថ* ។ ដូច្នេះហើយ បានជាពាក្យសព្វថ្ងៃគេហៅជាភាសាអង់គ្លេសថា *Course of study* ដែលភាសាខ្មែរយើងហៅថា *មុខវិជ្ជាសម្រាប់សិក្សា* ។ សព្វថ្ងៃនេះពាក្យ *Course of study* ឬ *Curriculum* នេះ មានន័យប្រែប្រួលមិនដូចពីមុនទៀតទេ។

តាមរយៈស្នាដៃរបស់ Gerard Giordano (2004) ដែលមានចំណងជើងថា "Wartime Schools: How World War II Change American Education" ត្រង់ទំព័រទី១៦៦ បានលើកឡើងពីនិយមន័យដែលផ្តល់ដោយ Bonser នៅឆ្នាំ១៩២០ ថា *កម្មវិធីសិក្សា* គឺជាបទពិសោធន៍ទាំងឡាយ ដែលអ្នកសិក្សារំពឹងទុកថានឹងទទួលបាននៅក្នុងសាលារៀន ។

ចំណែក Gagne នៅឆ្នាំ១៩៦៧ បានលើកឡើងថា *កម្មវិធីសិក្សា* គឺជាការតម្រៀបខ្លឹមសារចំណេះដឹងទៅតាមលំដាប់លំដោយ ដើម្បីផ្តល់សមត្ថភាពចំណេះដឹងបន្ថែមទៅលើអ្វីដែលអ្នកសិក្សាធ្លាប់មានពីមុនរួចមកហើយ នេះបើយោងទៅអត្ថបទស្នាដៃរបស់ Elliot W. Eisner (2005) ដែលមានចំណងជើងថា " Reimagining Schools" ត្រង់ទំព័រទី២៥។

ដោយឡែក Malcolm Skilbeck (1984) តាមរយៈស្នាដៃរបស់គាត់ដែលមានចំណងជើងថា "School- Based Curriculum Development" ត្រង់ទំព័រទី៣៥ បានបង្ហាញនិយមន័យដែលផ្តល់ដោយ Smith, Stanley និង Shores នៅឆ្នាំ១៩៥៧ ថា *កម្មវិធីសិក្សា* ថាគឺជាការតម្រៀបបទពិសោធរបស់សិស្ស ឬនិស្សិតតាមលំដាប់លំដោយដើម្បីអប់រំពួកគេឱ្យចេះពីរបៀបគិត និងរបៀបធ្វើសកម្មភាពនានា ។

តាមរយៈអត្ថបទស្រាវជ្រាវរបស់ Robert J. Marzano (2003) ដែលមានចំណងជើងថា "What Works in Schools" ត្រង់ទំព័រទី១០៦ បានលើកឡើងពីនិយមន័យមួយចំនួន ដែលរកឃើញដោយ (១) Caswell និង Campbell នៅឆ្នាំ១៩៣៥ *កម្មវិធីសិក្សា* គឺជាការផ្សំឡើងនូវបទពិសោធន៍ទាំងឡាយ ដែលអ្នកសិក្សាទទួលបានក្រោមការបង្ហាត់បង្រៀនរបស់គ្រូ (២) Saylor និង Alexander នៅឆ្នាំ១៩៧៤ បានលើកឡើងយ៉ាងខ្លីថា *កម្មវិធី*សិក្សា រួមបញ្ចូល ឱកាសសិក្សាទាំងអស់ដែលផ្តល់ដោយសាលា និង (៣) ផ្តល់ដោយ Ovila នៅឆ្នាំ១៩៨២ បានបញ្ជាក់ថា *កម្មវិធីសិក្សា* គឺជាផែនការឬកម្មវិធីសម្រាប់បទពិសោធន៍ដែលអ្នកសិក្សាជួបប្រទះក្រោម ការដឹកនាំរបស់សាលា។

### ២.១.៣.ការអនុវត្តកម្មវិធីសិក្សា

ដោយយោងទៅតាមនិយមន័យដែលបានលើកឡើងនៅចំណុច ២.១.១. និងចំណុច ២.១.២.ខាងលើ យើងអាចសំយោគន័យផ្ទាល់នៃឃ្លាថា *ការអនុវត្តកម្មវិធីសិក្សា* គឺជាការប្រព្រឹត្តតាមឬការធ្វើតាមក្របខណ្ឌអនុវត្តចំណេះដឹង និងបទពិសោធដែលមានឡើងដើម្បីអភិវឌ្ឍ

ដល់សិស្សានុសិស្សឱ្យមានចំណេះដឹង ជំនាញ និងលក្ខណៈសម្បត្តិដែលបានកំណត់ទុកដោយក្រសួងអប់រំ យុវជន និងកីឡា។

តាមរយៈព្រឹត្តិប័ត្រសារព័ត៌មានស្តីពីការអប់រំ និងការអនុវត្ត (Journal of Education and Practice) ចុះផ្សាយនៅឆ្នាំ២០១៥ វ៉ុលទី៦ លេខ១៩ ត្រង់ទំព័រទី១៩៥ របស់អ្នកនិពន្ធ Odey, O.E. និង Opoh, A.F. (2015) បានលើកឡើងពីការផ្តល់និយមន័យផ្សេងៗគ្នានៃឃ្លា *ការអនុវត្តកម្មវិធីសិក្សា* ដែលកំណត់ដោយអ្នកស្រាវជ្រាវមួយចំនួនដូចជា Mezieobi នៅឆ្នាំ១៩៩៣ *ការអនុវត្តកម្មវិធីសិក្សា (Curriculum Implementation)* គឺជាដំណើរការនៃការអនុវត្តផែនការ ដែលក្នុងនោះមានការព្រមព្រៀងលើការសម្រេចចិត្ត សំណើរនិងគោលនយោបាយឱ្យមានប្រសិទ្ធភាព។ចំណែក Garba នៅឆ្នាំ២០០៤ បានកំណត់ន័យថា *ការអនុវត្តកម្មវិធីសិក្សា* គឺជាដំណើរការដែលដាក់កម្មវិធីសិក្សាឱ្យទៅជាការអនុវត្ត ដើម្បីសម្រេចបានគោលបំណងកម្មវិធីសិក្សាដែលបានកំណត់ទុក។ រីឯ Okebukola នៅឆ្នាំ២០០៤ យល់ឃើញថា *ការអនុវត្តកម្មវិធីសិក្សា* គឺជារការបកប្រែគោលបំណងរបស់កម្មវិធីសិក្សាទៅជាការអនុវត្តជាក់ស្តែង។ Ivowi នៅឆ្នាំ២០០៤ *ការអនុវត្តកម្មវិធីសិក្សា* គឺជាការបកប្រែទ្រឹស្តីទៅជាការអនុវត្តឬការយកសំណើរទៅជាសកម្មភាព។ រីឯនិយមន័យ ដែលផ្តល់ដោយ Afangideh នៅឆ្នាំ២០០៩ *ការអនុវត្តកម្មវិធីសិក្សា* គឺជាការទាញអ្នកសិក្សាឱ្យចូលទៅក្នុងឱកាសសិក្សាដែលបានគ្រោងទុក។ ដូចនេះ វាគឺជាគោល-នយោបាយរបស់រដ្ឋាភិបាលដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា។

សរុបមក *ការអនុវត្តកម្មវិធីសិក្សា* គឺជាសកម្មភាពដែលធ្វើឱ្យសម្រេចបាននូវផែនការស្តីពីការបង្រៀននិងរៀននៅក្នុងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

## ២.២.និយមន័យពាក់ព័ន្ធ

### ២.២.១.ប្រសិទ្ធភាព

តាមវចនានុក្រមភាសាខ្មែរសម្តេចសង្ឃរាជ ជួន ណាត ពាក្យ *ប្រសិទ្ធ* មានន័យថាធ្វើឱ្យសម្រេច ធ្វើឱ្យពេញគ្រប់គ្រាន់ ធ្វើឱ្យពូកែ។ ដូចនេះ *ប្រសិទ្ធភាព* សំដៅដល់ភាពធ្វើឱ្យសម្រេចកិច្ចការអ្វីមួយ ប្រកបដោយភាពពេញលេញគ្រប់គ្រាន់។

*ប្រសិទ្ធភាព (Efficiency)* គឺជាគុណភាពដែលអាចបំពេញភារកិច្ចបានជោគជ័យដោយមិនចាំបាច់ខ្ជះខ្ជាយពេលវេលាឬកម្លាំងឡើយ បើយោងទៅតាម Collins Cobuild Dictionary ។

តាមសទ្ទានុក្រម ក្នុងសៀវភៅគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ បោះពុម្ពឆ្នាំ២០១២ ទំព័រទី៩ បានផ្តល់និយមន័យថា *ប្រសិទ្ធភាព* សំដៅដល់សមត្ថភាពផលិត

លទ្ធផលផ្អែកលើវត្ថុបំណង។

### ២.២.២.ដឹកនាំ

*ដឹកនាំ* មានន័យថា បបួលឱ្យធ្វើ ឱ្យតាមដោយនូវសម្រួលចិត្ត ឱ្យជឿ ឱ្យព្រមតាម នេះបើតាមវចនានុក្រមភាសាខ្មែរសម្តេចសង្ឃរាជ ជួន ណាត ។ ដូចនេះ *ការដឹកនាំការអនុវត្ត* សំដៅដល់ការណែនាំអ្នកនៅក្រោមបង្គាប់ឱ្យធ្វើតាម ឬការនាំធ្វើដើម្បីសម្រេចកិច្ចការណាមួយ ពីសំណាក់អ្នកដឹកនាំ។

### ២.២.៣.វង្វាយតម្លៃ

*វង្វាយតម្លៃ* គឺជាដំណើរការវាស់វែងឬវាយតម្លៃលើការសម្រេចបាន ឬភាពរីកចម្រើនរបស់អ្នកសិក្សា។ វង្វាយតម្លៃសមត្ថភាពនៅក្នុងថ្នាក់រៀន (Formative Assessment) គឺជាការវាស់វែងភាពរីកចម្រើននិងលទ្ធផលសម្រេចបានរបស់សិស្សដែលមានគោលបំណងគាំទ្រ និងជួយពង្រឹងការសិក្សាស្របទៅតាមដំណើរការអប់រំ ដើម្បីឱ្យដល់តម្រូវការដែលចង់បាន។ វង្វាយតម្លៃថ្នាក់ជាតិ (Summative Assessment) គឺជាការវាស់វែងលទ្ធផលសម្រេចបានរបស់អ្នកសិក្សាក្នុងគោលបំណង ដើម្បីផ្តល់ព័ត៌មានអំពីថាតើអ្នកសិក្សាសម្រេចបានកម្រិតណាមួយនៅក្នុងពេលវេលាជាក់លាក់ណាមួយ។ វាដូចជាស្តង់ដារតេស្ត ឬការប្រឡងថ្នាក់ជាតិជាដើម។ វង្វាយតម្លៃដើរតួនាទីយ៉ាសំខាន់នៅក្នុងដំណើរការអប់រំផ្អែកលើលទ្ធផល។ វាបានជួយកំណត់ពីភាពរីកចម្រើននៃការសិក្សារបស់សិស្ស ដែលជាប្រភពព័ត៌មានយ៉ាងសំខាន់សម្រាប់ការធ្វើឱ្យប្រសើរឡើងថែមទៀត។ ការធ្វើតេស្តដើម្បីវាស់ស្ទង់សមត្ថភាពសិស្សមានគោលបំណងស្វែងយល់និងធ្វើឱ្យប្រសើរឡើងនូវការសិក្សារបស់សិស្ស។ វាជួយឱ្យការរំពឹងទុករបស់យើងដែលបានកំណត់នៅក្នុងលក្ខខណ្ឌស្តង់ដារ នៃគុណភាពសិក្សាដោយប្រមូលផ្តុំជាប្រព័ន្ធ វិភាគនិងបកស្រាយ ទុកជាភស្តុតាងដើម្បីកំណត់ពីការបំពេញភារកិច្ចរបស់យើងបានល្អកម្រិតណា តើវាដូចទៅនឹងអ្វីដែលយើងរំពឹងទុកនិងមានស្តង់ដាដែរឬទេ និងអាចប្រើប្រាស់លទ្ធផលនេះទុកជាឯកសារព័ត៌មាន ពន្យល់ និងកែលម្អការបំពេញភារកិច្ច (Angelo, 1995)។

## ២.៣.ឯកសារកម្មវិធីសិក្សា

### ២.៣.១.គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា

ការអភិវឌ្ឍកម្មវិធីសិក្សាក្នុងដំណាក់កាលទី៤ ចាប់ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៩ មានគោលនយោបាយផ្តោតសំខាន់លើការបរិយាយពីម៉ោងបង្រៀន និងផ្តល់ម៉ោងសិក្សាសម្រាប់កម្មវិធីសិក្សាបំណិនជីវិតមូលដ្ឋាន (ថ្នាក់ទី១ដល់ទី១០) ហើយផ្តល់មុខវិជ្ជាជម្រើសសម្រាប់សិស្សថ្នាក់ទី១១ និង១២ ដោយបន្ថែមម៉ោងសិក្សាតាមមុខវិជ្ជនីមួយៗ ដោយឱ្យសិស្សរៀនមុខវិជ្ជាតិច

ជាងមុន (សិស្សសិក្សាតាមជម្រើសមុខវិជ្ជា និងសិក្សាតាមបណ្តុំមុខវិជ្ជាមានបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)។ គោលនយោបាយនេះ រៀបចំឡើងសម្រាប់រយៈពេល៥ឆ្នាំ (២០០៥-២០០៩) ហើយត្រូវបានពិនិត្យឡើងវិញក្នុងឆ្នាំ២០០៩ ដោយអភិវឌ្ឍគោលនយោបាយថ្មីសម្រាប់ រយៈពេល៥ឆ្នាំទៀត (២០១០-២០១៤) ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍប្រទេសជាតិ (ហង់ជួន ណារ៉ុន ២០១៦)។

ដោយផ្អែកលើសៀវភៅគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា បោះពុម្ពឆ្នាំ២០០៤ កម្មវិធីសិក្សាជាតិត្រូវកំណត់ឱ្យបង្រៀន ៣៨ សប្តាហ៍ក្នុងមួយឆ្នាំសិក្សា ហើយចែកចេញជាបីផ្នែកសំខាន់ៗគឺ កម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីសិក្សាអប់រំមូលដ្ឋាន និងកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ។

**ក.កម្មវិធីសិក្សាចំណេះទូទៅ**

ពីឆ្នាំ២០០៥-២០០៩ វត្ថុបំណងនៃការអប់រំគឺអភិវឌ្ឍទេពកោសល្យ និងសមត្ថភាពរបស់សិស្ស ដើម្បីឱ្យគេក្លាយជាមនុស្សពេញលេញរីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបរាងកាយ។ ជាពិសេសឱ្យពួកគេអាចៈ

- មានចំណូលចិត្តនិងស្រឡាញ់ការសិក្សាដើម្បីបម្រើការងារនិងបន្តការសិក្សាពេញមួយជីវិតបាន។
- មានចំណេះដឹងផ្នែកភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យាជាមូលដ្ឋាន។
- មានចំណេះដឹង បំណិន និងឥរិយាបថចាំបាច់ដើម្បីលើកស្ទួយការថែរក្សាសុខភាពផ្នែកផ្លូវកាយបញ្ញាស្មារតីរបស់ខ្លួន ហើយចូលរួមចំណែកក្នុងការលើកស្ទួយការថែរក្សាសុខភាពក្រុមគ្រួសារ និងសង្គមឱ្យកាន់តែល្អប្រសើរថែមទៀត។
- មានសមត្ថភាពគ្រប់គ្រង មានទំនួលខុសត្រូវលើសកម្មភាព លើសេចក្តីសម្រេចរបស់ខ្លួន និងមានជំនឿជាក់លើខ្លួនឯង។
- មានការកោតសរសើរ និងឱ្យតម្លៃសារៈសំខាន់នៃគំនិតវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការបង្កើតថ្មី និងគំនិតច្នៃប្រឌិត។
- មានបំណិនក្នុងការបម្រើការងារ យល់ដឹងនិងមានឥរិយាបថវិជ្ជមានចំពោះការងារ មានសមត្ថភាពធ្វើការងារជាមួយអ្នកដទៃប្រកបដោយប្រសិទ្ធភាពនិងភាពសុខដុម
- មានសមត្ថភាពក្នុងការពិចារណាថ្លឹងថ្លែង មានស្មារតីទទួលខុសត្រូវ មានសីលធម៌ ចេះបែងចែក វិភាគ ដោះស្រាយបញ្ហាក្នុងគ្រួសារនិងសង្គម។
- ស្វែងយល់ និងឱ្យតម្លៃដល់អ្នកដទៃ ដល់អរិយធម៌វប្បធម៌ផ្សេងៗ ប្រវត្តិសាស្ត្រនានា ដែលអាចឈានទៅរកការកសាងស្មារតីសាធារណៈ ក្នុងន័យចេះគោរពសិទ្ធ

អ្នកដទៃ និងមានសមធម៌។

- ជាពលរដ្ឋសកម្ម មានគំនិតយល់ដឹងជ្រៅជ្រះអំពីការវិវត្តនៃសង្គម ប្រព័ន្ធគ្រប់គ្រងច្បាប់ទម្លាប់របស់ប្រទេសកម្ពុជា ចេះរក្សានិងលើកស្ទួយតម្លៃជាតិ មានស្មារតីស្រឡាញ់ជាតិសាសនា និងព្រះមហាក្សត្រ។
- យល់ដឹងពីសារៈសំខាន់ និងចេះការពារថែរក្សាបរិស្ថានធម្មជាតិសង្គមនិងវប្បធម៌។

ចំណុចគន្លឹះនៃការកែលម្អកម្មវិធីសិក្សាឆ្នាំ១៩៩៦ ដែលមានក្នុងរចនាសម្ព័ន្ធថ្មីមានដូចតទៅៈ

- សម្រួលកម្មវិធីសិក្សាផ្នែកដំបូងនៃបឋមសិក្សាដើម្បីឱ្យគ្រូអាចផ្តោតលើការបង្រៀនដែលអាចធ្វើឱ្យសិស្សទាំងអស់ចេះភាសាខ្មែរ និងចេះគណនាលេខស្ទាត់នៅដំណាច់ថ្នាក់ទី៣។
- ឱ្យនិយមន័យ និងបញ្ជាក់ពីការផ្តល់ការអប់រំបំណិនជីវិត និងផ្តល់ឱកាសអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។
- ប្រើគោលវិធីបញ្ចូលគ្នានូវមុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គមក្នុងការអប់រំមូលដ្ឋាន (ថ្នាក់ទី១-៣) ដើម្បីធ្វើឱ្យការបង្រៀនកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់។
- ការបង្រៀនភាសាបរទេសជាអាទិភាពមួយ។ ផែនការណែនាំការបង្រៀនភាសាបរទេសអាស្រ័យលើអត្ថិភាព ធនធានដែលមានក្នុងប្រទេសទាំងមូល។ ក្រសួងនឹងផ្តល់ការបង្រៀនភាសាបរទេសចាប់ពីថ្នាក់ទី៥ដល់ថ្នាក់ទី១២។ នៅបឋមសិក្សាថ្នាក់ទី៥-៦ ក្នុងដំណាក់កាលទី១ (២០០៥-២០០៩) ក្រសួងអប់រំ យុវជន និងកីឡា នឹងជំរុញសាលារៀនឱ្យបង្រៀនភាសាបរទេស ដោយប្រើធនធានឧបត្ថម្ភពីខាងក្រៅ និងប្រើម៉ោងក្នុងកម្មវិធីបំណិនជីវិតមូលដ្ឋាន។
- មានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់អភិវឌ្ឍស្តង់ដារមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា (ការគណនាលេខ) នៅដំណាច់ថ្នាក់ទី៣ និងទី៦ ព្រមទាំងមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាបរទេសក្នុងការប្រឡងថ្នាក់ជាតិនៅដំណាច់ថ្នាក់ទី៩។
- មានជម្រើសមុខវិជ្ជាសិក្សានៅថ្នាក់ទី១១ និងទី១២ ដោយមានបន្ថែមម៉ោងសិក្សាសម្រាប់មុខវិជ្ជានីមួយៗ ដើម្បីឱ្យសិស្សដែលបានបញ្ចប់ការសិក្សាកាន់តែមានគុណភាពល្អប្រសើរ។ មុខវិជ្ជាដែលសិស្សត្រូវរៀនមានចំនួនតិចជាងមុន។

- មានរចនាសម្ព័ន្ធច្បាស់លាស់ សម្រាប់ពង្រីកការផ្ដល់ការអប់រំនៅមធ្យមសិក្សាទុតិយភូមិតាមរយៈភាពជាដៃគូរដ្ឋ និងឯកជន។

*តារាង ២.១ ៖ បំណែងចែកម៉ោងសិក្សា សម្រាប់កម្មវិធីសិក្សាជាតិ (២០០៥-២០០៩)*

| បឋមសិក្សា | | |
|---|---|---|
| កម្មវិធីសិក្សាជាតិ | កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន | សរុប |
| ៥ម៉ោងសិក្សាក្នុង១ថ្ងៃដែល ១ម៉ោងសិក្សាមាន៤០នាទី (២៥X៤០នាទីក្នុង១សប្ដាហ៍) | ២-៥ម៉ោងសិក្សាក្នុង១សប្ដាហ៍ ១ម៉ោងសិក្សាមាន ៤០នាទី | ២៧-៣០ម៉ោង សិក្សាក្នុង ១សប្ដាហ៍ |
| មធ្យមសិក្សា (ថ្នាក់ទី៧-១០) | | |
| ៣០ម៉ោងសិក្សាក្នុង១សប្ដាហ៍ ១ម៉ោងសិក្សាមាន ៥០ នាទី (៣០X៥០នាទីក្នុង១សប្ដាហ៍) | ២-៥ម៉ោងសិក្សាក្នុង១សប្ដាហ៍ ១ម៉ោងសិក្សាមាន ៥០នាទី | ៣២-៣៥ម៉ោង សិក្សាក្នុង ១សប្ដាហ៍ |
| មធ្យមសិក្សា (ថ្នាក់ទី១១-១២) | | |
| ៣២ម៉ោងសិក្សាក្នុង១សប្ដាហ៍ ១ម៉ោងសិក្សាមាន ៥០ នាទី (៣២X៥០នាទីក្នុង១សប្ដាហ៍) | | ៣២ម៉ោងសិក្សា ក្នុង១សប្ដាហ៍ ១ម៉ោងសិក្សា មាន ៥០នាទី |

**ខ.កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ**

កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ដល់ទី១២ មានគោលបំណងមិនគ្រាន់តែពង្រឹង និងពង្រីកចំណេះដឹងដែលសិស្សទទួលបានពីកម្មវិធីសិក្សាអប់រំកម្រិតមូលដ្ឋានប៉ុណ្ណោះទេ គឺថែមទាំងផ្ដល់ការសិក្សាបែបតម្រង់ទិស ដើម្បីសិស្សមានសមត្ថភាពអាចបន្តការសិក្សានៅឧត្តមសិក្សា ឬសិក្សាឯកទេស ឬចូលរួមក្នុងជីវភាពសង្គម ដោយធានាថាសិស្សនឹងទទួលបាន៖

- ការចេះដឹងកាន់តែខ្ពស់ផ្នែកអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា។
- ការស្គាល់អត្តសញ្ញាណជាតិកាន់តែច្បាស់។
- ការអភិវឌ្ឍការយល់ដឹងកាន់តែខ្លាំងពីសីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេស។
- បំណិនជីវិតប្រចាំថ្ងៃចាំបាច់សម្រាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និង

ក្នុងសង្គមកម្ពុជា។

- ការយល់ដឹងកាន់តែទូលំទូលាយពីពិភពលោក និងគោលការណ៍វិទ្យាសាស្ត្រ។
- សមត្ថភាពកាន់តែខ្ពស់ក្នុងការទំនាក់ទំនងជាភាសាបរទេស។

កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិចែកចេញជា២កម្រិតទៀតគឺកម្រិតថ្នាក់ទី១០ និងថ្នាក់ទី១១-១២ ។

**គ.១.ថ្នាក់ទី១០**

គោលបំណងនៃកម្មវិធីសិក្សាថ្នាក់ទី១០ គឺពង្រឹងនិងពង្រីកចំណេះដឹងដែលសិស្សទទួលបានពីកម្រិតអប់រំមូលដ្ឋាន។ ទន្ទឹមនឹងនោះសាលារៀនត្រូវផ្តល់ការណែនាំតម្រង់ទិសដល់សិស្សអំពីជម្រើសមុខវិជ្ជាដែលត្រូវបន្តការសិក្សានៅថ្នាក់ទី១១ និងទី១២។

*តារាង ២.២ ៖ របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១០*

| មុខវិជ្ជាកម្មវិធីសិក្សា | ចំនួនម៉ោងសិក្សាក្នុង១សប្តាហ៍ |
|---|---|
| ភាសាខ្មែរ | ៦ |
| គណិតវិទ្យា | ៦ |
| សិក្សាសង្គម | ៦ |
| វិទ្យាសាស្ត្រ | ៦ |
| ភាសាបរទេស | ៤ |
| អប់រំកាយ កីឡា និងសុខភាព | ២ |
| សរុបម៉ោងសិក្សាកម្មវិធីសិក្សា | ៣០ |
| កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន(រួមទាំងអប់រំសិល្បៈ) | ២-៥ |
| សរុបម៉ោងសិក្សា | ៣២-៣៥ |

**គ.២.ថ្នាក់ទី១១-១២**

គោលបំណងនៃកម្មវិធីសិក្សាថ្នាក់ទី១១-១២ គឺផ្តល់ឱកាសឱ្យសិស្សជ្រើសរើសមុខវិជ្ជាឯកទេស ដើម្បីអភិវឌ្ឍចំណេះដឹងឱ្យកាន់តែស៊ីជម្រៅលើមុខវិជ្ជាណាមួយ ឬជ្រើសរើសមុខវិជ្ជាដែលមានមូលដ្ឋានសិក្សាឯកទេសវិជ្ជាជីវៈ ដើម្បីអាចបន្តការសិក្សានៅឧត្តមសិក្សា ឬសិក្សាឯកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គម។

*តារាង ២.៣ ៖ របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១១-១២*

| មុខវិជ្ជាចាំបាច់ | ចំនួនម៉ោងសិក្សាតាមមុខវិជ្ជានីមួយៗក្នុង ១ សប្តាហ៍ |
|---|---|
| អក្សរសាស្ត្រខ្មែរ | ៦ម៉ោង |
| អប់រំកាយ កីឡា និងសុខភាព | ២ម៉ោង |

| | |
|---|---|
| ភាសាបរទេស<br>(ត្រូវជ្រើសរើសយក១) | ភាសាអង់គ្លេស ៤ម៉ោង |
| | ភាសាបារាំង ៤ម៉ោង |
| គណិតវិទ្យា<br>(ត្រូវជ្រើសរើសយក១) | កម្រិតមូលដ្ឋាន ៤ម៉ោង |
| | កម្រិតខ្ពស់ ៨ម៉ោង |
| មុខវិជ្ជាជម្រើស | មុខវិជ្ជានីមួយៗត្រូវសិក្សា ៤ម៉ោង ក្នុង១សប្តាហ៍ |
| វិទ្យាសាស្ត្រ<br>(អាចមិនជ្រើសរើស ឬជ្រើសយក១ ឬ២ ឬ៣ ) | រូបវិទ្យា |
| | គីមីវិទ្យា |
| | ជីវវិទ្យា |
| | ផែនដី និងបរិស្ថានវិទ្យា |
| សិក្សាសង្គម<br>(អាចមិនជ្រើសរើស ឬជ្រើសយក១ ឬ២ ឬ៣ ) | សីលធម៌-ពលរដ្ឋវិជ្ជា |
| | ប្រវត្តិវិទ្យា |
| | ភូមិវិទ្យា |
| | សេដ្ឋកិច្ច |
| កម្មវិធីអប់រំវិជ្ជាជីវៈជម្រើស<br>(អាចមិនជ្រើសរើស ឬជ្រើសយក១ ឬ២ ឬ៣ ) | បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន(ICT)/បច្ចេកវិទ្យា |
| | គណនេយ្យ គ្រប់គ្រងពាណិជ្ជកម្ម |
| | មុខវិជ្ជាបច្ចេកវិទ្យាវិជ្ជាជីវៈតាមមូលដ្ឋាន |
| | ទេសចរណ៍ |
| | អប់រំសិល្បៈ ។ល។ |
| សិស្សដែលជ្រើសរើសគណិតវិទ្យាកម្រិតមូលដ្ឋាន ត្រូវជ្រើសរើសមុខវិជ្ជាជម្រើស ៤មកសិក្សា<br>សរុប ១៦ម៉ + (៤X៤) = ៣២ ម៉ោង ក្នុងមួយសប្តាហ៍<br>សិស្សដែលជ្រើសរើសគណិតវិទ្យាកម្រិតខ្ពស់ ត្រូវជ្រើសរើសមុខវិជ្ជាជម្រើស ៣មកសិក្សា<br>សរុប ២០ម៉ + (៣X៤) = ៣២ ម៉ោង ក្នុងមួយសប្តាហ៍ | |

នៅខែតុលា ឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡា បានចេញផ្សាយឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ និងទី១២ តាមរយៈលិខិតលេខ ៣៦៩៤ អយក. អកស.ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ដើម្បីអនុវត្តចាប់ពីឆ្នាំសិក្សា ២០១១-២០១២តទៅ ដែលអនុញ្ញាតឱ្យបង្រៀនគ្រប់មុខវិជ្ជាទៅតាមកម្មវិធីសិក្សានិងសៀវភៅសិក្សាថ្មី។ ដោយឡែក សម្រាប់ការសិក្សាមុខវិជ្ជាអប់រំវិជ្ជាជីវៈជម្រើស ក្រសួងទុកលទ្ធភាពឱ្យសាលារៀនអនុវត្តជាក់ស្តែង។ ដើម្បីឱ្យសិស្សបានសិក្សាគ្រប់មុខវិជ្ជា ក្រសួងបានកំណត់ចំនួនមេរៀន ខ្លឹមសារមេរៀន និងចំនួនម៉ោងសិក្សានៃមេរៀនក្នុងមុខវិជ្ជានីមួយៗឱ្យបានសមស្របទៅតាម បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ

និងវិទ្យាសាស្ត្រសង្គម។

តាមរយៈឯកសារណែនាំនេះ មានលម្អិតកម្មវិធីសិក្សាគ្រប់មុខវិជ្ជាសម្រាប់ថ្នាក់ទី១១ និងទី១២ ហើយនៅក្នុងមុខវិជ្ជានីមួយៗ បានកំណត់ចំនួនម៉ោងដែលត្រូវបង្រៀនសម្រាប់ឆមាសនីមួយៗ និងបានកំណត់ប្រធានវិញ្ញាសាសម្រាប់ការប្រឡងឆមាសផងដែរ តាមថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គម។ ចំពោះថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គមគឺត្រូវបង្រៀន មុខវិជ្ជាដូចគ្នា តែខុសគ្នាត្រង់តែចំនួនម៉ោងបង្រៀនប៉ុណ្ណោះ ហើយតម្រូវឱ្យអនុវត្តដូចគ្នាទាំងថ្នាក់ទី១១ និងទី១២ ។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជានីមួយៗ បានលម្អិតពីចំណងជើងមេរៀន និងរយៈពេលដែលត្រូវបង្រៀនទាំងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ មុខវិជ្ជាទាំងនោះមានដូចជា អក្សរសាស្ត្រខ្មែរ គណិតវិទ្យា ភាសាអង់គ្លេស ភាសាបារាំង រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីនិងបរិស្ថានវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា និងមុខវិជ្ជាសេដ្ឋកិច្ច។

*តារាង២.៤៖ របាយមុខវិជ្ជានិងម៉ោងសិក្សាសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងឯកសារណែនាំ*

| ល.រ | មុខវិជ្ជា | ថ្នាក់ទី១១ | | ថ្នាក់ទី១២ | |
|---|---|---|---|---|---|
| | | វិទ្យាសាស្ត្រ | វិទ្យាសាស្ត្រសង្គម | វិទ្យាសាស្ត្រ | វិទ្យាសាស្ត្រសង្គម |
| ១ | អក្សរសាស្ត្រខ្មែរ | ៣ | ៥ | ៣ | ៥ |
| ២ | គណិតវិទ្យា | ៥ | ៣ | ៥ | ៣ |
| ៣ | ភាសាអង់គ្លេស | ២ | ២ | ២ | ២ |
| ៤ | ភាសាបារាំង | ២ | ២ | ២ | ២ |
| ៥ | រូបវិទ្យា | ៣ | ២ | ៣ | ២ |
| ៦ | គីមីវិទ្យា | ៣ | ២ | ៣ | ២ |
| ៧ | ជីវវិទ្យា | ៣ | ២ | ៣ | ២ |
| ៨ | ផែនដីនិងបរិស្ថានវិទ្យា | ២ | ២ | ២ | ២ |
| ៩ | ប្រវត្តិវិទ្យា | ២ | ៣ | ២ | ៣ |
| ១០ | ភូមិវិទ្យា | ២ | ៣ | ២ | ៣ |
| ១១ | សីលធម៌-ពលរដ្ឋវិជ្ជា | ២ | ៣ | ២ | ៣ |
| ១២ | សេដ្ឋកិច្ច | ២ | ២ | ២ | ២ |

**បញ្ជាក់៖** នៅមានមុខវិជ្ជាអប់រំវិជ្ជាជីវៈជម្រើសផ្សេងទៀត ដែលក្រសួងទុកលទ្ធភាពឱ្យសាលារៀនអនុវត្តជាក់ស្តែង។

### ២.៣.២.ក្របខណ្ឌកម្មវិធីសិក្សា

នៅឆ្នាំ២០១៦ជាដំណាក់កាលទី៥ នៃការធ្វើកំណែទម្រង់កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា គឺបានអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មីគ្រប់មុខវិជ្ជា ព្រមទាំងបានបន្ថែមមុខវិជ្ជាមួយចំនួនទៀត។ ក្របខណ្ឌកម្មវិធីសិក្សានេះ បានកែសម្រួលលើទម្រង់មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត ។

ដោយផ្អែកលើសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស របស់ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពឆ្នាំ២០១៦ បានបង្ហាញនូវខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

**ក.ចក្ខុវិស័យនៃក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦**

ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស គឺធានាអប់រំពលរដ្ឋឱ្យមានលក្ខណៈសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

**ខ.គោលបំណងនៃក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦**

កម្មវិធីសិក្សាចំណេះទូទៅមានគោលបំណងអភិវឌ្ឍ៖

- សមត្ថភាពភាសាខ្មែរ និងភាសាបរទេសលើបំណិនទាំងបួន (ការស្ដាប់ ការនិយាយ ការអាន និងការសរសេរ) ឱ្យបានច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ និងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។
- ចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេសនិងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្រាប់ជាមូលដ្ឋានដល់ការបន្តការសិក្សា និងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។
- បំណិនសិល្បៈ សុខភាព កីឡា សោភ័ណភាព នវានុវត្តន៍ សហគ្រិនភាព និងពលរដ្ឋវិជ្ជាសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ និង សង្គម។
- បំណិនស្វ័យសិក្សា ស្រាវជ្រាវត្រិះរិះពិចារណា ប្រាស្រ័យទាក់ទងនិងដោះស្រាយបញ្ហាក្នុងបរិបទផ្សេងៗ ដោយប្រើប្រាស់ចំណេះដឹងទូលំទូលាយនិងស៊ីជម្រៅ។
- សមត្ថភាពក្នុងការវាយតម្លៃនិងធ្វើសេចក្តីសម្រេចចិត្តដោយសុភវិនិច្ឆ័យ និងការទទួលខុសត្រូវប្រកបដោយសេចក្តីថ្លៃថ្នូរ ចិត្តមេត្តាករុណានូវរាល់សកម្មភាពរបស់ខ្លួន ក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ និងសង្គម។
- ការយល់ដឹងក្នុងការបំពេញកាតព្វកិច្ច និងការប្រើប្រាស់សិទ្ធិពលរដ្ឋដោយមានការទទួល

ខុសត្រូវក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ សង្គម តំបន់ និងពិភពលោក។

- បំណិនសិក្សាពេញមួយជីវិតជួយលើកកម្ពស់គុណតម្លៃជាមូលដ្ឋាន និងបង្កើនចំណេះដឹងឱ្យទូលំទូលាយស្ដីពីសេដ្ឋកិច្ច នយោបាយ ប្រវត្តិសាស្ត្រ វប្បធម៌ សាសនា ជាតិសាសន៍ អត្តសញ្ញាណជាតិ និងបរិស្ថានរបស់ប្រទេសខ្លួន ប្រទេសក្នុងតំបន់ និងពិភពលោកដើម្បីលើកកម្ពស់ការអប់រំជាពលរដ្ឋសកម្ម និងពលរដ្ឋសាកលប្រកបដោយចីរភាព និងសន្តិសហវិជ្ជមានជាមនុស្សជាតិ។
- ស្មារតីស្រឡាញ់ ការពារនិងកសាងជាតិមាតុភូមិ និងពូជសាសន៍របស់ខ្លួនដោយអនុវត្តគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្សដោយឈរលើច្បាប់ជាតិ និងអន្តរជាតិ។

**គ. របាយម៉ោងកម្មវិធីសិក្សាតាមភូមិសិក្សា**

កម្មវិធីសិក្សាត្រូវកំណត់ឱ្យបង្រៀនចំនួន ៣៥ សប្ដាហ៍ ក្នុងមួយឆ្នាំសិក្សា។

**គ.១.ផ្នែកមធ្យមសិក្សាទុតិយភូមិ**

**គ.១.១ សមត្ថភាពរំពឹងទុក**

ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ សិស្សនឹងទទួលបាន៖

- **វិជ្ជាសម្បទា**
  - មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកអក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និង អភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌។
  - មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) និងភាសាបរទេស។
- **បំណិនសម្បទា**
  - មានបំណិនមូលដ្ឋានរឹងមាំ ច្បាស់លាស់ និងទូលំទូលាយផ្នែកអក្សរសាស្ត្រខ្មែរ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)។
  - មានបំណិនមូលដ្ឋានរឹងមាំនិងច្បាស់លាស់ផ្នែកគណិតវិទ្យា(គណនាប្រៀបធៀបពន្យល់ រិះគន់ បកស្រាយ និងដោះស្រាយបញ្ហា)។
  - មានបំណិនអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងសារគមនា-គមន៍ (ICT) មូលដ្ឋាន។
  - មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហារឹងមាំ និងទូលំទូលាយទាំងក្នុងការសិក្សា និងក្នុងសង្គម។

- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងការសិក្សា និងក្នុងសង្គម។
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម។
- មានសមត្ថភាពនិងសីលធម៌ក្នុងការការពារ និងពង្រីកភាពត្រឹមត្រូវ។

- **ចរិយាសម្បទា**
  - ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត។
  - ស្គាល់ និងឱ្យតម្លៃសន្តានចិត្តមេត្តា និងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ។
  - អភិរក្សនិងអភិវឌ្ឍវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ។
  - ស្រឡាញ់ និងឱ្យតម្លៃខ្ពស់ដល់បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
  - ស្រឡាញ់ភាពស្អាតបាតទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ។
  - មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និងហាត់កីឡា។
  - ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯង និងរបស់ក្រុម ទាំងក្នុងការសិក្សានិងការរស់នៅប្រចាំថ្ងៃ។

**គ.១.២.មុខវិជ្ជា**

មុខវិជ្ជាដែលត្រូវសិក្សាមាន អក្សរសាស្ត្រខ្មែរ គណិតវិទ្យា ភាសាបរទេស អប់រំកាយនិងកីឡា វិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា) សិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា ទស្សនវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) និងអប់រំសុខភាព។

**គ.១.៣.ម៉ោងសិក្សា**

**<u>បណ្តុំវិទ្យាសាស្ត្រ</u>**

*តារាង ២.៥ ៖ របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រ*

| ល.រ. | មុខវិជ្ជា | ថ្នាក់ទី | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | ៥ | ៥ | ៥ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ |

| | | | | |
|---|---|---|---|---|
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ៤ | ៤ | ៤ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | **៤០** | **៤០** | **៤០** |

**សម្គាល់៖** - ៦ថ្ងៃក្នុងមួយសប្តាហ៍ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។

-ជីវភាសាទី១ មាន៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## <u>**បណ្តុំវិទ្យាសាស្ត្រសង្គម**</u>

*តារាង ២.៦ ៖ របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រសង្គម*

| ល.រ. | មុខវិជ្ជា | ថ្នាក់ទី | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | ៦ | ៦ | ៦ |
| ២ | គណិតវិទ្យា | ៥ | ៥ | ៥ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ២ | ២ | ២ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ២ | ២ | ២ |
| ៩ | ជីវវិទ្យា | ២ | ២ | ២ |
| ១០ | ប្រវត្តិវិទ្យា | ៤ | ៤ | ៤ |

| | | | | |
|---|---|---|---|---|
| ១១ | ភូមិវិទ្យា | ៣ | ៣ | ៣ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ៣ | ៣ | ៣ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | **៤០** | **៤០** | **៤០** |

**សម្គាល់៖**- ៦ថ្ងៃក្នុងមួយសប្តាហ៍ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សា មានរយៈពេល៥០នាទី។

-ជីវភាសាទី ១ មាន៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## ២.៤.ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា

តាមសៀវភៅស្តង់ដានាយកសាលារៀន បោះពុម្ពនៅឆ្នាំ២០១៧ របស់នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការនៃក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ស្តង់ដានាយកសាលារៀនដែលផ្តោតជាសំខាន់លើគុណវុឌ្ឍិ និងបទពិសោធការងារ ការគិតបែបយុទ្ធសាស្ត្រ និងនវានុវត្តន៍ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងការរៀន ឧត្តមភាពរបស់នាយកសាលារៀន និងការផ្សារភ្ជាប់សាលារៀននិងសហគមន៍ ក្នុងគោលដៅពង្រឹងការផ្តល់សេវាអប់រំប្រកបដោយគុណភាព ភាពឆ្លើយតប និងសុខដុមនីយកម្មក្នុងអង្គភាព។

ស្តង់ដានាយកសាលារៀនមានគោលបំណងកំណត់គុណវុឌ្ឍិ និងសមត្ថភាពនាយកសាលារៀនទៅតាមប្រភេទគ្រឹះស្ថានសិក្សានីមួយៗ និងផ្លាស់ប្តូរឥរិយាបថក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីគាំទ្រដល់គ្រូបង្រៀនដែលបានបំពេញការងារទៅតាមសមត្ថភាព និងទេពកោសល្យ និងផ្សារភ្ជាប់សាលារៀន និងសហគមន៍។ ស្តង់ដានេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ ចាប់ពីនាយកមត្តេយ្យសិក្សា រហូតដល់វិទ្យាល័យ ដើម្បីធានាសមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ស្របតាមច្បាប់ស្តីពីការអប់រំ។

ស្តង់ដានាយកសាលារៀននៅកម្ពុជា ត្រូវបានបែងចែកជា៦គឺ៖ ស្តង់ដារទី(១)កម្រិតវប្បធម៌ និងបទពិសោធការងារ ស្តង់ដាទី(២)សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន ស្តង់ដាទី(៣) បំណិនត្រិះរិះពិចារណានិងនវានុវត្តន៍ ស្តង់ដាទី(៤) ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន ស្តង់ដាទី(៥) ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងរៀន និងស្តង់ដាទី(៦) ការផ្សារភ្ជាប់សាលារៀន និងសហគមន៍។

ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា ការបង្រៀននិងរៀន មិនអាចកាត់ផ្ដាច់ពីតួនាទីរបស់អ្នកដឹកនាំសាលារៀនដែលជាកត្តាជំរុញដ៏សំខាន់ ធានាដល់គុណភាពក្នុងការអនុវត្តការងាររបស់គ្រូបង្រៀន ពោលគឺនាយកសាលាត្រូវអនុវត្តតាមស្តង់ដាទី៥ គឺភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងរៀន។ ស្តង់ដានេះ ជួយនាយកសាលារៀនឱ្យទទួលបានជោគជ័យក្នុងការធ្វើឱ្យសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅ។ នាយកសាលារៀនចាំបាច់ត្រូវដឹកនាំការអនុវត្តនិងការកែលម្អកម្មវិធីសិក្សា ការបង្កើតបរិស្ថាននិងបរិយាកាសសិក្សា ការធ្វើអធិការកិច្ចនិងការវាយតម្លៃ ការបំពេញការងាររបស់គ្រូបង្រៀន និងការផ្តល់លទ្ធផលសិក្សា។

ស្តង់ដាទី៥មានសូចនាករសំខាន់ៗចំនួន៥រួមមាន៖ (១) ការគ្រប់គ្រងការរៀន និងការបង្រៀន (២) ការស្រាវជ្រាវ (៣) ការសហការ និងទំនាក់ទំនង (៤) ការអភិវឌ្ឍសមត្ថភាព និង (៥) ការធ្វើអធិការកិច្ចផ្ទៃក្នុង។

**ក. ការគ្រប់គ្រងការរៀន និងការបង្រៀន**

- ការធានាឱ្យមានសម្ភារៈសម្រាប់ដំណើរការបង្រៀននិងរៀន និងផ្តល់ឱកាសដល់គ្រូសិស្សប្រើប្រាស់សម្ភារៈ និងធនធានសិក្សាទាំងឡាយដោយឈរលើស្មារតីថ្នៃប្រឌិត និងថៃរក្សា។
- ការជំរុញ និងលើកទឹកចិត្តគ្រូប្រើចិត្តគរុកោសល្យច្បាស់លាស់ក្នុងការសម្របសម្រួលឱ្យសិស្សចេះរៀន។
- ការរៀបចំធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូ និងអនុវត្តផែនការនេះឱ្យបានទៀងទាត់។
- ការជំរុញគ្រូធ្វើផែនការបង្រៀន និងអនុវត្តផែនការនោះបានត្រឹមត្រូវជាប្រចាំ។
- ការសង្កេតការបង្រៀនរបស់គ្រូ និងផ្តល់ព័ត៌មានត្រឡប់ប្រកបដោយការលើកទឹកចិត្ត។
- ការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនរើសអើង។
- ការជំរុញគ្រូបង្រៀនផ្តល់ការបង្រៀនឱ្យចប់កម្មវិធីសិក្សា និងស្របតាមតម្រូវការរបស់សិស្ស។
- ការជំរុញគ្រូបង្រៀនឱ្យលើកទឹកចិត្តសិស្សក្នុងការស្វ័យសិក្សាជាប្រចាំ។
- ការបង្កបរិយាកាសរៀនសូត្រល្អប្រសើរ ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់។

**ខ.ការស្រាវជ្រាវ**

- ការរៀបចំក្រុមបច្ចេកទេស និងប្រជុំបច្ចេកទេសឱ្យបានទៀងទាត់។

- ការចូលរួម និងជំរុញការសិក្សាស្រាវជ្រាវមេរៀន។
- ការស្រាវជ្រាវ និងរិះរកវិធីសាស្ត្រល្អៗ ដើម្បីឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាព។

**គ.ការសហការ និងទំនាក់ទំនង**

- ការរៀបចំប្រជុំបុគ្គលិក និងសហគមន៍ក្នុងការពិនិត្យ កែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា។
- ការផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជាផ្លូវការដល់ភាគីពាក់ព័ន្ធ។
- ការរក្សាបាននូវវប្បធម៌សាមគ្គីភាព សន្តិភាព និងការគោរពគ្នាទៅវិញទៅមក តាមឋានានុក្រម។

**ឃ.ការអភិវឌ្ឍសមត្ថភាព**

- ការអភិវឌ្ឍ និងប្រើប្រាស់ធនធានសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។
- ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលបំពេញការងារបានល្អ។
- ការផ្តល់ឱកាសឱ្យគ្រូបង្រៀនបានទស្សនកិច្ចសិក្សានៅសាលាដែលល្អ។
- ការសម្របសម្រួល និងជំរុញសកម្មភាពចែករំលែកចំណេះដឹង និងបទពិសោធទៅវិញទៅមក (បង្កើតកម្មវិធីអ្នកមានបទពិសោធច្រើន ឱ្យជួយអ្នកមានបទពិសោធតិច)។

**ង.ការធ្វើអធិការកិច្ចផ្ទៃក្នុង**

- ការពិនិត្យតាមដាន និងវាយតម្លៃសកម្មភាព ដើម្បីកែលម្អលទ្ធផលសិក្សា។
- ការវាយតម្លៃលទ្ធផលសិក្សា និងសរសេររបាយការណ៍អំពីវឌ្ឍនភាពនៃការបង្រៀន និងរៀន។
- ការវាយតម្លៃចំណុចខ្លាំង និងចំណុចខ្វះខាត ដើម្បីកែលម្អលើវិធីសាស្ត្របង្រៀន។
- ការបង្កើតបរិស្ថានសិក្សាល្អ មានអនាម័យ សណ្តាប់ធ្នាប់ របៀបរៀបរយ និងគ្មានគ្រោះថ្នាក់។
- ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ប្រកបដោយតម្លាភាព យុត្តិធម៌ឱ្យបានទៀងទាត់។
- ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃជាប្រយោជន៍ដល់ការកែលម្អដំណើរការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព។

## ២.៥.ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

យោងទៅតាមសៀវភៅស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការនៃក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពនៅឆ្នាំ២០១៦ បានកំណត់នូវបញ្ញត្តិធំៗ

ចំនួនបី នៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺ៖ (១) ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀនត្រូវយល់ដឹងនិងធ្វើ (២)ជាការបញ្ជាក់ប្រាប់ពីអំពើឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបាន ហើយមានឥទ្ធិពលទៅលើសិស្ស និង(៣)ជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀន។

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមិនមានបំណងវាយតម្លៃសមត្ថភាពគ្រូបង្រៀន ដើម្បីចាត់ជាប្រភេទគ្រូល្អ ឬគ្រូខ្សោយនោះទេ តែមានបំណងលើកស្ទួយការបង្រៀននិងរៀនរបស់គ្រូបង្រៀនសម្រាប់ជួយសម្រួលការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលសិក្សា ដែលមានកម្រិតសមស្របអាចទទួលយកបាន បើប្រៀបធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សាចំណេះទូទៅ ។ ស្តង់ដានេះជាឧបករណ៍ និងខ្នាតគំរូសម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូ និងសម្រាប់ធ្វើផែនការកសាងសមត្ថភាពគ្រូបង្រៀន។ ទៅអនាគតនឹងប្រើប្រាស់ស្តង់ដាសម្រាប់ចេញជាអាជ្ញាប័ណ្ណបង្រៀន និងជាលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ប្រាក់បៀវត្សដូចនៅប្រទេសអភិវឌ្ឍមួយចំនួន។

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនពីប្រទេសមួយទៅប្រទេសមួយ ផ្អែកលើកត្តាច្រើន ដូចជា កត្តាបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដោយឡែក ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាយើងបានកំណត់ជាបួនសមាសភាគគឺ៖ (១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ (៣)ការសិក្សាវិជ្ជាជីវៈ និង (៤)សីលធម៌វិជ្ជាជីវៈ។

ដើម្បីអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនត្រូវមានសមត្ថភាពស្របតាមស្តង់ដារបស់ខ្លួនដូចខាងក្រោម៖

**ក. ចំណេះដឹងវិជ្ជាជីវៈ**

**ក.១. ចំណេះដឹងអំពីសិស្ស៖**

- ស្គាល់សិស្ស (តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស)
    - ពណ៌នាបានពីតម្រូវការសិក្សារបស់សិស្ស
    - ពណ៌នាបានពីសមត្ថភាពសិក្សារបស់សិស្ស
    - ពណ៌នាបានពីប្រវត្តិសិក្សារបស់សិស្ស
    - ពណ៌នាបានពីឥរិយាបថសិក្សារបស់សិស្ស។
- ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ (ឧ.យេនឌ័រ សាវតារសង្គម សេដ្ឋកិច្ច ពិការភាព និងក្រុមជនជាតិភាគតិច...) ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងដឹងពីរបៀបដោះស្រាយកត្តាទាំងនោះ
    - ពណ៌នាបានពីយេនឌ័រ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស

- ពណ៌នាបានពីកត្តាសង្គម សេដ្ឋកិច្ច ដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីក្រុមជនជាតិ និងពិការភាពដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស
- ពណ៌នាបានពីរបៀបដោះស្រាយកត្តាទាំងនោះ។

**ក.២. ចំណេះដឹងអំពីខ្លឹមសារមេរៀនៈ**

- យល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ
  - ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ
  - ពណ៌នាបានពីវិធីដែលធ្វើឱ្យបានសម្រេចគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ។
- យល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន
  - ពណ៌នាបានពីវត្ថុបំណង និងធាតុរបស់វាបានត្រឹមត្រូវ
  - ពណ៌នាបានពីចំណុចសំខាន់ៗនៃគោលវិធីសិស្សមជ្ឈមណ្ឌល
  - ពណ៌នាបានពីយុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានសមស្រប
  - ពណ៌នាបានពីសម្ភារបង្រៀននិងរៀនបានសមស្រប សម្រាប់ប្រើប្រាស់ក្នុងការបង្រៀនមេរៀន។
- យល់ដឹងពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់ និងបង្រៀនខ្លឹមសារមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សាបានល្អ
  - គូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗ នៃកម្មវិធីសិក្សាដែលត្រូវបង្រៀនបានច្បាស់លាស់
  - បង្រៀនដើម្បីបង្ហាញពីការយល់ខ្លឹមសារច្បាស់លាស់។
- យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន
  - ពណ៌នាបានពីវិធីបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅក្នុងមុខវិជ្ជាផ្សេងទៀត ដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន។

**ក.៣. ចំណេះដឹងពីរបៀបរៀនរបស់សិស្សៈ**

- យល់ដឹងពីបរិស្ថានសិក្សាក្នុងថ្នាក់រៀន និងសហគមន៍
  - ពណ៌នាបានពីវិធីដែលធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សាក្នុងថ្នាក់រៀន ដើម្បី

ជួយឱ្យសិស្សរៀនកាន់តែពូកែ
    - ពណ៌នាបានពីវិធីដែលធ្វើឱ្យសហគមន៍ សាលារៀន ចូលរួមជួយសិស្សឱ្យរៀនកាន់តែពូកែ។
- យល់ដឹងពីរបៀបរៀនរបស់សិស្ស
    - ពណ៌នាបានពីទ្រឹស្តីមួយ ឬច្រើននៃរបៀបរៀនរបស់សិស្ស
    - ប្រាប់បានពីរបៀបរៀនផ្សេងៗគ្នារបស់សិស្ស ។
- យល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្ស
    - ពន្យល់ពីភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស
    - ពន្យល់ពីភាពខុសគ្នានៃល្បឿនសិក្សារបស់សិស្ស
    - ពន្យល់ពីភាពខុសគ្នានៃរបៀបសិក្សារបស់សិស្ស។

**ខ.ការប្រតិបត្តិវិជ្ជាជីវៈ**

**ខ.១.ការធ្វើផែនការ និងការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា៖**

- រៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព
    - កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីវត្ថុបំណងមេរៀនច្បាស់លាស់
    - កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីរបៀបវាយតម្លៃលទ្ធផលសិក្សាបានច្បាស់លាស់
    - កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីសកម្មភាពគ្រូសិស្ស និងខ្លឹមសារមេរៀន ដើម្បីគាំទ្រវត្ថុបំណងមេរៀនបានច្បាស់លាស់ និងត្រឹមត្រូវតាមគោលការណ៍។
- រៀបចំសម្ភារបង្រៀន និងរៀន ដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ
    - រៀបចំសម្ភាររៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អរបស់សិស្ស
    - រៀបចំសម្ភារបង្រៀនប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចបានលទ្ធផលសិក្សាល្អរបស់សិស្ស។
- ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស
    - កសាងសំណួរតែស ដោយមានទម្រង់ និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ
    - ជ្រើសរើសអាយតឹមតែស(Item Test)ពីសៀវភៅផ្សេងៗដែលមានទម្រង់សំណួរ

និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ
  - បង្ហាញប្រាប់ពីអត្រាកំណែតែស និងការកែចម្លើយរបស់សិស្សបានត្រឹមត្រូវ
  - កំណត់បានយ៉ាងច្បាស់ពីលទ្ធផលតែសដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស។
- តាមដានការចូលរួម និងថែរក្សាកំណត់ត្រានៃភាពរីកចម្រើនរបស់សិស្ស
  - តាមដានការចូលរួមរបស់សិស្ស តាមរយៈការសង្កេត និងធ្វើកំណត់ត្រា
  - ថែរក្សាកំណត់ត្រា ស្តីពីការចូលរួមរបស់សិស្សក្នុងសកម្មភាពសិក្សា។
- ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស
  - ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស តាមរយៈការនិយាយដោយផ្ទាល់ និងដាក់មូលវិចារណ៍ សមស្របជាលាយលក្ខណ៍អក្សរ នៅលើសន្លឹកកិច្ចការរបស់សិស្សពិសេសលើសៀវភៅទំនាក់ទំនង
  - ផ្តល់ព័ត៌មានត្រឡប់ទៅមាតាបិតាឬអាណាព្យាបាលសិស្សតាមរយៈរបាយការណ៍ប្រចាំខែ និងទៅជួបផ្ទាល់បើចាំបាច់។

**ខ.២.ការគ្រប់គ្រងបរិស្ថានសិក្សា៖**

- ផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព
  - បង្ហាញឱ្យឃើញពីការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព
  - ជួយសិស្សឱ្យមានអន្តរកម្មវិជ្ជមានជាមួយសិស្សដទៃទៀត
  - ផ្តល់បរិស្ថានសិក្សាដែលធ្វើឱ្យសិស្សពង្រីកការសិក្សាបានច្រើន។
- ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន
  - បង្ហាញពីវិធីដែលអាចជួយសិស្សឱ្យមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនកាន់តែខ្លាំង
  - បង្ហាញកិច្ចការសិស្សជាឧទាហរណ៍ ដែលចង្អុលបង្ហាញការរៀនដោយខ្លួនឯង ( កិច្ចការសិស្ស គម្រោងតូចៗ របាយការណ៍ក្រុម ។ល។
- ចូលរួមអភិវឌ្ឍសាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្សព្រមទាំងសហសេវិក/មិត្តរួមអាជីព
  - ពណ៌នាបានពីសកម្មភាពអភិវឌ្ឍន៍សាលារៀនដែលគាត់បានចូលរួម
  - លើកជាសំណូមពរពីសកម្មភាពអភិវឌ្ឍន៍សាលារៀន។

**ខ.៣.វិធីបង្រៀន៖**

- ប្រើវិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបាន តាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង
    - បង្ហាញពីវិធីបង្រៀនផ្សេងៗ ដូចជាអនុមានរួម អនុមានញែក ការងារក្រុម ពន្យល់បង្ហាញពីដំណោះស្រាយបញ្ហា។ល។
    - ពណ៌នាបានពីវិធីបង្រៀនដែលមានប្រសិទ្ធភាពចំពោះមេរៀននីមួយៗ ដែលបានប្រើ ពិសេសអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវ
    - ពន្យល់បានពីមូលហេតុដែលប្រើវិធីបង្រៀនទាំងនោះ។
- ផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងត្រូវការផ្សេងៗគ្នារបស់សិស្ស តាមរយៈការអនុវត្ត វិធីបង្រៀនសមស្រប និងសម្បូរបែប
    - បង្ហាញពីវិធីបង្រៀនផ្សេងៗដែលផ្តល់ជាមធ្យោបាយឱ្យត្រូវទៅតាមរបៀបសិក្សារបស់សិស្សផ្សេងៗគ្នា (ឧ.ពូកែខាងភាសា គណិត ចក្ខុ ចលនារាងកាយ តន្ត្រី ទាក់ទងរវាងបុគ្គល និងបុគ្គល។ល។ ពន្យល់បានពីវិធីបង្រៀនដែលផ្តល់ជាមធ្យោបាយ ឱ្យត្រូវទៅតាមរបៀបសិក្សាខុសៗគ្នារបស់សិស្ស។
- រៀបចំ និងផ្តល់ឱ្យសិស្ស នូវឱកាសសិក្សាពីដំណោះស្រាយបញ្ហាដើម្បីចូលរួមគិត ឱ្យបានល្អិតល្អន់ និងដោយច្នៃប្រឌិត
    - ជួយសិស្សឱ្យប្រើការគិតល្អិតល្អន់ ដើម្បីវិភាគចំណោទបញ្ហា
    - ពណ៌នាបានពីរបៀប ដែលគាត់ប្រើការគិតដោយច្នៃប្រឌិត ដើម្បីដោះស្រាយ បញ្ហា។
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព
    - ពណ៌នាបានពីរបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីជួយឱ្យសិស្សមានចិត្តចង់រៀន
    - ពណ៌នាបានពីរបៀបដែលគាត់ប្រើប្រាស់ចំណេះដឹង និងបំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីឱ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព។

**គ.ការសិក្សាវិជ្ជាជីវៈ**

**គ.១.ស្វ័យសិក្សា៖**

- វាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួន និងការប្រើប្រាស់ផែនការ សម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់

- កំណត់បានពីចំណុចខ្លាំង ចំណុចដែលត្រូវកែលម្អ និងតម្រូវការក្នុងមុខវិជ្ជាជីវៈផ្ទាល់ខ្លួន
  - រៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព
  - ស្វែងយល់ពីការប្រើប្រាស់សៀវភៅកំណត់ត្រាប្រចាំថ្ងៃ ដើម្បីឆ្លុះបញ្ចាំងការងាររបស់ខ្លួន។
- អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិន សម្រាប់អនុវត្តក្នុងការបង្រៀន និងរៀន
  - បង្កើនបំណិនដែលទាក់ទងនឹងវិជ្ជាជីវៈរបស់ខ្លួន ដោយបង្ហាញវិញ្ញាបនបត្រ ជាភស្តុតាង
  - ពណ៌នាបានពីរបៀបប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ សម្រាប់ការស្រាវជ្រាវ និងរៀនដោយខ្លួនឯង
  - មានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវបំពេញបន្ថែមទាំងចំណេះដឹងមូលដ្ឋាន ទាំងបច្ចេក-ទេសបង្រៀនថ្មីៗ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

**គ.២.ការចូលរួមកែលម្អការបង្រៀនៈ**

- ធ្វើឱ្យប្រសើរឡើង នូវបំណិនទំនាក់ទំនង ជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍
  - បង្ហាញពីបំណិនទំនាក់ទំនងជាមួយសិស្ស
  - បង្ហាញពីបំណិនទំនាក់ទំនងជាមួយសហការី
  - បង្ហាញពីបំណិនទំនាក់ទំនងជាមួយមាតាបិតា និងសហគមន៍។
- អានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង
  - ពណ៌នាបានពីអត្ថបទដែលគាត់បានអាន និងស្រាវជ្រាវ ហើយយកបទពិសោធក្នុងអត្ថបទនោះមក ជួយកែលម្អការបង្រៀន
  - ធ្វើថ្នាក់និទស្សន៍ដើម្បីបង្ហាញបទពិសោធដែលទទួលបានពីការអាន និងការស្រាវជ្រាវ ឯកសារផ្សេងៗ ដល់មិត្តរួមអាជីព ដើម្បីបង្កើនសមត្ថភាព។
- ធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ
  - ធ្វើបញ្ជីឈ្មោះសិក្ខាសាលា ឬវគ្គបំប៉នផ្សេងៗ ដែលបានចូលរួម
  - ពន្យល់បានពីខ្លឹមសារសិក្ខាសាលា ឬវគ្គបំប៉នដែលបានចូលរួម ហើយបានផ្តល់បទពិសោធល្អៗ ដល់ការបង្រៀន និងរៀន។

**ឃ.សីលធម៌វិជ្ជាជីវៈ**

- បង្ហាញពីការយកចិត្តទុកដាក់ និងថែរក្សាសិស្ស ហើយជានិច្ចកាលធ្វើការ ដើម្បីជាប្រយោជន៍សិស្ស និងសង្គម
  - និយាយទៅកាន់សិស្ស សហការី និងអ្នកឯទៀតនៅក្នុងសហគមន៍ដោយ មានការគោរព និងលើកទឹកចិត្ត
  - បង្ហាញពីការគោរពសិទ្ធិកុមារ មិនត្រូវនិយាយមើលងាយ ឬដាក់ពិន័យសិស្សតាមរបៀបអំពើហិង្សា
  - ធ្វើការជាមួយសហការី និងសមាជិកសហគមន៍ឯទៀតដើម្បីប្រយោជន៍សិស្ស។
- បង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់
  - ទៅថ្នាក់រៀន និងចូលរួមព្រឹត្តិការណ៍ផ្សេងៗបានទៀងទាត់ និងទាន់ពេលវេលា
  - បង្ហាញពីអាកប្បកិរិយារាក់ទាក់ និងសប្បុរសធម៌
  - បង្ហាញពីការគោរពសិស្ស សហការី និងអ្នកឯទៀតក្នុងសហគមន៍
  - បង្ហាញពីអារម្មណ៍ជក់ចិត្ត និងគំនិតផ្តួចផ្តើមលើគ្រប់ទិដ្ឋភាពសកម្មភាពវិជ្ជាជីវៈ
  - បង្ហាញពីចំណេះដឹងលើក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងលើច្បាប់ស្តីពីការអប់រំ។
- បង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខដុមជាមួយសិស្ស និងសហគមន៍
  - ស្លៀកពាក់សមរម្យ
  - បង្ហាញពីអារម្មណ៍វិជ្ជមានចំពោះសិស្ស និងអ្នកឯទៀត
  - បង្ហាញពីសមត្ថភាព ដើម្បីរក្សាទំនាក់ទំនងប្រកបដោយសុខដុម
  - ផ្តល់តម្លៃសីលធម៌ទៅមាតាបិតាសិស្ស និងអ្នកឯទៀត។

## ២.៦.បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សាកន្លងមក

តាមរយៈការសិក្សាស្រាវជ្រាវរបស់ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ករណីសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាគីមីវិទ្យា បោះពុម្ពឆ្នាំ១៩៩៦-២០០៤ មានកត្តាមួយដែលជះឥទ្ធិពលដល់ការអនុវត្តកម្មវិធីសិក្សាគឺដោយសៀវភៅទាំងនោះមានបញ្ហាដូចជា៖ (១)មានកំហុសច្រើនទាំងអក្ខរាវិរុទ្ធនិងរូបមន្ត (២)មេរៀនទាំងនោះគឺពិបាកពេកទាំងគ្រូនិងសិស្ស (៣)ចំនួនម៉ោងនិងចំនួនខ្លឹមសារមិនស៊ីគ្នា (៤)ការពន្យល់ទៅលើខ្លឹមសារមេរៀនមិនមានភាពច្បាស់លាស់ និងពិបាកយល់ (៥)ខ្លឹមសារមួយចំនួនមិនទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃនិងធ្វើឱ្យសិស្សគ្មានចិត្ត

ចង់រៀន (៦)មេរៀនលំបាកៗជាច្រើន ដែលមិនសមដាក់នៅកម្រិតនេះ ត្រូវបានគេដាក់បញ្ចូល (៧)មេរៀនសំខាន់ៗដែលចាំបាច់ និងជាមូលដ្ឋានគ្រឹះមួយចំនួនមិនត្រូវបានដាក់បញ្ចូល (៨) ចំណងជើងមេរៀនរៀបគ្មានលំដាប់លំដោយ (៩)មេរៀនមួយចំនួនមិនមានសារសំខាន់សម្រាប់បង្រៀនសិស្សឱ្យយល់ពីគីមីវិទ្យា (១០)លំហាត់មួយចំនួនមិនផ្សារភ្ជាប់ជាមួយនឹងខ្លឹមសារមេរៀន ១១)រូបភាពសម្រាប់សង្កេតមិនមានភាពច្បាស់លាស់ (១២)លំហាត់មួយចំនួនគ្មានចម្លើយនៅក្នុងសៀវភៅគ្រូ (១៣) ខ្លឹមសារពិសោធន៍មួយចំនួនមិនបានគិតពីសម្ភារដែលសាលាកំពុងជួបប្រទះ ចំណែកឯលំនាំពិសោធគឺតាមបែបឧស្សាហកម្ម និង(១៤)ពិសោធន៍មិនត្រូវបានបង្រៀនតាមវិធីវិទ្យាសាស្ត្រ។

តាមរបាយការណ៍ពាក់កណ្តាលអាណត្តិ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ ទំព័រទី៦៦ ចំណុចទី៣ ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការអប់រំបច្ចេកទេស និងកែលម្អកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅបានលើកឡើងពីបញ្ហា ជាច្រើនដែលបានជួបប្រទះពេលអនុវត្តកម្មវិធីសិក្សានៅកម្រិតសាលារៀន ដោយលោកគ្រូ អ្នកគ្រូមិនអាចអនុវត្តកម្មវិធីសិក្សាបានពេញលេញ បណ្តាលមកពីកត្តាមួយចំនួនដូចជាកត្តាគ្រោះធម្មជាតិ និងហានីភ័យផ្សេងៗ ការឈប់សម្រាកក្រៅផ្លូវការ និងការបំពេញភារកិច្ចរបស់គ្រូនៅមានកម្រិត ការប្រើវិធីសាស្ត្របែបទន្ទេញចាំមាត់នៅតែកើតមាន កង្វះខាតអ្នកសម្របសម្រួលកម្មវិធីសិក្សាកម្រិតថ្នាក់ស្រុកនៅតែជាបញ្ហាចោទនៅឡើយ ការយល់ដឹងទាក់ទងទៅនឹងគោលនយោបាយកម្មវិធីសិក្សានៅមានកម្រិតទាបក្នុងចំណោមគ្រូបង្រៀនទាំងអស់ និងការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សានៅមានកម្រិតនៅឡើយ ។

បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា ដែលបានរកឃើញតាមរយៈនិក្ខេបបទក្នុងករណីសិក្សានៅវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញរបស់អ្នកស្រាវជ្រាវ លឹម កិត្យា បោះពុម្ពឆ្នាំ ២០១៨ ទំព័រទី៤៤ និង៤៥ បានលើកឡើងថា បញ្ហាចម្បងធំៗដែលលោកគ្រូ អ្នកគ្រូជួបប្រទះក្នុងពេលអនុវត្តកម្មវិធីសិក្សាគឺ(១)សមត្ថភាពសិស្សមិនសមស្របទៅនឹងកម្រិតថ្នាក់ដែលកំពុងរៀន (សិស្សភាគច្រើនខ្សោយគ្មានមូលដ្ឋានគ្រឹះពីខាងក្រោម) (២)សិស្សមិនយកចិត្តទុកដាក់និងឱ្យតម្លៃលើការសិក្សា (៣)ខ្វះខាតសៀវភៅសិក្សាគោលច្រើនលើមុខវិជ្ជាមួយចំនួន (៤)ចំនួនមេរៀននិងម៉ោងបង្រៀនក្នុង១សប្តាហ៍មិនសមស្រប (៥)សៀវភៅសិក្សាគោលមានការខ្វះចន្លោះច្រើនចំពោះមុខវិជ្ជាមួយចំនួនដូចជា មានកំហុសអក្ខរាវិរុទ្ធ មានកំហុសឆ្លងលើលំហាត់ និងកំណែលំហាត់ ខ្លឹមសារមេរៀនមិនស៊ីជម្រៅទៅនឹងចំណងជើង ខ្លឹមសារមេរៀនច្រំដែល ខ្លឹមសារមេរៀនខ្លះទាបជាងសមត្ថភាពសិស្ស និងខ្លះទៀតខ្ពស់ជាងសមត្ថភាពសិស្សពេក ការពន្យល់ទៅលើខ្លឹមសារមេរៀនមិនមានភាពច្បាស់លាស់និងពិបាកយល់ ខ្លឹមសារមួយចំនួនមិន

ទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃនិងធ្វើឱ្យសិស្សគ្មានចិត្តចង់រៀន លំដាប់លំដោយមេរៀនមិនត្រឹមត្រូវ (៦)ខ្វះខាតឯកសារយោងដូចជាមេរៀនភាសាខ្មែរ។ល។ (៧)ខ្វះខាតសម្ភារឧបទេសដោយសម្ភារមានសម្រាប់តែតាំងលម្អ ហើយបែបបទនៃការយកសម្ភារមកប្រើប្រាស់នៅក្នុងថ្នាក់រៀនមានការលំបាក (៨)មិនមានការគាំទ្របច្ចេកទេសពីប្រធានក្រុមបច្ចេកទេសគ្រប់គ្រាន់តាមតម្រូវការនោះទេ (៩)គ្មានការចែករំលែកចំណេះដឹងរវាងគ្រូនិងគ្រូដែលជាសមាជិកក្រុមបច្ចេកទេសដូចគ្នា (១០)គោលវិធីសិស្សមជ្ឈមណ្ឌលដែលបានណែនាំក្នុងកម្មវិធីសិក្សាមិនអាចអនុវត្តបានទាំងស្រុងទេ ព្រោះទំហំថ្នាក់រៀនធំពេកសិស្សលើសពី៥០នាក់ នាំឱ្យពិបាកគ្រប់គ្រងសិស្ស បរិស្ថានថ្នាក់រៀនមិនអំណោយផលឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន និងមិនមានមន្ទីរពិសោធន៍និងបន្ទប់ ITC ជាដើម។

ដោយឡែក តាមរយៈការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ សៀវភៅផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ ទំព័រទី១៨ ត្រង់បញ្ហាប្រឈមបានលើកឡើងថា គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្រ្ត បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទ្ទេស រោងជាង ស្របតាមកម្មវិធីសិក្សានៅឡើយទេ។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.ការរៀបចំស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របែបចម្រុះមានទាំងបែបបរិមាណវិស័យនិងបែបគុណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រងសំណួរដែលមានសំណួរបែបទម្រង់បិទ និងទម្រង់បើកដើម្បីប្រមូលទិន្នន័យពីគណៈគ្រប់គ្រង និងគ្រូបង្រៀនគ្រប់មុខវិជ្ជាដែលបង្រៀននៅផ្នែកទុតិយភូមិ នៅតាមវិទ្យាល័យចំនួន៣ ក្នុងខេត្តតាកែវ។ កម្រងសំណួរដែលត្រូវយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ ចែកចេញជាពីរប្រភេទគឺប្រភេទទី១សម្រាប់បំពេញដោយគណៈគ្រប់គ្រង (នាយកនិងនាយករង) និងប្រភេទទី២សម្រាប់បំពេញដោយគ្រូបង្រៀន។

## ៣.២.វិធីសាស្ត្រប្រមូលទិន្នន័យ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមដែលចេញដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទៅសុំការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ដើម្បីចុះប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅ។ បន្ទាប់មកទៀតអ្នកស្រាវជ្រាវបានទាក់ទងទៅនាយកសាលានីមួយៗ ដោយជូនដំណឹងដល់ពួកគាត់មុន៣ថ្ងៃដើម្បីផ្តល់ព័ត៌មានដល់គ្រូបង្រៀនពាក់ព័ន្ធ និងសុំណាត់ជួបពួកគាត់នៅពេលវេលាណាមួយទុកជាមុន។ ពេលទៅដល់សាលារៀន អ្នកស្រាវជ្រាវបានបង្ហាញលិខិតឧទ្ទេសនាមបេសកកម្មចុះប្រមូលទិន្នន័យនោះទៅនាយកសាលា និងសុំការអនុញ្ញាតពីគាត់ដើម្បីធ្វើការប្រមូលទិន្នន័យដោយអញ្ជើញគ្រូបង្រៀនដែលពាក់ព័ន្ធ ប្រជុំធ្វើការណែនាំក្នុងការបំពេញកម្រងសំណួរ និងធ្វើការបំពេញកម្រងសំណួរនោះ ដោយគោរពតាមក្រមសីលធម៌អ្នកស្រាវជ្រាវតាមការស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំឡើយ។ ក្នុងការបំពេញកម្រងសំណួរនេះ ប្រើប្រាស់ពេលវេលាប្រហែល ៣០នាទី។ ចំណែកគ្រូបង្រៀនមួយចំនួនធំ ក្រោយពេលទទួលបានការណែនាំក្នុងការបំពេញរួចហើយ ក៏សុំយកទៅបំពេញនៅផ្ទះ ព្រោះពួកគាត់ត្រូវចូលបង្រៀនវិញដោយមិនចង់ប៉ះពាល់ដល់ម៉ោងបង្រៀនរបស់ពួកគាត់។ ក្នុងករណីគ្រូបង្រៀនយកទៅបំពេញនៅផ្ទះ អ្នកស្រាវជ្រាវបានស្នើសុំទុកពេលឱ្យពួកគាត់១សប្តាហ៍ និងបានកំណត់កាលបរិច្ឆេទច្បាស់លាស់ដើម្បីសុំប្រមូលកម្រងសំណួរវិញ ហើយចំពោះលោកគ្រូអ្នកគ្រូដែលមិនបានផ្តល់កម្រងសំណួរមកវិញតាមពេលវេលាកំណត់ អ្នកស្រាវជ្រាវបានសុំការយោគយល់ពីនាយកសាលាក្នុងការជួយ

សម្របសម្រួលប្រមូលទុករហូតគ្រប់ចំនួន ទើបគាត់ផ្តល់ដំណឹងមកអ្នកស្រាវជ្រាវទៅយកជាលើកចុងក្រោយ។ ការចុះទៅប្រមូលទិន្នន័យទាំង៣វិទ្យាល័យនេះ ធ្វើតាមលំនាំដូចៗគ្នា និងប្រើពេលវេលាសរុបចំនួន២០ថ្ងៃ ដោយគិតចាប់ពីថ្ងៃណែនាំក្នុងការបំពេញនិងចែកកម្រងសំណួរដំបូងរហូតដល់ថ្ងៃប្រមូលចុងក្រោយ ។

## ៣.៣.ការជ្រើសរើសសំណាក

អ្នកស្រាវជ្រាវជ្រើសរើសយកសំណាកចំនួន៣វិទ្យាល័យ ដើម្បីចុះទៅប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវ ដោយផ្អែកទៅតាមប្រភេទសាលាចំនួន២ប្រភេទ គឺសាលានៅទីប្រជុំជនចំនួន១សាលា និងប្រភេទសាលានៅទីជនបទចំនួន២សាលា សរុប៣សាលា។

ចំពោះសាលាទីប្រជុំជន អ្នកស្រាវជ្រាវកំណត់យកវិទ្យាល័យហេងសំរិនព្រៃល្វា ស្ថិតក្នុងស្រុកព្រៃកប្បាស ដោយសារទីតាំងសាលារៀននេះស្ថិតក្នុងទីរួមស្រុក និងនៅតំបន់ផ្សារ (ផ្សារព្រៃល្វា) មានមនុស្សរស់នៅច្រើន។ ចំណែកសាលារៀននៅទីជនបទអ្នកស្រាវជ្រាវបានជ្រើសរើសយកវិទ្យាល័យចំនួន២ គឺវិទ្យាល័យអង្គអណ្តែត ដែលមានទីតាំងស្ថិតនៅក្នុងឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស និងវិទ្យាល័យហ៊ុនសែន១មិថុនា ស្ថិតនៅក្នុងឃុំពារាម ស្រុកបាទី ព្រោះសាលារៀនទាំង២នេះស្ថិតនៅទីជនបទ ដាច់ឆ្ងាយពីទីរួមស្រុក ប្រជាពលរដ្ឋនៅតំបន់នោះប្រកបរបរកសិកម្ម ធ្វើស្រែចម្ការ។

អ្នកស្រាវជ្រាវកំណត់យកគណៈគ្រប់គ្រងចំនួន ៩នាក់ ដោយជ្រើសយកនាយកចំនួន១នាក់ និងនាយករងចំនួន ២នាក់ សរុប៣នាក់ ក្នុង១វិទ្យាល័យ ព្រោះនាយក និងនាយករងជាអ្នកដែលអនុវត្តផ្ទាល់ជាងគេក្នុងចំណោមសមាសភាពគណៈគ្រប់គ្រងទាំងអស់។ ដោយឡែកវិទ្យាល័យអង្គអណ្តែត មាននាយករង២នាក់ តែក្នុងនោះនាយករងម្នាក់គឺជាអ្នកស្រាវជ្រាវផ្ទាល់ ដូចនេះ អ្នកស្រាវជ្រាវសម្រេចជ្រើសយកប្រធានក្រុមបច្ចេកទេសម្នាក់ជំនួសវិញ ដើម្បីប្រមូលទិន្នន័យ ដោយប្រើកម្រងសំណួរសម្រាប់នាយក នាយករង។ ចំណែកគ្រូបង្រៀនគ្រប់មុខវិជ្ជាចាប់ពីថ្នាក់ទី១០ដល់ទី១២ អ្នកស្រាវជ្រាវកំណត់យកសរុបចំនួន ៩០នាក់ ពីវិទ្យាល័យទាំង៣ខាងលើ។

*តារាង ៣.១ ៖ ចំនួនសំណាក*

| ល.រ | ឈ្មោះវិទ្យាល័យ | គណៈគ្រប់គ្រង | | គ្រូបង្រៀន | |
|---|---|---|---|---|---|
| | | ចំនួនសរុប | ចំនួនសំណាក | ចំនួនសរុប | ចំនួនសំណាក |
| ១ | វិទ្យាល័យហេងសំរិនព្រៃល្វា | ១៥ | ៣ | ៣៦ | ១៧ |
| ២ | វិទ្យាល័យអង្គអណ្ដែត | ១៥ | ៣ | ១៥ | ៧ |
| ៣ | វិទ្យាល័យហ៊ុនសែន១មិថុនា | ១៥ | ៣ | ៣៥ | ១៦ |
| សរុប | | ៤៥ | ៩ | ៨៦ | ៤០ |

## ៣.៤.ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរចំនួន២ប្រភេទក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យនិងគុណវិស័យ។ កម្រងសំណួរទាំង២ប្រភេទនោះរួមមានប្រភេទទី១គឺកម្រងសំណួរសម្រាប់នាយកនិងនាយករង និងទី២គឺកម្រងសំណួរសម្រាប់គ្រូបង្រៀនដែលកំពុងបង្រៀនថ្នាក់ទី១០ដល់ថ្នាក់ទី១២។ កម្រងសំណួរទាំង២ប្រភេទនេះត្រូវបានបង្កើតឡើង ដោយផ្អែកលើទ្រឹស្ដីនានាទាក់ទងនឹងការដឹកនាំការអនុវត្ត និងការអនុវត្តកម្មវិធីសិក្សា មានដូចជា ស្ដង់ដានាយកសាលារៀន សៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ សៀវភៅស្ដង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសំណួរមួយចំនួនទៀត ដកស្រង់ចេញពីឧបករណ៍វាយតម្លៃនាយកសាលាល្អ ឧបករណ៍វាយតម្លៃគ្រូបង្រៀនល្អដែលទាក់ទងនឹងការដឹកនាំការអនុវត្ត និងការអនុវត្តកម្មវិធីសិក្សា។

## ៣.៥.កម្រងសំណួរ និងគោលបំណង

### ក.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង ចែកចេញជា៣ផ្នែកគឺ៖

ផ្នែកទី១៖ មាន៧សំណួរជាព័ត៌មានទូទៅរបស់អ្នកផ្ដល់ចម្លើយរួមមាន ឈ្មោះវិទ្យាល័យកំពុងបម្រើការ ភេទ អាយុ កម្រិតវប្បធម៌ មុខវិជ្ជាឯកទេស មុខវិជ្ជាធ្លាប់បង្រៀន/បង្រៀនថ្នាក់ទី និងបទពិសោធន៍ជាគណៈគ្រប់គ្រង។

ផ្នែកទី២ ៖ មាន២២សំណួរ ជាសំណួរបែបបរិមាណវិស័យផ្ដោតលើការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់គណៈគ្រប់គ្រងសាលារៀន ដែលសំណួរទី១-៩ ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃការអនុវត្តលើការគ្រប់គ្រងនិងដឹកនាំការងារបង្រៀន។ សំណួរពី១០-១៣ សម្រាប់

វាស់កម្រិតនៃការអនុវត្តលើការគ្រប់គ្រងនិងដឹកនាំការរៀនសូត្រ។ ចំណែកសំណួរទី១៤-១៨ ប្រើសម្រាប់បង្ហាញពីកម្រិតនៃការអនុវត្តការពិនិត្យតាមដាននិងវាយតម្លៃ និងផ្នែកចុងក្រោយចាប់ពីសំណួរទី១៩-២២ សម្រាប់វាស់ពីកម្រិតនៃការអនុវត្តការសហការនិងទំនាក់ទំនង។

ផ្នែកទី៣ ៖ មាន២សំណួរ ជាសំណួរបែបគុណវិស័យ ដែលអ្នកស្រាវជ្រាវចង់ដឹងអំពីមតិយោបល់របស់អ្នកផ្តល់ទិន្នន័យ តាមរយៈការឆ្លើយនឹងសំណួរទី១ទាក់ទងនឹងបញ្ហាលំបាក ក្នុងការដឹកនាំការអនុវត្តកម្មវិធីសិក្សាបច្ចុប្បន្ន និងសំណួរទី២ជាការសុំជាសំណូមពរ ឬអនុ-សាសន៍របស់នាយកនិងនាយករង ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ។

### ខ.កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរសម្រាប់គ្រូបង្រៀន គឺត្រូវប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យពីគ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិដែលកំពុងបង្រៀនថ្នាក់ទី១០ដល់ថ្នាក់ទី១២ ដែលចែកចេញជា៣ផ្នែកសំខាន់ៗគឺ៖

ផ្នែកទី១ ៖មាន៧សំណួរជាព័ត៌មានទូទៅរបស់អ្នកផ្តល់ចម្លើយរួមមាន ឈ្មោះវិទ្យាល័យកំពុងបម្រើការ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍បង្រៀន មុខវិជ្ជាឯកទេស និងមុខវិជ្ជាកំពុងបង្រៀន/បង្រៀនថ្នាក់ទី ។

ផ្នែកទី២ ៖ ចែកចេញជា២៧សំណួរ ជាសំណួរបែបបរិមាណវិស័យផ្តោតលើការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ដែលសំណួរទី១-៦ សម្រាប់វាស់ពីកម្រិតនៃការអនុវត្តកម្មវិធីសិក្សា។ សំណួរពី៧-១៣ សម្រាប់វាស់កម្រិតនៃការអនុវត្តការរៀបចំការបង្រៀន ។ ចំណែកសំណួរទី១៤-១៨ សម្រាប់បង្ហាញពីកម្រិតនៃចំណេះដឹងលើជំនាញរបស់គ្រូបង្រៀន។ សំណួរទី១៩-២២ ប្រើសម្រាប់វាស់ស្ទង់កម្រិតនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀន និងចាប់ពីសំណួរទី២៣-២៧ សម្រាប់វាស់ពីកម្រិតនៃការអនុវត្តការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។

ផ្នែកទី៣ ៖ មាន២សំណួរ ជាសំណួរបែបគុណវិស័យ ដែលបង្ហាញអំពីមតិយោបល់បន្ថែមរបស់អ្នកផ្តល់ទិន្នន័យ ក្នុងនោះរួមមានសំណួរទី១ទាក់ទងនឹងបញ្ហាប្រឈម ក្នុងការអនុវត្តកម្មវិធីសិក្សានាពេលកន្លងមក និងសំណួរទី២តម្រូវឱ្យលោកគ្រូអ្នកគ្រូផ្តល់មតិយោបល់ឬសំណូមពរ ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាកាន់តែមានប្រសិទ្ធភាព។

## ៣.៦.ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យបែបបរិមាណវិស័យត្រូវធ្វើឡើង ដោយយកលទ្ធផលនៃចម្លើយរៀបទៅតាមតារាងដែលស្រង់ចេញពីកម្មវិធី SPSS ហើយធ្វើការវិភាគទៅលើតារាងនីមួយៗ ដោយ

រកតម្លៃមធ្យម (Mean) រួចពិនិត្យមើលគម្លាតស្តង់ដា (Std. Error) ដើម្បីពិនិត្យមើលថាតើតម្លៃមធ្យមដែលរកឃើញនោះ មានកម្រិតខុសគ្នាអាចទទួលយកបានឬទេ និងកំណត់កម្រិត (Level) នៃការអនុវត្តសកម្មភាព។ ម្យ៉ាងទៀត ការវិភាគទិន្នន័យបែបគុណវិស័យ អ្នកស្រាវជ្រាវវិភាគលើចម្លើយដែលបានមកពីសំណួរទម្រង់បើកចំនួន២របស់នាយក/នាយករង និងគ្រូបង្រៀន ដោយធ្វើការស្រង់ពាក្យពេចន៍ក្នុងចម្លើយដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីទាញព័ត៌មានបន្ថែមអំពីបញ្ហាលំបាកក្នុងការដឹកនាំការអនុវត្តកម្មវិធីសិក្សា និងអនុសាសន៍ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះរបស់នាយកនិងនាយករង ព្រមទាំងបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីសិក្សានិងមតិយោបល់របស់គ្រូបង្រៀន ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាកាន់តែមានប្រសិទ្ធភាព រួចទាញសេចក្តីសន្និដ្ឋាន។

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

## ៤.១.ការវិភាគទិន្នន័យលើកម្រងសំណួរទី១

### ៤.១.១.ព័តមានទូទៅរបស់អ្នកចូលរួម

តាមតារាង៤.១ មានបង្ហាញព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងដែលជាសំណាកស្រាវជ្រាវទាំងអស់ រួមមានព័ត៌មានលម្អិតពីភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ជាគណៈគ្រប់គ្រងដូចមានក្នុងតារាងខាងក្រោមៈ

*តារាង ៤.១ ៖ចំនួនគណៈគ្រប់គ្រងគិតតាមភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍*

| ល.រ | បរិយាយ | | វិទ្យាល័យ | | | សរុបរួម | |
|---|---|---|---|---|---|---|---|
| | | | វិ.ហាសរព្រៃល្វា | វិ.អង្គអណ្ដែត | វិ.ហាស១មិថុនា | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 3 | 3 | 2 | 8 | 88.9% |
| | | ស្រី | 0 | 0 | 1 | 1 | 11.1% |
| | | សរុប | 3 | 3 | 3 | 9 | 100.0% |
| ២ | អាយុ | ៣១-៤០ឆ្នាំ | 0 | 0 | 2 | 2 | 22.2% |
| | | ៤១-៥០ឆ្នាំ | 2 | 3 | 1 | 6 | 66.7% |
| | | លើស៥០ឆ្នាំ | 1 | 0 | 0 | 1 | 11.1% |
| | | សរុប | 3 | 3 | 3 | 9 | 100.0% |
| ៣ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | 2 | 3 | 1 | 6 | 66.7% |
| | | បរិ.ជាន់ខ្ពស់ | 1 | 0 | 2 | 3 | 33.3% |
| | | សរុប | 3 | 3 | 3 | 9 | 100.0% |
| ៤ | បទពិសោធន៍ជាគណៈគ្រប់គ្រង | ១-៥ឆ្នាំ | 0 | 0 | 2 | 2 | 22.2% |
| | | ៦-១០ឆ្នាំ | 1 | 1 | 0 | 2 | 22.2% |
| | | លើស១០ឆ្នាំ | 2 | 2 | 1 | 5 | 55.6% |
| | | សរុប | 3 | 3 | 3 | 9 | 100.0% |

តារាងខាងលើបង្ហាញថា គណៈគ្រប់គ្រងដែលបានបំពេញកម្រងសំណួរមានចំនួន ៩ នាក់ ក្នុងនោះស្រី ១នាក់ ស្មើនឹង ១១,១% និងប្រុស ៨នាក់ ស្មើនឹង ៨៨,៩% ។ ក្នុងចំណោម គណៈគ្រប់គ្រងទាំង៩នាក់ មានអាយុពី៣១-៤០ឆ្នាំ មានចំនួន ២នាក់ ស្មើនឹង ២២,២% អាយុពី៤១-៥០ឆ្នាំ មានចំនួន ៦ នាក់ ស្មើនឹង ៦៦,៧% និងអាយុលើសពី៥០ឆ្នាំ មានចំនួន ១ នាក់ ស្មើនឹង ១១,១%។ គណៈគ្រប់គ្រងដែលមានកម្រិតវប្បធម៌បរិញ្ញាបត្រមានចំនួន ៦ នាក់ ស្មើនឹង

៦៦,៧% និងបរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ៣នាក់ ស្មើនឹង ៣៣,៣%។ គណៈគ្រប់គ្រងដែលបានបំពេញកម្រងសំណួរទាំង៩នាក់ មានបទពិសោធន៍ជាគណៈគ្រប់គ្រងរយៈពេលពី១-៥ឆ្នាំ មានចំនួន ២នាក់ ស្មើនឹង ២២,២% រយៈពេលពី ៦-១០ឆ្នាំ មានចំនួន ២នាក់ ស្មើនឹង ២២,២% និងរយៈពេលលើសពី១០ឆ្នាំ ចំនួន ៥នាក់ ស្មើនឹង ៥៥,៦%។

### ៤.១.២.ការដឹកនាំអនុវត្តកម្មវិធីសិក្សា

តាមតារាង ៤.២ យើងសង្កេតឃើញថា អ្នកឆ្លើយសំណួរក្នុងកម្រិតនៃការអនុវត្តច្រើនមានចំនួនច្រើនជាងគេគឺ ៤៧,៩៨% បន្ទាប់មកកម្រិតនៃការអនុវត្តច្រើនបំផុតមាន ៣១,៨២% កម្រិតមធ្យមមាន ១៨,១៨% កម្រិតនៃការអនុវត្តបានតិចមាន ១,៥២% និងកម្រិតដែលបានអនុវត្តតិចជាងគេគឺកម្រិតតិចបំផុតមានត្រឹមតែ 0,៥0% ប៉ុណ្ណោះ។

*តារាង ៤.២ ៖ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត*

| ល.រ | សំណួរស្តីពីការដឹកនាំការអនុវត្តកម្មវិធីសិក្សា | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | |
|---|---|---|---|---|---|---|
| | | តិចបំផុត | តិច | មធ្យម | ច្រើន | ច្រើនបំផុត |
| ក.ការគ្រប់គ្រងនិងដឹកនាំការងារបង្រៀន | | | | | | |
| ១ | ធ្វើការបែងចែកកម្មវិធីសិក្សាសម្រាប់លោកគ្រូ/អ្នកគ្រូតាមកម្រិតថ្នាក់ | 0 | 0 | 0 | 6 | 3 |
| ២ | រៀបចំតារាងកាលវិភាគសម្រាប់លោកគ្រូ/អ្នកគ្រូតាមកម្រិតថ្នាក់ | 0 | 1 | 1 | 3 | 4 |
| ៣ | ផ្តល់សម្ភារៈនិង ធនធានសិក្សាសម្រាប់ដំណើរការបង្រៀន ដោយឈរលើស្មារតីច្នៃប្រឌិត | 0 | 0 | 4 | 1 | 4 |
| ៤ | ធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូបង្រៀនអនុវត្តផែនការនោះឱ្យបានទៀង | 0 | 0 | 3 | 4 | 2 |
| ៥ | ជំរុញគ្រូបង្រៀន បង្រៀនឱ្យទាន់កម្មវិធី | 0 | 0 | 0 | 3 | 6 |
| ៦ | មានកិច្ចប្រជុំក្រុមបច្ចេកទេសមុខវិជ្ជាបានទៀងទាត់ | 0 | 0 | 2 | 5 | 2 |
| ៧ | លើកទឹកចិត្តក្នុងការស្រាវជ្រាវ រកវិធីសាស្រ្តបង្រៀនថ្មី ដើម្បីបង្កើនប្រសិទ្ធភាព | 0 | 0 | 0 | 8 | 1 |
| ៨ | បញ្ជូនគ្រូបង្រៀន ចូលរួមក្នុងវគ្គបំប៉នបច្ចេកទេស វិធីសាស្រ្តថ្មី | 1 | 0 | 5 | 3 | 0 |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | លើកទឹកចិត្តគ្រូឱ្យបង្រៀនប្រើចិត្ត-គរុកោសល្យ ក្នុងការសម្របសម្រួលឱ្យសិស្សចូលចិត្តការ | 0 | 0 | 2 | 5 | 2 |
| ខ.ការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ | | | | | | |
| ១០ | ការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្ស គ្រប់ប្រភេទដោយមិនរើសអើង | 0 | 0 | 0 | 5 | 4 |
| ១១ | បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបានប្រកប ដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់ | 0 | 0 | 0 | 4 | 5 |
| ១២ | ជំរុញឱ្យសិស្សានុសិស្ស មានទឹកចិត្តក្នុងការ ស្វ័យសិក្សាជាប្រចាំ | 0 | 0 | 0 | 5 | 4 |
| ១៣ | បានរៀបចំបណ្ណាល័យ និងការផ្គត់ផ្គង់ សៀវភៅសិក្សាគោល | 0 | 0 | 2 | 4 | 3 |
| គ.ការពិនិត្យតាមដាន និងវាយតម្លៃ | | | | | | |
| ១៤ | ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់ កម្រិតថ្នាក់តាមមុខវិជ្ជា | 0 | 0 | 0 | 5 | 4 |
| ១៥ | ស្វែងរកកង្វះខាត លើវិធីសាស្ត្របង្រៀន ដើម្បីកែលម្អ | 0 | 0 | 2 | 5 | 2 |
| ១៦ | ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដោយតម្លាភាព | 0 | 0 | 1 | 3 | 5 |
| ១៧ | ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដំណើរ ការបង្រៀន និងរៀនឱ្យកាន់តែល្អប្រសើរ | 0 | 0 | 2 | 5 | 2 |
| ១៨ | វាយតម្លៃការបង្រៀនរបស់គ្រូតាមរយៈការ សង្កេតលើដំណើរការបង្រៀន | 0 | 0 | 3 | 4 | 2 |
| ឃ. ការសហការ និងទំនាក់ទំនង | | | | | | |
| ១៩ | បានរៀបចំប្រជុំបុគ្គលិក ដើម្បីអភិវឌ្ឍការ អនុវត្តកម្មវិធីសិក្សា | 0 | 0 | 3 | 2 | 4 |
| ២០ | បានផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃគ្រូ ជាផ្លូវការដល់ភាគីពាក់ព័ន្ធ | 0 | 0 | 4 | 4 | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| ២១ | ផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋាន ទៅនឹងតម្រូវការសហគមន៍ | 0 | 2 | 1 | 5 | 1 |
| ២២ | មានកិច្ចពិភាក្សាលើលទ្ធផលសិក្សារបស់សិស្ស ទាំងសិស្សពូកែ និងសិស្សខ្សោយ | 0 | 0 | 1 | 6 | 2 |
| | ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ | 0.50 % | 1.52 % | 18.18% | 47.98% | 31.82 % |

តារាង ៤.៣ ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពក្នុងការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលានៅវិទ្យាល័យក្នុងខេត្តតាកែវ ពីតម្លៃមធ្យម (Mean) តម្លៃគម្លាតស្តង់ដា (Std. Error) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពតាមផ្នែកទាំងបួន៖ ការគ្រប់គ្រងនិងដឹកនាំការងារបង្រៀន, ការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ, ការពិនិត្យតាមដាននិងវាយតម្លៃ និងការសហការ និងទំនាក់ទំនង។

*តារាង ៤.៣ ៖ កម្រិតនៃការអនុវត្តសកម្មភាពលម្អិតតាមផ្នែកទាំងបួន នៃការដឹកនាំកាអនុវត្តកម្មវិធីសិក្សា របស់នាយកសាលា*

| ក.ការគ្រប់គ្រងនិងដឹកនាំការងារបង្រៀន | | Mean | | Level |
|---|---|---|---|---|
| | | Statistic | Std. Error | |
| ១ | ធ្វើការបែងចែកកម្មវិធីសិក្សាសម្រាប់លោកគ្រូ/អ្នកគ្រូតាមកម្រិត | 4.33 | 0.17 | ល្អណាស់ |
| ២ | រៀបចំតារាងកាលវិភាគសម្រាប់លោកគ្រូ/អ្នកគ្រូតាមកម្រិតថ្នាក់ | 4.11 | 0.35 | ល្អ |
| ៣ | ផ្តល់សម្ភារៈនិង ធនធានសិក្សាសម្រាប់ដំណើរការបង្រៀន ដោយឈរលើស្មារតីច្នៃប្រឌិត | 4.00 | 0.33 | ល្អ |
| ៤ | ធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូបង្រៀនអនុវត្តផែនការនោះឱ្យបានទៀងទាត់ | 3.89 | 0.26 | ល្អ |
| ៥ | ជំរុញគ្រូបង្រៀន បង្រៀនឱ្យទាន់កម្មវិធីសិក្សា | 4.67 | 0.17 | ល្អណាស់ |
| ៦ | មានកិច្ចប្រជុំក្រុមបច្ចេកទេសមុខវិជ្ជាបានទៀងទាត់ | 4.00 | 0.24 | ល្អ |
| ៧ | លើកទឹកចិត្តក្នុងការស្រាវជ្រាវ រកវិធីសាស្រ្តបង្រៀនថ្មី ដើម្បីបង្កើនប្រសិទ្ធភាព | 4.11 | 0.11 | ល្អ |
| ៨ | បញ្ជូនគ្រូបង្រៀន ចូលរួមក្នុងវគ្គបំប៉នបច្ចេកទេស វិធីសាស្រ្តថ្មី | 3.11 | 0.31 | មធ្យម |

| | | Mean | | Level |
|---|---|---|---|---|
| ៩ | លើកទឹកចិត្តគ្រូឱ្យបង្រៀនប្រើចិត្ត-គរុកោសល្យ ក្នុងការសម្របសម្រួលឱ្យសិស្សចូលចិត្តការសិក្សា | 4.00 | 0.24 | ល្អ |
| | សរុប | 4.02 | 0.24 | ល្អ |
| ខ.ការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ | | Statistic | Std. Error | Level |
| ១០ | ការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនរើសអើង | 4.44 | 0.18 | ល្អណាស់ |
| ១១ | បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបានប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់ | 4.56 | 0.18 | ល្អណាស់ |
| ១២ | ជំរុញឱ្យសិស្សានុសិស្ស មានទឹកចិត្តក្នុងការស្វ័យសិក្សាជាប្រចាំ | 4.44 | 0.18 | ល្អណាស់ |
| ១៣ | បានរៀបចំបណ្ណាល័យ និងការផ្គត់ផ្គង់សៀវភៅសិក្សាគោល | 4.11 | 0.26 | ល្អ |
| | សរុប | 4.39 | 0.20 | ល្អណាស់ |
| គ.ការពិនិត្យតាមដាន និងវាយតម្លៃ | | Statistic | Std. Error | Level |
| ១៤ | ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់តាមមុខវិជ្ជា | 4.44 | 0.18 | ល្អណាស់ |
| ១៥ | ស្វែងរកកង្វះខាត លើវិធីសាស្រ្តបង្រៀនដើម្បីកែលម្អ | 4.00 | 0.24 | ល្អ |
| ១៦ | ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដោយតម្លាភាព | 4.44 | 0.24 | ល្អណាស់ |
| ១៧ | ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដំណើរការបង្រៀន និងរៀនឱ្យកាន់តែល្អប្រសើរ | 4.00 | 0.24 | ល្អ |
| ១៨ | វាយតម្លៃការបង្រៀនរបស់គ្រូតាមរយៈការសង្កេតលើដំណើរការបង្រៀន | 3.89 | 0.26 | ល្អ |
| | សរុប | 4.15 | 0.23 | ល្អ |
| ឃ. ការសហការ និងទំនាក់ទំនង | | Statistic | Std. Error | Level |
| ១៩ | បានរៀបចំប្រជុំបុគ្គលិក ដើម្បីអភិវឌ្ឍការអនុវត្តកម្មវិធីសិក្សា | 4.11 | 0.31 | ល្អ |
| ២០ | បានផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃគ្រូជាផ្លូវការដល់ភាគីពាក់ព័ន្ធ | 3.67 | 0.24 | ល្អ |

| | | | | |
|---|---|---|---|---|
| ២១ | ផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋាន ទៅនឹងតម្រូវការសហគមន៍ | 3.56 | 0.34 | ល្អ |
| ២២ | មានកិច្ចពិភាក្សាលើលទ្ធផលសិក្សារបស់សិស្ស ទាំងសិស្សពូកែ និងសិស្សខ្សោយ | 4.11 | 0.20 | ល្អ |
| | សរុប | 3.86 | 0.27 | ល្អ |

តាមតារាងទិន្នន័យ ៤.៣ បានបង្ហាញពីមធ្យមភាគសរុបផ្នែក ក "ការគ្រប់គ្រង និងដឹកនាំការងារបង្រៀន" នៅវិទ្យាល័យក្នុងខេត្តតាកែវ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០២)។ សូចនាករ " ជំរុញគ្រូបង្រៀន បង្រៀនឱ្យទាន់កម្មវិធីសិក្សា" ទទួលបានការយល់ស្របខ្ពស់ជាងគេទៅលើការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៦៧) និងសូចនាករ "បញ្ជូនគ្រូបង្រៀន ចូលរួមក្នុងវគ្គបំប៉នបច្ចេកទេស វិធីសាស្ត្រថ្មី" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.១១)។

ផ្នែក ខ "ការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ" មធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៣៩)។ សូចនាករ " បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបានប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥៦) និងសូចនាករ "បានរៀបចំបណ្ណាល័យ និងការផ្គត់ផ្គង់សៀវភៅសិក្សាគោល" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១១)។

ផ្នែក គ "ការពិនិត្យតាមដាន និងវាយតម្លៃ" មធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៥)។ សូចនាករ " ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់តាមមុខវិជ្ជា" និងសូចនាករ "ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដោយតម្លាភាព" ទទួលបានការយល់ស្របខ្ពស់ជាងគេដូចគ្នា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៤៤) និង សូចនាករ "វាយតម្លៃការបង្រៀនរបស់គ្រូតាមរយៈការសង្កេតលើដំណើរការបង្រៀន" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៩)។

ផ្នែក ឃ "ការសហការ និងទំនាក់ទំនង" នៅវិទ្យាល័យក្នុងខេត្តតាកែវ មធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៦)។ សូចនាករ " បានរៀបចំប្រជុំបុគ្គលិកដើម្បីអភិវឌ្ឍការអនុវត្តកម្មវិធីសិក្សា" និងសូចនាករ "មានកិច្ចពិភាក្សាលើលទ្ធផលសិក្សារបស់សិស្សទាំងសិស្សពូកែនិងសិស្សខ្សោយ" ទទួលបានការយល់ស្របខ្ពស់ជាងគេដូចគ្នា ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១១) និងសូចនាករ "ផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍" ទទួលបានការ យល់ស្របទាបជាងគេ ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៥៦)។

តារាង៤.៤ ឆ្លុះបញ្ចាំងពីការគ្រប់គ្រង និងការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលានៅវិទ្យាល័យក្នុងខេត្តតាកែវ ពីតម្លៃមធ្យម (Mean) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពសរុបលើផ្នែកទាំងបួន៖ ក)ការគ្រប់គ្រងនិងដឹកនាំការងារបង្រៀន, ខ)ការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ, គ)ការពិនិត្យតាមដាន និងវាយតម្លៃ និង ឃ)ការសហការ និងទំនាក់ទំនង។

*តារាង៤.៤៖ កម្រិតនៃការអនុវត្តសកម្មភាព លើប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា*

| ល.រ | ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា | Mean | Level |
|---|---|---|---|
| ក | ការគ្រប់គ្រង និងដឹកនាំការងាបង្រៀន | 4.02 | ល្អ |
| ខ | ការគ្រប់គ្រង និងដឹកនាំការងាររៀនសូត្រ | 4.39 | ល្អណាស់ |
| គ | ការពិនិត្យតាមដាន និងវាយតម្លៃ | 4.15 | ល្អ |
| ឃ | ការសហការ និងទំនាក់ទំនង | 3.86 | ល្អ |
| | សរុប | 4.11 | ល្អ |

តាមតារាងទិន្នន័យ ៤.៤ បានបង្ហាញពីមធ្យមភាគសរុបនៃការគ្រប់គ្រងនិងដឹកនាំការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យក្នុងខេត្តតាកែវ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១១)។ ផ្នែក ខ "ការគ្រប់គ្រង និងដឹកនាំការងាររៀនសូត្រ" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៣៩) បន្ទាប់ ផ្នែក គ "ការពិនិត្យតាមដាន និងវាយតម្លៃ" ទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៥)។ ផ្នែក ក "ការគ្រប់គ្រង និងដឹកនាំការងារបង្រៀន" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០២) និង ផ្នែក ឃ "ការសហការ និងទំនាក់ទំនង" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៦)។

អ្នកស្រាវជ្រាវរកឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អមួយចំនួនតាមរយៈតារាងខាងលើនេះ។ នាយកសាលាមានការគ្រប់គ្រង និងដឹកនាំការងារបង្រៀនបានល្អអាចទទួលយកបាន ដោយពួកគាត់បានរៀបចំកាលវិភាគ និងធ្វើការបែងចែកកម្មវិធីសិក្សាសម្រាប់គ្រូគ្រប់កម្រិតថ្នាក់ តាមមុខវិជ្ជា និងជំរុញគ្រូបង្រៀនឱ្យបង្រៀនទាន់កម្មវិធីសិក្សានោះដោយស្មារតីទទួលខុសត្រូវខ្ពស់។ លើសពីនេះ នាយកសាលាបានផ្តល់សម្ភារឧបទេសដល់គ្រូបង្រៀនធ្វើគម្រោងផែនការអធិការកិច្ច និងអនុវត្តផែនការនោះបានទៀងទាត់ បានរៀបចំប្រជុំក្រុមបច្ចេកទេសលើគ្រប់មុខវិជ្ជា និងមានការលើកទឹកចិត្តគ្រូក្នុងការស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗដើម្បីប្រើប្រាស់ក្នុងការបង្រៀនសិស្ស។ សកម្មភាពទាំងនេះ ដូចគ្នាទៅនឹងការលើកឡើង

របស់លោក Mason (2004) ដែលបានអះអាងថា នាយកសាលាអាចកំណត់នូវផែនការកម្មវិធីសិក្សានៅក្នុងសាលារៀន និងជួយអភិវឌ្ឍគ្រប់សកម្មភាពនានាក្នុងការអប់រំ។ លោកបានបន្ថែមថា ប្រធានក្រុមបច្ចេកទេសគួរតែលើកកម្ពស់ថ្នាក់និទស្សន៍ និងលើកកម្ពស់ឱ្យគ្រូដែលបង្រៀនមុខវិជ្ជាដូចគ្នា ធ្វើការចែករំលែកចំណេះដឹងនិងបទពិសោធន៍រវាងគ្នានឹងគ្នា ។ ទោះបីការអនុវត្តលើដំណើរការគ្រប់គ្រង និងដឹកនាំការបង្រៀនបានល្អយ៉ាងណាក្តី បើពិនិត្យលើការបញ្ជូនគ្រូបង្រៀនទៅចូលរួមក្នុងវគ្គបំប៉នបច្ចេកទេស វិធីសាស្រ្តថ្មីមិនបានអនុវត្តបានច្រើនឡើយ ពោលគឺនៅកម្រិតមធ្យមប៉ុណ្ណោះ ពីព្រោះបើតាមការលើកឡើងរបស់នាយកសាលា ក្រសួងមិនបានបើកវគ្គបំប៉នលើផ្នែកនេះឱ្យបានច្រើននិងគ្រប់មុខវិជ្ជានៅឡើយទេ ដែលស្នើឱ្យមានការយកចិត្តទុកដាក់ ការពិនិត្យ និងកែលម្អនូវចំណុចខ្វះខាតនេះឱ្យល្អប្រសើរឡើងវិញដើម្បីអភិវឌ្ឍចំណេះដឹង និងវិធីសាស្រ្តបង្រៀនថ្មីៗរបស់គ្រូបង្រៀនស្របតាមការរីកចម្រើននៃសង្គម និងសកលលោក ដោយហេតុថាបើគ្មានការបើកវគ្គបណ្តុះបណ្តាល នោះនាយកសាលាមិនអាចបញ្ជូនគ្រូទៅចូលរួមបានទេ។ បញ្ហានេះហាក់មិនសូវឆ្លើយតបទៅនឹង យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ ត្រង់យុទ្ធសាស្រ្តរង១.២ ស្តីពីកែលម្អវិធីសាស្រ្តបង្រៀននៃយុទ្ធសាស្រ្តគោលទី១ ស្តីពីការគ្រប់គ្រងការសិក្សា ដែលបានលើកឡើងថា ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចអនុម័តនិងអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការអប់រំ ផ្តល់ធនធានសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងគាំទ្របច្ចេកទេសដល់សាលារៀន និងបណ្តុះបណ្តាលគ្រូបង្រៀន។ ក្រសួងអប់រំ យុវជន និងកីឡាត្រូវណែនាំវិធីសាស្រ្តរៀនផ្អែកលើគម្រោងសិស្សមជ្ឈមណ្ឌល និងវិធីសាស្រ្តបង្រៀនតាមបែបរិះរកនិងកសាងសមត្ថភាពអង្គភាពដើម្បីផ្តល់ការគាំទ្រនិងបណ្តុះបណ្តាលគ្រូបង្រៀន។ ដោយឡែក សាលារៀនត្រូវទទួលបន្ទុកបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងមេរៀនប្រកបដោយប្រសិទ្ធ-ភាព ការគ្រប់គ្រងថ្នាក់រៀន និងការផ្ចង់អារម្មណ៍របស់សិស្សក្នុងម៉ោងបង្រៀន ផ្តល់បច្ចេកវិទ្យាដើម្បីឱ្យគ្រូបង្រៀនប្រើប្រាស់ក្នុងការអនុវត្តវិធីសាស្រ្តបង្រៀនថ្មីៗ។

ដោយឡែក បើពិនិត្យលើផ្នែកការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រវិញ នាយកសាលាអនុវត្តបានល្អណាស់ ដោយពួកគាត់បានបង្កបរិយាកាសសិក្សាដល់សិស្សប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងមានជំនឿជាក់ក្រៃលែង។ លើសពីនេះ នាយកសាលាមានការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនមានការរើសអើង និងជំរុញឱ្យសិស្សមានទឹកចិត្តក្នុងការស្វ័យសិក្សាដោយខ្លួនឯងជាប្រចាំបន្ថែមទៀត។ សកម្មភាពទាំងនេះបានបញ្ជាក់ថានាយកសាលានៅកម្រិតវិទ្យាល័យបានអនុវត្តស្តង់ដាររបស់ខ្លួនបានល្អ ឆ្លើយតបនឹងស្តង់ដាទី៥ នៃស្តង់ដានាយកសាលារៀន ស្តីពីភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន

និងរៀន ត្រង់ចំណុច៥.១.ការគ្រប់គ្រងការរៀន និងការបង្រៀន។ ម្យ៉ាងវិញទៀត នាយកវិទ្យាល័យបានយកចិត្តទុកដាក់ខ្ពស់លើការអាន និងសិក្សាស្រាវជ្រាវបន្ថែមរបស់សិស្ស ដោយបានរៀបចំបណ្ណាល័យ និងផ្គត់ផ្គង់សៀវភៅសិក្សាគោល បង្កលក្ខណៈងាយស្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស ដែលត្រង់ចំណុចនេះក៏មានការលើកឡើងផងដែរនៅក្នុងភារកិច្ចរបស់នាយកសាលា ក្នុងសៀវភៅដែលមានចំណងជើងថា ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ ចងក្រងដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ បោះពុម្ពឆ្នាំ២០១៦ ត្រង់ទំព័រ៦៧ ដោយបានសរសេររៀបរាប់ថា នាយកសាលាមានភារកិច្ចផ្គត់ផ្គង់សៀវភៅគោល ឯកសារ និងសម្ភារផ្សេងៗ។

ចំណែកការពិនិត្យតាមដាន និងវាយតម្លៃ នាយកសាលាបានអនុវត្តបានល្អ ដោយបានយកចិត្តទុកដាក់ខ្ពស់ លើការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សារបស់គ្រូគ្រប់កម្រិតថ្នាក់តាមមុខវិជ្ជា ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រកបដោយតម្លាភាព បានកែលម្អចំណុចខ្វះខាតលើវិធីសាស្ត្របង្រៀនរបស់គ្រូបានល្អ បានវាយតម្លៃការបង្រៀនរបស់គ្រូ និងបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនោះ ដើម្បីកែលម្អឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។ ដូចលោក Mason បានរកឃើញថា នាយកសាលាឬគណៈនាយកត្រូវគ្រប់គ្រងយុទ្ធសាស្ត្រ ក្នុងការវាយតម្លៃធានាបាននូវម៉ោងបង្រៀន និងរៀនបានអនុវត្តប្រកបដោយប្រសិទ្ធភាព លើកកម្ពស់និងប្រើប្រាស់ផែនការបច្ចេកទេសដែលរៀបចំដោយក្រុមអភិវឌ្ឍ និងគ្រប់គ្រងធនធានសិក្សា។ ចំណែកគ្រប់សកម្មភាពនៅផ្នែកចុងក្រោយ ការសហការនិងទំនាក់ទំនងនាយកសាលា នៅកម្រិតវិទ្យាល័យអនុវត្តបានល្អ ពីព្រោះពួកគាត់បានសហការជាមួយគ្រូបង្រៀនគ្រប់រូបក្នុងការអភិវឌ្ឍការអនុវត្តកម្មវិធីសិក្សាដោយការប្រជុំផ្សេងៗ មានការពិភាក្សាលើលទ្ធផលសិក្សារបស់សិស្សបានទៀងទាត់ បានផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃគ្រូជាផ្លូវការដល់ភាគីពាក់ព័ន្ធ ព្រមទាំងការផ្សារភ្ជាប់បំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ ក៏បានអនុវត្តបានច្រើនគួរឱ្យកត់សម្គាល់។ ការអនុវត្តបានល្អនូវសកម្មភាពទាំងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញថា នាយកសាលាបានអនុវត្តសកម្មភាពឆ្លើយតបនឹងស្តង់ដានាយកសាលារៀន ត្រង់ចំណុច៥.៣ ស្តីពីការសហការ និងទំនាក់ទំនង ដែលបានរៀបរាប់ពីការសហការគ្នារបស់នាយកសា និងគ្រូបង្រៀន ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាពខ្ពស់។

### ក.បញ្ហាប្រឈមរបស់អ្នកដឹកនាំអនុវត្តកម្មវិធីសិក្សា

ចំពោះបញ្ហាប្រឈមក្នុងការដឹកនាំការអនុវត្តកម្មវិធីសិក្សា ក្នុងចំណោមគណៈគ្រប់គ្រងទាំង៩នាក់ ភាគច្រើនបានលើកឡើងថាការខ្វះគ្រូបង្រៀនតាមឯកទេសនៅកម្រិតទុតិយភូមិ គឺជាបញ្ហាប្រឈមមួយគួរឱ្យកត់សម្គាល់។ ចំណែកគណៈគ្រប់គ្រងមួយចំនួនទៀតយល់ឃើញ

ថា បញ្ហាប្រឈមនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សាគឺការខ្វះបន្ទប់រៀន គ្រូមួយចំនួនតូចមិនមានមនសិការវិជ្ជាជីវៈ មិនគោរពពេលវេលា (មកបង្រៀនយឺត) និងការបើកវគ្គបំប៉នវិធីសាស្ត្រថ្មីៗដល់គ្រូបង្រៀនរបស់ក្រសួងនៅមានកម្រិតទាបនៅឡើយ។ ចំណែកមតិភាគតិចបានលើកឡើងថា គ្រូបង្រៀនភាគច្រើនធ្វើកិច្ចតែងការបង្រៀនមិនទាន់បានត្រឹមត្រូវល្អ ហើយសាលារៀននៅខ្វះបន្ទប់កុំព្យូទ័រ និងកុំព្យូទ័រសម្រាប់ឱ្យសិស្សអនុវត្តផ្ទាល់។

លទ្ធផលខាងលើបង្ហាញថា បញ្ហាប្រឈមដែលកើតមានឡើងក្នុងការដឹកនាំការអនុវត្តកម្មវិធីសិក្សាផ្នែកមធ្យមសិក្សាទុតិយភូមិគឺដោយសារក្រសួងអប់រំ យុវជន និងកីឡាមិនបានផ្តល់គ្រូបង្រៀនគ្រប់គ្រាន់តាមឯកទេស កង្វះបន្ទប់រៀន បន្ទប់និងសម្ភារបរិក្ខារកុំព្យូទ័រក្នុងការបង្រៀនសិស្ស និងមិនបានបើកវគ្គបំប៉នសមត្ថភាពនិងវិធីសាស្ត្របង្រៀនថ្មីៗដល់គ្រូបង្រៀនឱ្យបានគ្រប់មុខវិជ្ជា។ ចំណែកគ្រូបង្រៀនមួយចំនួនមិនបានអនុវត្តភារកិច្ចរបស់ខ្លួនបានល្អ មិនគោរពពេលវេលាចេញចូល ជាហេតុនាំឱ្យការដឹកនាំអនុវត្តកម្មវិធីសិក្សាជួបនូវការលំបាក។ បញ្ហាប្រឈមខាងលើនេះ ហាក់ឆ្លើយតបគ្នានឹងបញ្ហាប្រឈមក្នុងរបាយការណ៍សន្និបាតបូកសរុបវាយតម្លៃការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៨-២០១៩ របស់ខេត្តតាកែវ កន្លងទៅថ្មីៗនេះ ត្រង់អនុវិស័យធម្យមសិក្សានិងអប់រំបច្ចេកទេស ដែលបានលើកឡើងថា គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ ភាគច្រើនខ្វះគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ដូចជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា។ កង្វះអគារសិក្សា បណ្ណាល័យ បន្ទប់ពិសោធន៍ ផ្ទះគ្រូបង្រៀន (ពិសេសតំបន់ជួបការលំបាក)។ ចំណុចនេះក៏ដូចគ្នានឹងបញ្ហាមួយចំនួននៃការលើកឡើងរបស់ Chisholm (2000) ដែលបានរកឃើញចំណុចខ្សោយនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សាគឺ គុណភាពនៃការគាំទ្រការរៀននិងសម្ភារបង្រៀននៅមានកម្រិតទាប ម៉ោងសិក្សាមិនអាចគ្រប់គ្រងបាននិងពិតប្រាកដ មិនមានការណែនាំគ្រូបង្រៀនគ្រប់គ្រាន់ និងបណ្តុះបណ្តាលក្នុងការផ្លាស់ប្តូរទៅជាការអនុវត្តក្នុងថ្នាក់រៀន។

ដើម្បីដោះស្រាយបញ្ហាចំពោះមុខទាំងនេះ នាយកសាលាបានបង្ខំចិត្តរៀបចំគ្រូបង្រៀនកម្រិតមូលដ្ឋានមកបង្រៀននៅផ្នែកទុតិយភូមិ ដើម្បីបំពេញបន្ថែមលើមុខវិជ្ជាណាដែលខ្វះគ្រូ។ ចំណែកបញ្ហាកង្វះបន្ទប់រៀន នាយកសាលាបានបង្រួមថ្នាក់រៀនឱ្យនៅចំនួនតិចតម្រូវនឹងចំនួនបន្ទប់រៀនដែលមាន ដោយក្នុងមួយថ្នាក់ៗមានចំនួនសិស្សច្រើនហួសនិយាមកំណត់របស់ក្រសួង។ លើសពីនេះ នាយកសាលារៀនបានលើកជាសំណូមពរជាច្រើនដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបំពេញនូវកង្វះខាតផ្សេងៗដែលបានលើកឡើង។

### ខ.សំណូមពររបស់អ្នកឆ្លើយតប តាមទិន្នន័យកម្រងសំណួរ

ចំណែកសំណូមពរ ក្នុងការដោះស្រាយបញ្ហាប្រឈម គណៈគ្រប់គ្រងភាគច្រើនបាន លើកជាសំណូមពរថា ៖

- ស្នើសុំដល់ក្រសួងផ្តល់គ្រូបង្រៀនតាមមុខវិជ្ជាដែលខ្វះ តាមសំណូមពររបស់សាលា និង បំប៉នសមត្ថភាពនិងវិធីសាស្ត្របង្រៀនថ្មីៗដល់គ្រូបង្រៀនគ្រប់មុខវិជ្ជា។

- រីឯគណៈគ្រប់គ្រងមួយចំនួនតូចបានលើកជាសំណូមពរថា ក្រសួងគួរជំរុញលើកទឹកចិត្ត គ្រូដែលអនុវត្តការងារបានល្អ និងដាក់ពិន័យចំពោះគ្រូដែលបំពេញការងារមិនបានល្អ សាង សង់អគារសិក្សាឱ្យបានគ្រប់គ្រាន់ ស្នើមន្ទីរចុះអធិការកិច្ចជាប្រចាំ សុំកុំព្យូទ័រនិងបន្ទប់កុំព្យូទ័រ និងជួយដោះស្រាយរាល់សំណូមពរដែលបានដាក់ជូន។

## ៤.២. ការវិភាគទិន្នន័យលើកម្រងសំណួរទី២

### ៤.២.១.ព័តមានទូទៅរបស់អ្នកចូលរួម

តាមតារាង ៤.៥ មានបង្ហាញព័ត៌មានទូទៅរបស់គ្រូបង្រៀនជាសំណាកស្រាវជ្រាវទាំង អស់ ដែលមានព័ត៌មានលម្អិតពីភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍បង្រៀន និងមុខវិជ្ជា កំពុងបង្រៀន ផ្នែកមធ្យមសិក្សាទុតិយភូមិ ដូចមានក្នុងតារាងនីមួយៗខាងក្រោម៖

*តារាង ៤.៥ ៖ ចំនួនគ្រូបង្រៀនគិតតាមភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍បង្រៀន និង មុខវិជ្ជាកំពុងបង្រៀន*

| ល.រ | បរិយាយ | | វិទ្យាល័យ | | | សរុបរួម | |
|---|---|---|---|---|---|---|---|
| | | | វិ.ហាសរព្រៃល្វា | វិ.អង្គអណ្តែត | វិ.ហាស១មិថុនា | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | 14 | 6 | 13 | 33 | 82.5% |
| | | ស្រី | 3 | 1 | 3 | 7 | 17.5% |
| | | សរុប | 17 | 7 | 16 | 40 | 100.0% |
| ២ | អាយុ | ២០-៣០ឆ្នាំ | 6 | 0 | 2 | 8 | 20.0% |
| | | ៣១-៤៥ឆ្នាំ | 10 | 5 | 13 | 28 | 70.0% |
| | | លើស៤៥ឆ្នាំ | 1 | 2 | 1 | 4 | 10.0% |
| | | សរុប | 17 | 7 | 16 | 40 | 100.0% |
| ៣ | កម្រិតវប្បធម៌ | បរិញ្ញាបត្រ | 16 | 5 | 11 | 32 | 80.0% |
| | | បរិ.ជាន់ខ្ពស់ | 1 | 1 | 0 | 2 | 5.0% |
| | | ផ្សេងៗ | 0 | 1 | 5 | 6 | 15.0% |
| | | សរុប | 17 | 7 | 16 | 40 | 100.0% |
| ៤ | | ១-៣ឆ្នាំ | 1 | 0 | 2 | 3 | 7.5% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បទពិសោធន៍បង្រៀន | ៤-៦ឆ្នាំ | 4 | 0 | 2 | 6 | 15.0% |
| | | ៧-១០ឆ្នាំ | 4 | 3 | 6 | 13 | 32.5% |
| | | លើស១០ឆ្នាំ | 8 | 4 | 6 | 18 | 45.0% |
| | | សរុប | 17 | 7 | 16 | 40 | 100.0% |
| ៥ | មុខវិជ្ជាបង្រៀន | អក្សរសាស្ត្រខ្មែរ | 4 | 1 | 3 | 8 | 20.0% |
| | | គណិត | 3 | 1 | 3 | 7 | 17.5% |
| | | រូបវិទ្យា | 1 | 1 | 1 | 3 | 7.5% |
| | | គីមីវិទ្យា | 2 | 1 | 1 | 4 | 10.0% |
| | | ជីវវិទ្យា | 1 | 1 | 1 | 3 | 7.5% |
| | | ផែនដីវិទ្យា | 1 | 0 | 1 | 2 | 5.0% |
| | | សីលធម៌-ពលរដ្ឋ | 1 | 0 | 2 | 3 | 7.5% |
| | | ភូមិវិទ្យា | 1 | 0 | 1 | 2 | 5.0% |
| | | ប្រវត្តិវិទ្យា | 2 | 1 | 1 | 4 | 10.0% |
| | | អង់គ្លេស | 1 | 1 | 1 | 3 | 7.5% |
| | | ICT | 0 | 0 | 1 | 1 | 2.5% |
| | | សរុប | 17 | 7 | 16 | 40 | 100.0% |

តារាងខាងលើបង្ហាញថា គ្រូបង្រៀនដែលបានបំពេញកម្រងសំណួរមានចំនួនសរុប៤០នាក់ ក្នុងនោះស្រី ៧នាក់ ស្មើនឹង ១៧,៥% និងប្រុស ៣៣នាក់ ស្មើនឹង ៨២,៥% ។ ក្នុងចំណោមគ្រូបង្រៀនទាំង៤០នាក់ គ្រូអាយុពី២០-៣០ឆ្នាំ មានចំនួន ៨នាក់ ស្មើនឹង ២០,០% អាយុពី៣១-៤៥ឆ្នាំ មានចំនួន ២៨ នាក់ ស្មើនឹង ៧០,០% និងអាយុលើសពី៤៥ឆ្នាំ មានចំនួន ៤ នាក់ ស្មើនឹង ១០,០%។ គ្រូបង្រៀនដែលមានបរិញ្ញាបត្រចំនួន ៣២នាក់ ស្មើនឹង ៨០,០% មានបរិញ្ញាបត្រជាន់ខ្ពស់ ២នាក់ ស្មើនឹង ៥,០% និងមានសញ្ញាបត្រផ្សេងៗ (សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ) ចំនួន ៦នាក់ ស្មើនឹង១៥,០%។ ដោយឡែក គ្រូបង្រៀនមានបទពិសោធន៍បង្រៀនរយៈពេលពី១-៣ឆ្នាំ មានចំនួន ៣នាក់ ស្មើនឹង ៧,៥% រយៈពេលពី ៤-៦ឆ្នាំ មានចំនួន ៦នាក់ ស្មើនឹង ១៥,០% រយៈពេលពី៧-១០ឆ្នាំ មានចំនួន ១៣នាក់ ស្មើនឹង ៣២,៥% និងមានរយៈពេលលើសពី១០ឆ្នាំ ចំនួន ១៨នាក់ ស្មើនឹង ៤៥,០%។ ក្នុងចំណោមគ្រូបង្រៀនទាំង ៤០នាក់ គ្រូកំពុងបង្រៀនមុខវិជ្ជា អក្សរសាស្ត្រខ្មែរចំនួន ៨នាក់ ស្មើនឹង ២០,០% គណិតវិទ្យាចំនួន ៧នាក់ ស្មើនឹង១៧,៥% រូបវិទ្យា ៣នាក់ ស្មើនឹង ៧,៥% គីមីវិទ្យា ៤នាក់ ស្មើនឹង ១០,០% ជីវវិទ្យា ៣នាក់ស្មើនឹង ៧,៥% ផែនដីវិទ្យា ២នាក់ ស្មើនឹង ៥,០% សីលធម៌-ពលរដ្ឋវិជ្ជា ៣នាក់ ស្មើនឹង ៧,៥% ភូមិវិទ្យា២នាក់ ស្មើនឹង ៥,០% ប្រវត្តិវិទ្យា ៤នាក់ ស្មើនឹង ១០,០% ភាសាអង់គ្លេស ៣

នាក់ ស្មើនឹង ៧,៥% និង មុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ចំនួន ១នាក់ ស្មើនឹង ២,៥%។

### ៤.២.២.ការអនុវត្តកម្មវិធីសិក្សា

តាមតារាង ៤.៦ យើងសង្កេតឃើញថា អ្នកឆ្លើយសំណួរក្នុងកម្រិតនៃការអនុវត្តច្រើន មានចំនួនច្រើនជាងគេគឺ ៤៦,៦៧% បន្ទាប់មកកម្រិតនៃការអនុវត្តច្រើនបំផុតមាន ៣២,៥៩% កម្រិតមធ្យមមាន ១៥,៣៧% កម្រិតនៃការអនុវត្តបានតិចមាន ៣,១៥% និងកម្រិតដែលបានអនុវត្តតិចជាងគេគឺកម្រិតតិចបំផុតមានត្រឹមតែ ២,២២%។

*តារាង ៤.៦ ៖ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត*

| ល.រ | សំណួរស្តីពីការអនុវត្តកម្មវិធីសិក្សា | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | |
|---|---|---|---|---|---|---|
| | | តិចបំផុត | តិច | មធ្យម | ច្រើន | ច្រើនបំផុត |
| ក. ការអនុវត្តកម្មវិធីសិក្សា | | | | | | |
| ១ | បានអនុវត្តកម្មវិធីសិក្សាតាមគោលការណែនាំស្របតាមកម្រិតថ្នាក់ | 0 | 0 | 4 | 16 | 20 |
| ២ | បានអនុវត្តថ្នាក់និទស្សន៍លើក្របខណ្ឌមុខវិជ្ជាគោល | 8 | 7 | 14 | 6 | 5 |
| ៣ | មានកិច្ចតែងការបង្រៀន លើគ្រប់មុខវិជ្ជា | 0 | 1 | 4 | 12 | 23 |
| ៤ | បានបង្រៀនគ្រប់តាមម៉ោងសិក្សាកំណត់ ក្នុងមួយពេលម៉ោង | 0 | 0 | 1 | 16 | 23 |
| ៥ | បានបង្រៀនឱ្យទាន់កម្មវិធីសិក្សា លើគ្រប់មុខវិជ្ជា | 0 | 0 | 2 | 17 | 21 |
| ៦ | ចូលរួមប្រជុំក្នុងក្រុមបច្ចេកទេសមុខវិជ្ជា បានយ៉ាងទៀងទាត់ | 0 | 1 | 7 | 16 | 16 |
| ខ.រៀបចំដំណើរការបង្រៀន | | | | | | |
| ៧ | មានសៀវភៅកត់ត្រា ស្របតាមដំណើរការបង្រៀន | 0 | 0 | 4 | 16 | 20 |
| ៨ | មានរៀបចំកិច្ចតែងការ មុនដំណើរការបង្រៀន | 0 | 0 | 5 | 15 | 20 |
| ៩ | មានសម្ភារៈឧបទេស ក្នុងការបង្រៀន | 0 | 3 | 14 | 20 | 3 |

| | | | | | | |
|---|---|---|---|---|---|---|
| ១០ | បានផលិតសម្ភារឧបទេសគាំទ្រដល់ការបង្រៀន | 1 | 5 | 17 | 15 | 2 |
| ១១ | វាយតម្លៃលទ្ធផលសិក្សា របស់សិស្សបានត្រឹមត្រូវ | 0 | 0 | 3 | 26 | 11 |
| ១២ | បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបានប្រកបដោយភាពរីករាយ ស្និទ្ធស្នាល | 0 | 0 | 3 | 17 | 20 |
| ១៣ | បានកំណត់វិធីសាស្ត្របង្រៀន ទៅតាមមេរៀននីមួយៗ | 0 | 0 | 2 | 25 | 13 |
| គ.ចំណេះដឹងលើជំនាញ | | | | | | |
| ១៤ | បានបង្រៀនត្រូវតាមឯកទេសដែលបានសិក្សា ស្របតាមវិជ្ជាជីវៈ | 0 | 0 | 2 | 12 | 26 |
| ១៥ | ចូលរួមធ្វើផែនការអធិការកិច្ច ដើម្បីជួយឱ្យការអនុវត្តផែនការនោះបានល្អ | 4 | 4 | 5 | 20 | 7 |
| ១៦ | បានចូលរួមវគ្គបណ្តុះបណ្តាល លើការអភិវឌ្ឍកម្មវិធីសិក្សា | 10 | 2 | 10 | 16 | 2 |
| ១៧ | សរសេរកិច្ចតែងការបង្រៀន ដោយឆ្លុះបញ្ចាំងគ្រប់ឥរិយាបថសិក្សា | 1 | 2 | 8 | 18 | 11 |
| ១៨ | យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមេរៀនមួយទៅមេរៀនមួយ | 0 | 0 | 6 | 25 | 9 |
| ឃ.វិធីសាស្ត្របង្រៀន | | | | | | |
| ១៩ | ប្រើប្រាស់វិធីសាស្ត្រ ទៅតាមកម្រិតសិក្សារបស់សិស្ស | 0 | 1 | 4 | 22 | 13 |
| ២០ | ការកែលម្អវិធីសាស្ត្របង្រៀន និងស្រាវជ្រាវបន្ថែមលើបច្ចេកទេសបង្រៀនថ្មីៗ | 0 | 0 | 5 | 29 | 6 |
| ២១ | ការរិះរកវិធីសាស្ត្រជួយបង្រៀនបន្ថែមដល់សិស្សរៀនយឺត | 0 | 1 | 8 | 24 | 7 |
| ២២ | ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃ និងមុខវិជ្ជាដទៃ | 0 | 1 | 7 | 23 | 9 |

ង.ការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា

| | | | | | | |
|---|---|---|---|---|---|---|
| ២៣ | ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 0 | 0 | 9 | 25 | 6 |
| ២៤ | ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស | 0 | 1 | 8 | 21 | 10 |
| ២៥ | ផ្តល់ព័ត៌មានត្រឡប់អំពីសិស្ស ទៅដល់អាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និង ឥរិយាបថរបស់សិស្ស | 0 | 5 | 9 | 17 | 9 |
| ២៦ | រៀបចំដំណើរការប្រឡងសំណេរប្រកបដោយតម្លាភាព | 0 | 0 | 1 | 15 | 24 |
| ២៧ | ពិនិត្យតាមដាន ការសិក្សារបស់សិស្សជាប្រចាំ និងដោយឡែក | 0 | 0 | 4 | 20 | 16 |
| | ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ | 2.22% | 3.15% | 15.37% | 46.67% | 32.59% |

តារាង ៤.៧ ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀនផ្នែកទុតិយភូមិនៅវិទ្យាល័យក្នុងខេត្តតាកែវ ពីតម្លៃមធ្យម (Mean) តម្លៃគម្លាតស្តង់ដារ (Std. Error) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពតាមផ្នែកទាំងប្រាំៈ ការអនុវត្តកម្មវិធីសិក្សា, រៀបចំដំណើរការបង្រៀន, ចំណេះដឹងលើជំនាញ, វិធីសាស្ត្របង្រៀន និងការពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលសិក្សា។

*តារាង ៤.៧ ៖ កម្រិតនៃការអនុវត្តសកម្មភាពលម្អិតតាមផ្នែកទាំងប្រាំ នៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន*

| ក. ការអនុវត្តកម្មវិធីសិក្សា | | Mean | | Level |
|---|---|---|---|---|
| | | Statistic | Std. Error | |
| ១ | បានអនុវត្តកម្មវិធីសិក្សាតាមគោលការណែនាំ ស្របតាមកម្រិតថ្នាក់ | 4.40 | 0.11 | ល្អណាស់ |
| ២ | បានអនុវត្តថ្នាក់និទស្សន៍លើក្របខណ្ឌមុខវិជ្ជាគោល | 2.83 | 0.20 | មធ្យម |
| ៣ | មានកិច្ចតែងការបង្រៀន លើគ្រប់មុខវិជ្ជាគោល | 4.43 | 0.12 | ល្អណាស់ |
| ៤ | បានបង្រៀនគ្រប់តាមម៉ោងសិក្សាកំណត់ ក្នុងមួយពេលម៉ោង | 4.55 | 0.09 | ល្អណាស់ |

| | | | | |
|---|---|---|---|---|
| ៥ | បានបង្រៀនឱ្យទាន់កម្មវិធីសិក្សា លើគ្រប់មុខវិជ្ជា | 4.48 | 0.09 | ល្អណាស់ |
| ៦ | ចូលរួមប្រជុំក្នុងក្រុមបច្ចេកទេសមុខវិជ្ជា បានយ៉ាងទៀងទាត់ | 4.18 | 0.13 | ល្អ |
| | សរុប | 4.15 | 0.12 | ល្អ |
| ខ.រៀបចំដំណើរការបង្រៀន | | Mean | | Level |
| | | Statistic | Std. Error | |
| ៧ | មានសៀវភៅកត់ត្រា ស្របតាមដំណើរការបង្រៀន | 4.40 | 0.11 | ល្អណាស់ |
| ៨ | មានរៀបចំកិច្ចតែងការ មុនដំណើរការបង្រៀន | 4.38 | 0.11 | ល្អណាស់ |
| ៩ | មានសម្ភារៈឧបទេស ក្នុងការបង្រៀន | 3.58 | 0.12 | ល្អ |
| ១០ | បានផលិតសម្ភារឧបទេសគាំទ្រដល់ការបង្រៀន | 3.30 | 0.13 | មធ្យម |
| ១១ | វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ | 4.20 | 0.09 | ល្អ |
| ១២ | បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបាន ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល | 4.43 | 0.10 | ល្អណាស់ |
| ១ | បានកំណត់វិធីសាស្ត្របង្រៀន ទៅតាមមេរៀននីមួយៗ | 4.27 | 0.09 | ល្អណាស់ |
| | សរុប | 4.05 | 0.11 | ល្អ |
| គ.ចំណេះដឹងលើជំនាញ | | Mean | | Level |
| | | Statistic | Std. Error | |
| ១៤ | បានបង្រៀនត្រូវតាមឯកទេសដែលបានសិក្សា ស្របតាមវិជ្ជាជីវៈ | 4.60 | 0.09 | ល្អណាស់ |
| ១៥ | ចូលរួមធ្វើផែនការអធិការកិច្ច ដើម្បីជួយឱ្យការអនុវត្តផែនការនោះបានល្អ | 3.55 | 0.19 | ល្អ |
| ១៦ | បានចូលរួមវគ្គបណ្តុះបណ្តាល លើការអភិវឌ្ឍកម្មវិធីសិក្សា | 2.95 | 0.21 | មធ្យម |
| ១៧ | សរសេរកិច្ចតែងការបង្រៀន ដោយឆ្លុះបញ្ចាំងគ្រប់តវិយាបថសិក្សា | 3.90 | 0.15 | ល្អ |
| ១៨ | យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមេរៀនមួយទៅមេរៀនមួយ | 4.08 | 0.10 | ល្អ |
| | សរុប | 3.82 | 0.15 | ល្អ |
| ឃ.វិធីសាស្ត្របង្រៀន | | Mean | | Level |
| | | Statistic | Std. Error | |
| ១៩ | ប្រើប្រាស់វិធីសាស្ត្រ ទៅតាមកម្រិតសិក្សារបស់សិស្ស | 4.18 | 0.11 | ល្អ |

| | | | | |
|---|---|---|---|---|
| ២០ | ការកែលម្អវិធីសាស្ត្របង្រៀន និងស្រាវជ្រាវបន្ថែមលើបច្ចេកទេសបង្រៀនថ្មីៗ | 4.03 | 0.08 | ល្អ |
| ២១ | ការរិះរកវិធីសាស្ត្រជួយបង្រៀនបន្ថែមដល់សិស្សរៀនយឺត | 3.92 | 0.11 | ល្អ |
| ២២ | ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃ និងមុខវិជ្ជាដទៃ | 4.00 | 0.11 | ល្អ |
| | សរុប | 4.03 | 0.10 | ល្អ |

| ង.ការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា | | Mean | | Level |
|---|---|---|---|---|
| | | Statistic | Std. Error | |
| ២៣ | ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 3.93 | 0.10 | ល្អ |
| ២៤ | ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស | 4.00 | 0.12 | ល្អ |
| ២៥ | ផ្តល់ព័ត៌មានត្រឡប់អំពីសិស្ស ទៅដល់អាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និង ឥរិយាបថរបស់សិស្ស | 3.75 | 0.15 | ល្អ |
| ២៦ | រៀបចំដំណើរការប្រឡងសំណេរ ប្រកបដោយតម្លាភាព | 4.57 | 0.09 | ល្អណាស់ |
| ២៧ | ពិនិត្យតាមដាន ការសិក្សារបស់សិស្សជាប្រចាំ និងដោយឡែក | 4.30 | 0.10 | ល្អណាស់ |
| | សរុប | 4.11 | 0.11 | ល្អ |

តាមតារាងទិន្នន័យ ៤.៧ បានបង្ហាញពីមធ្យមភាគសរុបផ្នែក ក "ការអនុវត្តកម្មវិធីសិក្សា" របស់គ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យក្នុងខេត្តតាកែវ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៥)។ សូចនាករ " បានបង្រៀនគ្រប់តាមម៉ោងសិក្សាកំណត់ក្នុងមួយពេលម៉ោង" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥៥) និង សូចនាករ "បានអនុវត្តថ្នាក់និទស្សន៍លើក្របខណ្ឌមុខវិជ្ជាគោល" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ២.៨៣)។

ផ្នែក ខ "រៀបចំដំណើរការបង្រៀន" របស់គ្រូបង្រៀននៅវិទ្យាល័យក្នុងខេត្តតាកែវ មធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០៥)។ សូចនាករ " បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបាន ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤៣) និង សូចនាករ "បានផលិតសម្ភារឧបទេសគាំទ្រដល់ការបង្រៀន" ទទួលបានការយល់ស្របទាប

ជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣០)។

ផ្នែក គ "ចំណេះដឹងលើជំនាញ" របស់គ្រូបង្រៀននៅវិទ្យាល័យក្នុងខេត្តតាកែវមធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨២)។ សូចនាករ " បានបង្រៀនត្រូវតាមឯកទេសដែលបានសិក្សាស្របតាមវិជ្ជាជីវៈ" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦០) និង សូចនាករ "បានចូលរួមវគ្គបណ្តុះបណ្តាល លើការអភិវឌ្ឍកម្មវិធីសិក្សា" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ២.៩៥)។

ផ្នែក ឃ "វិធីសាស្រ្តបង្រៀន" របស់គ្រូបង្រៀន នៅវិទ្យាល័យក្នុងខេត្តតាកែវមធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០៣)។ សូចនាករ " ប្រើប្រាស់វិធីសាស្រ្តទៅតាមកម្រិតសិក្សារបស់សិស្ស" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.១៨) និង សូចនាករ "ការរិះរកវិធីសាស្រ្តជួយបង្រៀនបន្ថែមដល់សិស្សរៀនយឺត" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៩២)។

ផ្នែក ង "ការពិនិត្យតាដាន និងវាយតម្លៃលទ្ធផលសិក្សា" របស់គ្រូបង្រៀននៅវិទ្យាល័យក្នុងខេត្តតាកែវ មធ្យមភាគសរុបគឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១១)។ សូចនាករ " រៀបចំដំណើរការប្រឡងសំណេរ ប្រកបដោយតម្លាភាព" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៥៧) និង សូចនាករ "ផ្តល់ព័ត៌មានត្រឡប់អំពីសិស្ស ទៅដល់អាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស" ទទួលបានការយល់ស្របទាបជាងគេ ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៧៥)។

តារាង៤.៨ ឆ្លុះបញ្ចាំងពីការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យក្នុងខេត្តតាកែវ ពីតម្លៃមធ្យម (Mean) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពសរុបលើផ្នែកទាំងប្រាំ៖ ក)ការអនុវត្តកម្មវិធីសិក្សា, ខ)រៀបចំដំណើរការបង្រៀន, គ) ចំណេះដឹងលើជំនាញ , ឃ)វិធីសាស្រ្តបង្រៀន និង ង)ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សា។

*តារាង៤.៨ ៖ កម្រិតនៃការអនុវត្តសកម្មភាព លើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា*

| ល.រ | ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា | Mean | Level |
|---|---|---|---|
| ក | ការអនុវត្តកម្មវិធីសិក្សា | 4.15 | ល្អ |
| ខ | រៀបចំដំណើរការបង្រៀន | 4.05 | ល្អ |
| គ | ចំណេះដឹងលើជំនាញ | 3.82 | ល្អ |
| ឃ | វិធីសាស្ត្របង្រៀន | 4.03 | ល្អ |
| ង | ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សា | 4.11 | ល្អ |
| | សរុប | 4.03 | ល្អ |

តាមតារាងទិន្នន័យ ៤.៨ បានបង្ហាញពីមធ្យមភាគសរុបនៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យក្នុងខេត្តតាកែវ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០៣)។ ផ្នែក ក "ការអនុវត្តកម្មវិធីសិក្សា" ទទួលបានការយល់ស្របខ្ពស់ជាងគេ ទៅលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៥) បន្ទាប់ ផ្នែក ង "ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សា" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១១)។ ផ្នែក ខ "រៀបចំដំណើរការបង្រៀន" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០៥) ។ ផ្នែក ឃ "វិធីសាស្ត្របង្រៀន" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០៣) និងផ្នែក គ "ចំណេះដឹងលើជំនាញ" ទទួលបានការយល់ស្រប ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨២) ។

អ្នកស្រាវជ្រាវបានរកឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អមួយចំនួនតាមរយៈតារាងខាងលើនេះ។ គ្រូបង្រៀនបានអនុវត្តកម្មវិធីសិក្សាបានល្អ ដោយពួកគាត់បានអនុវត្តកម្មវិធីសិក្សាតាមគោលការណែនាំ បានបង្រៀនគ្រប់តាមម៉ោងសិក្សាក្នុងមួយពេលម៉ោង បង្រៀនទាន់កម្មវិធី ស្របតាមស្តង់ដារទី៤ នៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលលើកឡើងថា គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាព ទាំងក្នុងនិងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។ លើសពីនេះទៅទៀតអ្នកស្រាវជ្រាវបានរកឃើញថា គ្រូបង្រៀនមានកិច្ចតែងការបង្រៀនត្រឹមត្រូវ និងចូលរួមប្រជុំក្រុមបច្ចេកទេសបានយ៉ាងទៀងទាត់ ដូចការលើកឡើងរបស់ Carl (1997) ដែលបានអះអាងថាដើម្បីធានាឱ្យការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនត្រូវតែធ្វើកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវ និងប្រាស្រ័យទាក់ទងជាមួយប្រធានក្រុមបច្ចេកទេសជាញឹកញាប់ និងទៀងទាត់ដើម្បីទទួលបានដំបូន្មាន និងជំនួយបច្ចេកទេស។

ថ្វីត្បិតតែការអនុវត្តកម្មវិធីសិក្សាបានល្អយ៉ាងណាក្តីក៏សង្កេតឃើញថា ការធ្វើថ្នាក់និទស្សន៍លើក្របខណ្ឌមុខវិជ្ជាគោល អនុវត្តបានកម្រិតមធ្យមនៅឡើយ ដែលត្រូវស្នើពង្រឹងបន្ថែមទៀត។

អ្នកស្រាវជ្រាវបានរកឃើញបន្ថែមទៀតថាគ្រូបង្រៀនមានការរៀបចំដំណើរការបង្រៀនបានល្អ។ មុនដំណើរការបង្រៀន ពួកគាត់បានបង្កបរិយាកាសប្រកបដោយភាពរីករាយ សិទ្ធស្នាលដើម្បីឱ្យសិស្សចាប់អារម្មណ៍ចង់រៀន និងមានរៀបចំសៀវភៅកត់ត្រាស្របតាមដំណើរការបង្រៀនបានល្អ។ គ្រូបង្រៀនមានរៀបចំកិច្ចតែងការបង្រៀនបានត្រឹមត្រូវ បានកំណត់វិធីសាស្រ្តបង្រៀនបានសមស្របទៅតាមខ្លឹមសារមេរៀន វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានត្រឹមត្រូវ និងមានរៀបចំសម្ភារឧបទេសសមស្របមុននឹងចាប់ផ្តើមដំណើរការបង្រៀន។ ប៉ុន្តែការផលិតសម្ភារឧបទេសគាំទ្រដល់ការបង្រៀន ស្ថិតក្នុងកម្រិតមធ្យមនៅឡើយ ដែលត្រូវពង្រឹងនិងកែលម្អបន្ថែមទៀត។ សកម្មភាពទាំងនេះ បានឆ្លុះបញ្ចាំងពីការអនុវត្តរបស់គ្រូ ឆ្លើយតបតាមស្តង់ដារវិជ្ជាជីវៈរបស់ខ្លួនបានយ៉ាងល្អស្របតាមស្តង់ដារទី២ ស្តីពីការប្រតិបត្តិវិជ្ជាជីវៈ ។

បើពិនិត្យមើលអំពីចំណេះដឹងលើជំនាញរបស់គ្រូបង្រៀនវិញ ក៏ស្ថិតនៅកម្រិតល្អដែរ ដោយពួកគាត់បានបង្រៀនត្រូវតាមឯកទេសរបស់ខ្លួនដែលបានសិក្សា ស្របតាមវិជ្ជាជីវៈត្រឹមត្រូវ យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមេរៀនមួយទៅមេរៀនមួយបានល្អ សរសេរកិច្ចតែងការបង្រៀនដោយឆ្លុះបញ្ចាំងគ្រប់ឥរិយាបថសិក្សារបស់សិស្សបានត្រឹមត្រូវ និងបានចូលរួមធ្វើផែនការអធិការកិច្ច ដើម្បីជួយឱ្យការអនុវត្តផែនការនោះបានល្អ។ លទ្ធផលនេះបានបង្ហាញថាគ្រូបង្រៀនមានគុណសម្បត្តិត្រឹមត្រូវស្របតាមស្តង់ដារទី១ ស្តីអំពីចំណេះដឹងវិជ្ជាជីវៈនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលបានចែងថា គ្រូបង្រៀនត្រូវយល់ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀនដូចជា វត្ថុបំណង វិធីសាស្រ្តបង្រៀន និងអាចជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនត្រូវយល់ពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់ មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។ ប៉ុន្តែគ្រូបង្រៀនមិនសូវបានចូលរួមវគ្គបណ្តុះបណ្តាលលើការអភិវឌ្ឍកម្មវិធីសិក្សាញឹកញាប់ឡើយ ដែលក្រសួងអប់រំ យុវជន និកីឡាគួរពិនិត្យ និងយកចិត្តទុកដាក់ដោះស្រាយ លើបញ្ហានេះ ដើម្បីការអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាពខ្ពស់។

ចំណែកការប្រើប្រាស់វិធីសាស្រ្តបង្រៀនវិញ គ្រូបង្រៀនអនុវត្តបានល្អ។ គ្រូបង្រៀនបានប្រើប្រាស់វិធីសាស្រ្តសមស្របទៅតាមកម្រិតសិក្សារបស់សិស្ស មានការកែលម្អវិធីសាស្រ្តបង្រៀននិងស្រាវជ្រាវបន្ថែមលើបច្ចេកទេសបង្រៀនថ្មីៗ បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃរបស់សិស្ស និងមុខវិជ្ជាដទៃទៀតបានល្អ ព្រមទាំងបានរិះរកវិធីសាស្រ្តជួយបង្រៀន

បន្ថែមដល់សិស្សរៀនយឺតទាន់ពេលវេលាផងដែរ។ ចំណុចវិជ្ជមាននេះ ហាក់បានឆ្លើយតបនឹងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣ យុទ្ធសាស្ត្រគោលទី១ ស្តីពីការគ្រប់គ្រងការសិក្សា ត្រង់យុទ្ធសាស្ត្ររង១.២ កែលម្អវិធីសាស្ត្របង្រៀន ដែលបានចែងថាគ្រូបង្រៀនមានភារកិច្ចផលិតសម្ភារៈជំនួយការបង្រៀន និងអនុវត្តវិធីសាស្ត្របង្រៀនសមស្របស្រាវជ្រាវលើវិធីសាស្ត្របង្រៀន ដើម្បីកែលម្អគុណភាពការបង្រៀននិងចូលរួមកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ផ្លាស់ប្តូរវិធីសាស្ត្របង្រៀនពីការរៀនបែបអកម្ម ដែលសិស្សជាអ្នករងចាំទទួលចំណេះដឹងទៅជាវិធីសាស្ត្រថ្មីឬការរៀនបែបសកម្ម ដែលសិស្សជាអ្នកបង្កើតនូវចំណេះដឹងថ្មីៗ ។

ដោយឡែក ការពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស គ្រូបង្រៀនក៏អនុវត្តបានល្អដែរ ដោយពួកគាត់បានរៀបចំដំណើរការប្រឡងសំណេរប្រកបដោយតម្លាភាព ពិនិត្យតាមដានការសិក្សារបស់សិស្សជាប្រចាំ ផ្តល់ព័ត៌មានត្រឡប់អំពីសិស្សទៅសិស្សខ្លួនឯង និងមាតាបិតាសិស្ស និងប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានល្អ។ សកម្មភាពទាំងនេះ បានឆ្លុះបញ្ចាំងពីការអនុវត្តរបស់គ្រូ ឆ្លើយតបតាមស្តង់ដារវិជ្ជាជីវៈរបស់ខ្លួនបានយ៉ាងល្អប្រសើរ។ ចំណែក Gurol (2004) ក៏បានរកឃើញដែរថា ទោះបីកម្មវិធីសិក្សាល្អប៉ុណ្ណាក៏ដោយប្រសិនបើគ្រូបង្រៀនមិនបានអនុវត្តប្រកប ដោយប្រសិទ្ធភាពនោះទេ យើងនឹងមិនអាចសម្រេចឱ្យបាននូវវត្ថុបំណងរបស់កម្មវិធីសិក្សានោះទេ។ ដូចនេះដើម្បីអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពលុះត្រាតែលោកគ្រូ អ្នកគ្រូប្រើប្រាស់វិធីសាស្ត្រក្នុងការវាយតម្លៃសមត្ថភាពសិស្សបានល្អ ហើយត្រូវអនុវត្តនៅក្នុងដំណើរការបង្រៀនរបស់គាត់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កម្មវិធីសិក្សាផងដែរ ។

### ក.បញ្ហាប្រឈមរបស់អ្នកអនុវត្ត

ទន្ទឹមនឹងការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីសិក្សាបានល្អ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាពពីសំណាក់គ្រូបង្រៀន នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងវិទ្យាល័យនៅខេត្តតាកែវយ៉ាងណាក្តី ក៏ក្នុងពេលអនុវត្តកម្មវិធីសិក្សាគ្រូបង្រៀនបានជួបប្រទះនូវការលំបាកមួយចំនួនដូចខាងក្រោមៈ

១).ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលមានកង្វះខាតៈ ក្នុងចំណោមគ្រូបង្រៀនទាំង៤០នាក់ មានគ្រូបង្រៀនស្ទើរតែគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ចាប់ពីថ្នាក់ទី១០ដល់១២ ភាគច្រើនបានលើកឡើងថា មេរៀនក្នុងសៀវភៅសិក្សាគោលមានចំនួនច្រើន តែម៉ោងក្នុង កម្មវិធីសិក្សាតិច នាំឱ្យបង្រៀនលឿនខ្លាចមិនទាន់កម្មវិធី។ គ្រូបង្រៀនមុខវិជ្ជាផែនដីវិទ្យាថ្នាក់ទី១០ដល់១២ម្នាក់ គណិតវិទ្យានៅកម្រិតថ្នាក់ដូចគ្នាម្នាក់ និងប្រវត្តិវិទ្យាថ្នាក់ទី១០ម្នាក់ នៃវិទ្យាល័យ ផ្សេ

ងៗគ្នាបានលើកឡើងដូចគ្នាថា មេរៀនក្នុងសៀវភៅមានលំដាប់មិនល្អ នាំឱ្យសិស្សពិបាកចាប់យកខ្លឹមសារមេរៀន។ គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតទុតិយភូមិម្នាក់នៃ វិទ្យាល័យមួយលើកឡើងថា មុខវិជ្ជាភាសាអង់គ្លេសគ្រប់កម្រិតមានខ្លឹមសារមេរៀនចាស់ពេកមិនអភិវឌ្ឍន៍ ដែលធ្វើឱ្យសិស្សមិនសូវចាប់អារម្មណ៍ចង់រៀន។ ចំណែកគ្រូបង្រៀនមុខវិជ្ជាផែនដីវិទ្យាថ្នាក់ទី១០ដល់១២ម្នាក់ បានលើកឡើងថាខ្លឹមសារមេរៀនខ្លះនៅមានកម្រិត។ ចំណែកគ្រូបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជានៅផ្នែកទុតិយភូមិម្នាក់ទៀត បានបង្ហាញពីការលំបាកថាដោយមិនមានសទ្ទានុក្រមមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ធ្វើឱ្យមានការលំបាកក្នុងស្វែងយល់ពាក្យបច្ចេកទេសដែលប៉ះពាល់ដល់ខ្លឹមសារមេរៀនទាំងមូល។ ចំណែកគ្រូបង្រៀនគណិតវិទ្យាថ្នាក់ទី១២ម្នាក់បង្ហាញថា សៀវភៅគណិតវិទ្យាថ្នាក់ទី១២មានរហូតដល់៤ប្រភេទ នាំឱ្យពិបាកក្នុងការបង្រៀននិងរៀន។

២).ខ្វះខាតសម្ភារបង្រៀន និងរៀន៖ គ្រូបង្រៀនភាគច្រើនបានលើកឡើងថា សាលាមិនមានសម្ភារឧបទេសគ្រាប់គ្រាន់សម្រាប់ដំណើរការបង្រៀនទេ។ គ្រូបង្រៀនមួយចំនួនតូចទៀតបានបង្ហាញថា កង្វះសៀវភៅគ្រូក៏ជាបញ្ហាប្រឈមមួយដែរក្នុងការអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព។ ចំណែកគ្រូបង្រៀនមុខវិជ្ជាផ្នែកសង្គមមួយចំនួនតូច បានលើកឡើងពីការលំបាកក្នុងការផលិតសម្ភារឧបទេសក្នុងការបង្រៀនលើមុខវិជ្ជាមួយចំនួនផ្នែកសង្គម មិនដូចមុខវិជ្ជាផ្នែកវិទ្យាសាស្ត្រពិតទេដែលស្រួលបង្កើតសម្ភារឧបទេសជាង។ ដោយឡែកគ្រូបង្រៀនមុខវិជ្ជា ICT ម្នាក់នៃសាលាក្នុងទីជនបទមួយលើកឡើងថា សាលាពុំមានអគ្គិសនីប្រើប្រាស់ដល់បន្ទប់រៀន និងពុំមានកុំព្យូទ័រសម្រាប់ឱ្យសិស្សអនុវត្ត ក្នុងម៉ោងសិក្សាលើមុខវិជ្ជារបស់ខ្លួនឡើយ។ គ្រូបង្រៀនមួយចំនួនធំបានផ្តល់យោបល់ថា បញ្ហាប្រឈមនៃការអនុវត្តកម្មវិធីសិក្សាសព្វថ្ងៃគឺខ្វះសៀវភៅសិក្សាគោល។ ចំណែកឯគ្រូបង្រៀនមួយចំនួនទៀត បានបញ្ចេញគំនិតដូចៗគ្នាថា កង្វះសម្ភារពិសោធន៍ និងគ្មានបន្ទប់ពិសោធន៍ សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ គឺជាបញ្ហាប្រឈមមួយដែលត្រូវដោះស្រាយជាចាំបាច់ ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាពខ្ពស់។ ដោយឡែកគ្រូបង្រៀនម្នាក់យល់ឃើញថា សាលាខ្វះឯកសារសម្រាប់គ្រូនិងសិស្សស្រាវជ្រាវឬស្វ័យសិក្សាដោយខ្លួនឯងបន្ថែមទៀត។

៣).សិស្សមិនយកចិត្តទុកដាក់រៀនសូត្រ៖ គ្រូបង្រៀនមួយចំនួនលើកឡើងថា សមត្ថភាពសិស្សនៅមានកម្រិត មិនខិតខំប្រឹងប្រែងរៀនសូត្រ មករៀនមិនទៀងទាត់ អវត្តមានច្រើន និងមិនស្វ័យសិក្សាក៏ដូចជាស្រាវជ្រាវខ្លួនឯងបន្ថែម ជាហេតុនាំឱ្យលទ្ធផលសិក្សាធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ដោយឡែកគ្រូបង្រៀនមួយក្រុមតូចទៀតបានលើកឡើងថា សិស្សមួយចំនួនតូចនៅមិនសូវចេះសរសេ ឬអានពាក្យជាភាសាខ្មែរបានត្រឹមត្រូវច្បាស់លាស់នៅឡើយទេ បើទោះបី

សិក្សាដល់កម្រិតថ្នាក់ទី១០ហើយក៏ដោយ។

៤).មានការលំបាកក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលៈ គ្រូបង្រៀនមួយចំនួនធំបានផ្ដល់យោបល់ថា សិស្សភាគច្រើនមិនសូវយកចិត្តទុកដាក់ក្នុងការពិភាក្សាក្រុម។ ចំណែកឯគ្រូបង្រៀនមួយចំនួនទៀតបានបញ្ជាក់ថា ចំនួនសិស្សក្នុងមួយថ្នាក់ច្រើនពេកលើសនិយាម សិស្សមានសមត្ថភាពមិនដូចគ្នា នាំឱ្យការពិភាក្សាក្រុមត្រូវចំណាយពេលច្រើន និងពិបាកគ្រប់គ្រងសិស្សពេលអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល។

៥).មិនមានការបំប៉នគ្រូបន្ថែមលើសៀវភៅប្រឆាំអំពើពុករលួយៈ គ្រូបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាថ្នាក់ទី១០ដល់ទី១២ម្នាក់លើកឡើងថា មិនមានការបំប៉នគ្រូបន្ថែមលើការប្រើប្រាស់សៀវភៅប្រឆាំងអំពើពុករលួយដែលតម្រូវឱ្យបញ្ជ្រាបក្នុងខ្លឹមសារមេរៀន។

៦).ថ្ងៃឈប់សម្រាកច្រើនពេកៈ គ្រូបង្រៀនម្នាក់លើកឡើងថាថ្ងៃឈប់សម្រាកច្រើនធ្វើឱ្យប៉ះពាល់ដល់ម៉ោងបង្រៀន នាំឱ្យបង្រៀនមិនទាន់កម្មវិធី។

៧).ការចេញវិញ្ញាសាប្រឡងថ្នាក់ជាតិៈ គ្រូបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរថ្នាក់ទី១០-១២ម្នាក់នៃវិទ្យាល័យមួយបានលើកឡើងថា ក្រសួងចេញវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមិនស្របតាមកម្មវិធីសិក្សា ហើយសំណួរខ្លះក្នុងវិញ្ញាសាអក្សរសាស្ត្រខ្មែរវែងអន្លាយពេក។

លទ្ធផលខាងលើបង្ហាញថា ថ្វីត្បិតតែការអនុវត្តកម្មវិធីសិក្សាបានល្អយ៉ាងណាក្ដី តែគ្រូបង្រៀនបានជួបប្រទះនូវការលំបាកចំពោះមុខមួយចំនួន ដែលពួកគាត់ត្រូវស្នើសុំដំណោះស្រាយជាចាំបាច់ ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាកាន់តែមានប្រសិទ្ធភាពខ្ពស់។ បញ្ហាប្រឈមទាំងនេះក៏មានលើកឡើងប្រហាក់ប្រហែលគ្នាផងដែរ ក្នុងរបាយការណ៍ពាក់កណ្ដាលអាណត្តិស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ ទំព័រទី៦៦ ចំណុចទី៣ ស្ដីពីការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការអប់រំបច្ចេកទេស និងកែលម្អកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅបានលើកឡើងពីបញ្ហាជាច្រើន ដែលបានជួបប្រទះពេលអនុវត្តកម្មវិធីសិក្សានៅកម្រិតសាលារៀន ដោយលោកគ្រូ អ្នកគ្រូមិនអាចអនុវត្តកម្មវិធីសិក្សាបានពេញលេញបណ្ដាលមកពីកត្តាមួយចំនួនដូចជាកត្តាគ្រោះធម្មជាតិ និងហានីភ័យផ្សេងៗ ការឈប់សម្រាកក្រៅផ្លូវការ និងការបំពេញភារកិច្ចរបស់គ្រូនៅមានកម្រិត ការប្រើវិធីសាស្ត្របែបទន្ទេញចាំមាត់នៅតែកើតមាន កង្វះខាតអ្នកសម្របសម្រួលកម្មវិធីសិក្សាកម្រិតថ្នាក់ស្រុកនៅតែជាបញ្ហាចោទនៅឡើយ ការយល់ដឹងទាក់ទងទៅនឹងគោលនយោបាយកម្មវិធីសិក្សានៅមានកម្រិតទាបក្នុងចំណោមគ្រូបង្រៀនទាំងអស់ និងការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សានៅមានកម្រិតនៅឡើយ។ ដោយឡែកការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ឆ្នាំ២០១៤-២០១៨ ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ទំព័រទី១៨ ត្រង់បញ្ហាប្រឈមក៏បានលើកឡើងនូវបញ្ហាដូចគ្នាដែរថា គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទ្ទេស រោងជាង ស្របតាមកម្មវិធីសិក្សានៅឡើយ។

បើពិនិត្យទៅលើបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា ដែលបានរកឃើញតាមរយៈនិក្ខេបបទក្នុងករណីសិក្សានៅវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ របស់អ្នកស្រាវជ្រាវ លឹម កិត្យា បោះពុម្ពឆ្នាំ២០១៨ ទំព័រទី៤៤ និង៤៥ បានលើកឡើងថា បញ្ហាចម្បងធំៗដែលលោកគ្រូអ្នកគ្រូជួបប្រទះក្នុងពេលអនុវត្តកម្មវិធីសិក្សាកន្លងមកគឺ (១)សមត្ថភាពសិស្សមិនសមស្របទៅនឹងកម្រិតថ្នាក់ដែលកំពុងរៀន (សិស្សភាគច្រើនខ្សោយគ្មានមូលដ្ឋានគ្រឹះពីខាងក្រោម) (២)សិស្សមិនយកចិត្តទុកដាក់និងឱ្យតម្លៃលើការសិក្សា (៣)ខ្វះខាតសៀវភៅសិក្សាគោលច្រើនលើមុខវិជ្ជាមួយចំនួន (៤)ចំនួនមេរៀននិងម៉ោងបង្រៀនក្នុង១សប្តាហ៍មិនសមស្រប (៥)សៀវភៅសិក្សាគោលមានការខ្វះចន្លោះច្រើនចំពោះមុខវិជ្ជាមួយចំនួនដូចជា មានកំហុសអក្ខរាវិរុទ្ធ មានកំហុសឆ្គងលើលំហាត់ និងកំណែលំហាត់ ខ្លឹមសារមេរៀនមិនស៊ីជម្រៅទៅនឹងចំណងជើង ខ្លឹមសារមេរៀនច្រំដែល ខ្លឹមសារមេរៀនខ្លះទាបជាងសមត្ថភាពសិស្ស និងខ្លះទៀតខ្ពស់ជាងសមត្ថភាពសិស្សពេក ការពន្យល់ទៅលើខ្លឹមសារមេរៀនមិនមានភាពច្បាស់លាស់និងពិបាកយល់ ខ្លឹមសារមួយចំនួនមិនទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃនិងធ្វើឱ្យសិស្សគ្មានចិត្តចង់រៀន លំដាប់លំដោយមេរៀនមិនត្រឹមត្រូវ (៦)ខ្វះខាតឯកសារយោងដូចជាមេរៀនភាសាខ្មែរ។ល។ (៧)ខ្វះខាតសម្ភារឧបទេស ដោយសម្ភារមានសម្រាប់តែតាំងលម្អ ហើយបែបបទនៃការយកសម្ភារមកប្រើប្រាស់នៅក្នុងថ្នាក់រៀនមានការលំបាក (៨)មិនមានការគាំទ្របច្ចេកទេសពីប្រធាន ក្រុមបច្ចេកទេសគ្រប់គ្រាន់តាមតម្រូវការនោះទេ (៩)គ្មានការចែករំលែកចំណេះដឹងរវាងគ្រូនិងគ្រូដែលជាសមាជិកក្រុមបច្ចេកទេសដូចគ្នា (១០)គោលវិធីសិស្សមជ្ឈមណ្ឌលដែលបានណែនាំក្នុងកម្មវិធីសិក្សាមិនអាចអនុវត្តបានទាំងស្រុងទេ ព្រោះទំហំថ្នាក់រៀនធំពេកសិស្សលើសពី៥០នាក់ នាំឱ្យពិបាកគ្រប់គ្រងសិស្ស បរិស្ថានថ្នាក់រៀនមិនអំណោយផលឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន និងមិនមានមន្ទីរពិសោធន៍និងបន្ទប់ ITC ជាដើម។ លទ្ធផលនេះបានបង្ហាញថា នៅពេលអនុវត្តកម្មវិធីសិក្សាទាំងក្នុងខេត្តតាកែវនិងក្នុងរាជធានីភ្នំពេញ បើទោះបីជាទំហំនៃការសិក្សាស្រាវជ្រាវមានដែនកំណត់និងវិសាលភាពតូចដូចគ្នាក៏ដោយ ពោលគឺធ្វើការប្រៀបធៀបគ្នារវាងការសិក្សាតែ៣វិទ្យាល័យក្នុងខេត្តតាកែវ និងការសិក្សាស្រាវជ្រាវតែ១វិទ្យាល័យក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក៏អ្នកស្រាវជ្រាវសង្កេតឃើញថា គ្រូបង្រៀនបានជួបប្រទះនូវបញ្ហាប្រឈមប្រហាក់ប្រហែលគ្នា ដែលទាមទារឱ្យមានការកែលម្អឡើងវិញជាចាំបាច់។

ដោយឡែក បើក្រឡេកមើលទៅលើការអនុវត្តកម្មវិធីសិក្សាចាស់វិញ ដែលផ្តោតលើខ្លឹមសារសៀវភៅសិក្សាគោល ក៏មានបញ្ហាប្រឈមបានកើតឡើងស្រដៀងគ្នាទៅនឹងខ្លឹមសារសៀវភៅសិក្សាគោលដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្នផងដែរ តួយ៉ាងតាមរយៈការសិក្សាស្រាវជ្រាវរបស់ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ករណីសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាគីមីវិទ្យា បោះពុម្ពឆ្នាំ១៩៩៦-២០០៤ មានកត្តាមួយដែលជះឥទ្ធិពលដល់ការអនុវត្តកម្មវិធីសិក្សា គឺដោយសៀវភៅទាំងនោះមានបញ្ហាដូចជា៖ (១)មានកំហុសច្រើនទាំងអក្ខរាវិរុទ្ធនិងរូបមន្ត (២)មេរៀនទាំងនោះគឺពិបាកពេកទាំងគ្រូនិងសិស្ស (៣)ចំនួនម៉ោងនិងចំនួនខ្លឹមសារមិនស៊ីគ្នា (៤)ការពន្យល់ទៅលើខ្លឹមសារមេរៀនមិនមានភាពច្បាស់លាស់និងពិបាកយល់ (៥)ខ្លឹមសារមួយចំនួនមិនទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃនិងធ្វើឱ្យសិស្សគ្មានចិត្តចង់រៀន (៦)មេរៀនលំបាកៗជាច្រើនដែលមិនសមដាក់នៅកម្រិតនេះត្រូវបានគេដាក់បញ្ចូល (៧)មេរៀនសំខាន់ៗដែលចាំបាច់និងជាមូលដ្ឋានគ្រឹះមួយចំនួនមិនត្រូវបានដាក់បញ្ចូល (៨)ចំណងជើងមេរៀនរៀបគ្មានលំដាប់លំដោយ (៩)មេរៀនមួយចំនួនមិនមានសារសំខាន់សម្រាប់បង្រៀនសិស្សឱ្យយល់ពីគីមីវិទ្យា (១០)លំហាត់មួយចំនួនមិនផ្សារភ្ជាប់ជាមួយនឹងខ្លឹមសារមេរៀន (១១)រូបភាពសម្រាប់សង្កេតមិនមានភាពច្បាស់លាស់ (១២)លំហាត់មួយចំនួនគ្មានចម្លើយនៅក្នុងសៀវភៅគ្រូ (១៣) ខ្លឹមសារពិសោធមួយចំនួនមិនបានគិតពីសម្ភារដែលសាលាកំពុងជួបប្រទះ ចំណែកឯលំនាំពិសោធគឺតាមបែបឧស្សាហកម្ម និង១៤)ពិសោធន៍មិនត្រូវបានបង្រៀនតាមវិធីវិទ្យាសាស្ត្រ។ តែការលើកឡើងនេះ គ្រាន់តែបង្ហាញពីខ្លឹមសារសៀវភៅសិក្សាគោលមុខវិជ្ជាគីមីវិទ្យាដែលបានបោះពុម្ពឆ្នាំ១៩៩៦ដល់២០០៤ តែមួយមុខវិជ្ជាប៉ុណ្ណោះ ដោយមិនបានសិក្សាលើគ្រប់មុខវិជ្ជាឱ្យទូលំទូលាយនោះទេ។

### ខ.សំណើសុំពីអ្នកឆ្លើយតប តាមទិន្នន័យកម្រងសំណួរ

សម្រាប់យោបល់របស់គ្រូបង្រៀន ក្នុងការអនុវត្តកម្មវិធីសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព គ្រូបង្រៀនបានលើកជាសំណូមពរមួយចំនួនដូចខាងក្រោម៖

១).ស្នើសុំសម្ភាររៀន-បង្រៀន និងសម្ភាររូបវន្តផ្សេងៗ៖ គ្រូបង្រៀនភាគច្រើនបានស្នើដល់ក្រសួងឱ្យផ្តល់សៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាបន្ថែមទៀតដល់សាលារៀន ដើម្បីសិស្សបានប្រើប្រាស់គ្រប់ៗគ្នា។ ចំណែកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួនទៀតស្នើសុំសម្ភារនិងរៀបចំបន្ទប់ពិសោធន៍ឱ្យបានគ្រប់គ្រាន់តាមសាលារៀន ដើម្បីឱ្យសិស្សងាយយល់ខ្លឹមសារមេរៀនក្នុងការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត។ គ្រូបង្រៀនមុខវិជ្ជាគីមីវិទ្យាថ្នាក់ទី១០ម្នាក់ នៃវិទ្យាល័យមួយបានស្នើសុំឱ្យមានសម្ភារឧបទេសគ្រប់គ្រាន់ សម្រាប់ការបង្រៀននិងរៀន។ ដោយឡែកគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១០ម្នាក់ បានលើកសំណូមពរដល់សាលារៀន

និងភាគីពាក់ព័ន្ធក្នុងការរៀបចំឱ្យមានក្តារខៀន២ក្នុង១ថ្នាក់ និងសង់អគារសិក្សាបន្ថែមដើម្បីដោះស្រាយបញ្ហាកង្វះខាតបន្ទប់សិក្សា។

២).វិធីសាស្ត្របង្រៀន និងការបំប៉នបន្ថែម៖ គ្រូបង្រៀនមួយចំនួនធំបានសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបើកវគ្គបណ្តុះបណ្តាលលើចំណេះដឹង និងវិធីសាស្ត្របង្រៀនរបស់គ្រូបន្ថែមទៀត ដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀន។ រីឯគ្រូបង្រៀនម្នាក់ទៀត បានស្នើសុំរៀបចំចំនួនសិស្សក្នុងថ្នាក់ត្រឹមត្រូវស្របតាមនិយាមគរុកោសល្យ ដើម្បីងាយស្រួលក្នុងការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល។

៣).ការអភិវឌ្ឍកម្មវិធីសិក្សា និងខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល៖ គ្រូបង្រៀនមួយក្រុមស្នើឱ្យបង្កើនម៉ោងបង្រៀនមុខវិជ្ជាគោល និងមុខវិជ្ជាវិទ្យាសាស្ត្រ និងកាត់បន្ថយមេរៀនដែលមិនចាំបាច់ចេញ ឬសម្រួលខ្លឹមសារឱ្យនៅខ្លី។ គ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១២ ចំនួនពីរនាក់ មកពីវិទ្យាល័យពីរផ្សេងគ្នាបានលើកសំណូមពរដូចគ្នាដល់ក្រសួង ឱ្យរៀបចំកាត់បន្ថយខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលគណិតវិទ្យាថ្នាក់ទី១២ ដោយសម្រួលឱ្យនៅសល់ត្រឹមតែ១ឬ២ក្បាល ដើម្បីងាយស្រួលក្នុងការបង្រៀននិងរៀន។ ចំណែកគ្រូបង្រៀនពីរនាក់ផ្សេងទៀតស្នើដល់ក្រសួងរៀបចំនិងអភិវឌ្ឍសៀវភៅសិក្សាគោលថ្មី ជាពិសេសមុខវិជ្ជាភាសាអង់គ្លេស។ ចំណែកគ្រូបង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរថ្នាក់ទី១០ដល់ទី១២ម្នាក់ នៃសាលារៀនមួយ បានស្នើដល់ក្រសួងរៀបចំម៉ោងសិក្សាឱ្យសមស្របតាមខ្លឹមសារមេរៀន។

៤).សំណើទាក់ទងនឹងការរៀបចំវិញ្ញាសាប្រឡងថ្នាក់ជាតិ៖ គ្រូបង្រៀនមួយចំនួនធ្វើការស្នើសុំដល់ក្រសួង ចំពោះការរៀបចំវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យស្របតាមកម្មវិធីសិក្សា។

៥).ទប់ស្កាត់ការប្រើប្រាស់ទូរស័ព្ទដៃក្នុងថ្នាក់ឬសាលារៀន៖ គ្រូបង្រៀនមួយចំនួនស្នើដល់សាលារៀនក្នុងការទប់ស្កាត់សិស្សមិនឱ្យប្រើប្រាស់ទូរស័ព្ទដៃ (Smart Phone) ក្នុងថ្នាក់ ឬក្នុងសាលារៀន។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍

## ៥.១.សេចក្តីសន្និដ្ឋាន

ស្នាដៃស្រាវជ្រាវនេះបានបង្ហាញនូវលទ្ធផលធំៗចំនួនពីរគឺ ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលារៀន និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ (ចាប់ពីថ្នាក់ទី១០-១២) នៅខេត្តតាកែវ។ កិច្ចការនេះក៏បាន បង្ហាញផងដែរនូវបញ្ហាប្រឈមនានាដែលបានកើតឡើង ក្នុងអំឡុងពេលគ្រប់គ្រង និងដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលា និងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន ព្រមទាំងមតិឬសំណូមពរមួយចំនួនរបស់ពួកគាត់ ដើម្បីចូលរួមចំណែកអភិវឌ្ឍកម្មវិធីសិក្សារបស់យើងឱ្យល្អប្រសើរ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

ឆ្លងតាមរយៈការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានរកឃើញថានាយកវិទ្យាល័យបានយកចិត្តទុកដាក់ខ្ពស់លើការដឹកនាំការអនុវត្តកម្មវិធីសិក្សា ដោយលទ្ធផលបង្ហាញថា នាយកសាលាមានការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ ក្នុងកម្រិតមួយល្អណាស់ ខណៈដែលការគ្រប់គ្រងនិងដឹកនាំការបង្រៀន ការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងការសហការនិងទំនាក់ទំនងស្ថិតក្នុងកម្រិតល្អអាចទទួលយកបាន។ បើទោះបីជាការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងសាលាទទួលបានលទ្ធផលល្អយ៉ាងណាក៏ដោយ ក៏ការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់ពួកគាត់បានជួបនូវបញ្ហាលំបាកមួយចំនួនដូចជា ការខ្វះគ្រូបង្រៀនតាមឯកទេសមួយចំនួនផ្នែកទុតិយភូមិ ខ្វះបន្ទប់រៀន គ្រូបង្រៀនមួយចំនួនតូចខ្វះមនសិការវិជ្ជាជីវៈដោយមិនសូវយកចិត្តទុកដាក់លើការងារបង្រៀន និងមិនមានបន្ទប់បំពាក់សម្ភារបរិក្ខារសម្រាប់អនុវត្តមុខវិជ្ជា ICT ជាដើម ដែលសុទ្ធសឹងជាបញ្ហាត្រូវដោះស្រាយជាចាំបាច់។

ចំណែកការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យ ផ្នែកមធ្យមសិក្សាទុតិយភូមិវិញ អ្នកស្រាវជ្រាវបានរកឃើញថា គ្រូបង្រៀនបានអនុវត្តបានល្អ ទាំងការអនុវត្ត កម្មវិធីសិក្សា ការរៀបចំដំណើរការបង្រៀន ចំណេះដឹងលើជំនាញរបស់ពួកគាត់ក៏សមស្រប វិធីសាស្រ្តបង្រៀន និងការពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ទន្ទឹមនឹងការអនុវត្តបានល្អនេះ គ្រូបង្រៀនក៏បានជួបនូវបញ្ហាប្រឈមមួយចំនួន ដែលបានលើកជាសំណើសុំដំណោះស្រាយដល់ភាគីពាក់ព័ន្ធផងដែររួមមាន ស្ទើរតែគ្រប់មុខវិជ្ជាមានម៉ោងសិក្សាមិនសមស្របនឹងខ្លឹមសារមេរៀន ខ្វះសៀវភៅសិក្សាគោល សិស្សមិនសូវយកចិត្តទុកដាក់រៀនសូត្រនិងអវត្តមានច្រើន គ្រូមិនទទួលបានការបណ្តុះបណ្តាលលើបច្ចេកទេសវិធីសាស្រ្តបង្រៀន

ថ្មីៗ ខ្វះសម្ភារឧបទេស និងខ្វះសម្ភារនិងបន្ទប់ពិសោធន៍ ជាដើម។

លទ្ធផលដែលបានបង្ហាញខាងលើ ជាទឡ្ហីករណ៍មួយអាចជួយឱ្យអ្នកស្រាវជ្រាវទាញសេចក្តីសន្និដ្ឋានបានថា ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលា និងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅវិទ្យាល័យក្នុងខេត្តតាកែវ មានកម្រិតល្អ អាចទទួលយកបាន ប៉ុន្តែក៏មាននូវចំណុចខ្វះខាតមួយចំនួនត្រូវកែលម្អផងដែរ។ ការខិតខំប្រឹងប្រែងបំពេញការងារពីសំណាក់គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនរហូតទទួលបានផ្លែផ្កាជាវិជ្ជមាននេះ បានឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា លើផ្នែកអភិវឌ្ឍកម្មវិធីសិក្សា ក្នុងគោលបំណងធ្វើយ៉ាងណា ឱ្យមនុស្សគ្រប់រូបក្លាយជាពលរដ្ឋពេញលេញប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនបន្ថែមមួយកម្រិតទៀត។

## ៥.២.សំណូមពរ

បើទោះបីជាលទ្ធផលដែលបានរកឃើញបង្ហាញថា ការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលា និងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យនានាក្នុងខេត្តតាកែវ ស្ថិតក្នុងកម្រិតមួយល្អយ៉ាងណាក៏ដោយក៏អ្នកស្រាវជ្រាវសូមលើកឡើងនូវសំណូមពរមួយចំនួន ដើម្បីកែលម្អចំណុចខ្វះខាត ដែលភាគីពាក់ព័ន្ធនានាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន និងអាណាព្យាបាលសិស្ស ត្រូវរួមគ្នាដោះស្រាយជាប្រព័ន្ធក្នុងការពង្រឹងប្រសិទ្ធភាពនៃការដឹកនាំការអនុវត្ត និងការអនុវត្តកម្មវិធីសិក្សាឱ្យកាន់តែល្អប្រសើរឡើង។

### ៥.២.១.ក្រសួងអប់រំ យុវជន និងកីឡា

- សូមបើវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនស្តីពីកម្មវិធីសិក្សា និងបញ្ចូលមេរៀនអំពីកម្មវិធីសិក្សាទៅក្នុងវគ្គបណ្តុះបណ្តាលគ្រូគ្រប់កម្រិត។
- ស្នើដល់ក្រសួងរៀបចំសេចក្តីណែនាំដល់ភាគីដែលពាក់ព័ន្ធទាំងអស់ ស្តីពីការអនុវត្តកម្មវិធីសិក្សា ដោយមានការបែងចែកតួនាទីឱ្យបានច្បាស់លាស់ក្នុងការអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព។
- សូមរៀបចំនិងបោះពុម្ពសៀវភៅគ្រូ និងសៀវភៅសិក្សាគោលបន្ថែមលើគ្រប់មុខវិជ្ជា ដើម្បីបំពេញតម្រូវការគ្រូ និងសិស្ស។
- រៀបចំ និងផ្តល់សៀវភៅវិធីសាស្រ្តបង្រៀនថ្មីៗដល់គ្រូបង្រៀនគ្រប់មុខវិជ្ជា។

- បែងចែកគ្រូបង្រៀនតាមឯកទេស ដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន។
- សូមជួយសាងសង់អគារសិក្សាបន្ថែម ដល់សាលារៀនដែលខ្វះអគារសិក្សា។
- កៀរគរថវិកា ឬសម្ភារបន្ថែមពីអង្គការដៃគូរអភិវឌ្ឍនានា ដើម្បីផ្តល់ជូនជាសម្ភារឧបទេស សម្ភារពិសោធន៍ និងកុំព្យូទ័រជាដើម ដល់សាលារៀនក្នុងការអនុវត្តកម្មវិធីសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

### ៥.២.២.មន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- ស្នើដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចុះអធិការកិច្ចសាលារៀនជាប្រចាំ និងកែលម្អព្រមទាំងផ្តល់អនុសាសន៍រាល់ចំណុចខ្វះខាតរបស់សាលារៀនទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា។
- សូមជួយពង្រឹងការដឹកនាំការអនុវត្តកកម្មវិធីសិក្សារបស់នាយកសាលា ដោយស្មារតីទទួលខុសត្រូវខ្ពស់។

### ៥.២.៣.គណៈគ្រប់គ្រងសាលារៀន

- រៀបចំបំណែកចែកភារកិច្ច និងកាលវិភាគឱ្យបានត្រឹមត្រូវដល់គ្រូបង្រៀន។
- ផ្សព្វផ្សាយឱ្យបានច្បាស់លាស់អំពីកម្មវិធីសិក្សាដល់គ្រូបង្រៀនឱ្យបានទូលំទូលាយបំផុត។
- ពង្រឹងការគ្រប់គ្រង និងដឹកនាំការបង្រៀនរបស់គ្រូ និងការរៀនសូត្ររបស់សិស្ស។
- ធ្វើផែនការនិងអនុវត្តអធិការកិច្ចផ្ទៃក្នុងជាប្រចាំ និងកែលម្អចំណុចខ្វះខាតរបស់គ្រូ។
- ពង្រឹងការប្រជុំក្រុមបច្ចេកទេស និងរៀបចំឱ្យមានថ្នាក់និទស្សន៍ឱ្យបានទៀងទាត់។
- ពិនិត្យតាមដាន និងវាយតម្លៃការងារបង្រៀនរបស់គ្រូជាប្រចាំ។
- ដោះស្រាយរាល់បញ្ហាលំបាករបស់គ្រូ ក្នុងការអនុវត្តកម្មវិធីសិក្សា ដូចជាការផ្តល់ជូនសម្ភារឧបទេស រៀបចំសម្ភារនិងបន្ទប់ពិសោធន៍ ជាដើម។
- ទំនាក់ទំនង និងសហការជាមួយភាគីពាក់ព័ន្ធ ដូចជាគ្រូបង្រៀន សិស្ស និងអាណាព្យាបាលសិស្សជាប្រចាំដោយប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីពង្រឹងការអនុវត្តកម្មវិធីសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព។

### ៥.២.៤.ប្រធានក្រុមបច្ចេកទេស

- សូមចែករំលែកចំណេះដឹង និងបទពិសោធន៍នានាស្តីពីកម្មវិធីសិក្សា និងការអនុវត្តកម្មវិធីសិក្សាដល់សមាជិកដទៃទៀត ព្រមទាំងកែលម្អវិធីសាស្ត្របង្រៀនរបស់គ្រូ

តាមរយៈការប្រជុំក្រុមបច្ចេកទេស។

- ចូលរួមសហការ និងតាមដាននូវដំណោះស្រាយនានារបស់នាយកសាលាចំពោះបញ្ហាលំបាករបស់គ្រូបង្រៀនពេលអនុវត្តកម្មវិធីសិក្សា។
- បញ្ចូលរបៀបវារៈស្តីពីការអនុវត្តកម្មវិធីសិក្សា នៅក្នុងអង្គប្រជុំក្រុមបច្ចេកទេសជារៀងរាល់ខែ។

### ៥.២.៥.គ្រូបង្រៀន

- គោរពតាមការចាត់តាំងរបស់នាយកសាលា និងអនុវត្តប្រកបដោយមនសិការវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់។
- មានការតាំងចិត្តខ្ពស់ ក្នុងការអនុកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព ដោយឈរលើគោលការណ៍ណែនាំ ការរៀបចំកិច្ចតែងការបង្រៀនបានត្រឹមត្រូវ និងចូលរួមប្រជុំក្រុមបច្ចេកទេសជាប្រចាំ ជាដើម។
- រៀបចំដំណើរការបង្រៀនឱ្យបានល្អ និងត្រឹមត្រូវ។
- អភិវឌ្ឍចំណេះដឹងរបស់ខ្លួនតាមការរីកចម្រើននៃសម័យបច្ចេកវិទ្យា និងយកចំណេះដឹងលើជំនាញរបស់ខ្លួនទៅអនុវត្តឱ្យបានត្រឹមត្រូវ។
- ប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែបសមស្របតាមកាលៈទេសៈ និងសមត្ថភាពរបស់សិស្ស។
- ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ជូនដល់សិស្ស និងអាណាព្យាបាលសិស្សជាប្រចាំនូវលទ្ធផលសិក្សារបស់សិស្ស។

### ៥.២.៦.អាណាព្យាបាលសិស្ស

- ចូលរួមសហការជាមួយសាលារៀន ក្នុងការជំរុញការសិក្សារបស់សិស្សបន្ថែម។
- ពិនិត្យតាមដានការសិក្សារបស់កូនជាប្រចាំ និងផ្តល់ព័ត៌មានត្រឡប់ ជូនសាលារៀនវិញឱ្យបានទាន់ពេលវេលា។
- ចូលរួមប្រជុំរាល់ការកោះអញ្ជើញពីសំណាក់សាលារៀន។
- យកចិត្តទុកដាក់ និងចូលរួមអភិវឌ្ឍសាលារៀន តាមរយៈការជួយជាថវិកា សម្ភារដើម្បីកែលម្អបរិស្ថានសាលារៀន និងការអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព។

## ៥.៣.អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលា និងការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀននៅកម្រិតថ្នាក់ទី១០ដល់ទី១២ នៃវិទ្យាល័យ

មួយចំនួនក្នុងខេត្តតាកែវតែប៉ុណ្ណោះ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- សិក្សាលើការអនុវត្តកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ ឬទាំងពីរកម្រិត (កម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ) ឬកម្រិតបឋមសិក្សា នៅខេត្តតាកែវដដែល ឬនៅខេត្តផ្សេងៗទៀត។
- ស្រាវជ្រាវលើប្រធានបទដដែល តែជ្រើសរើសសំណាកធំជាងនេះ ដោយធ្វើការប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការសម្ភាសផ្ទាល់ជាមួយអ្នកឆ្លើយសំណួរតែម្តង។
- អាចធ្វើការសិក្សាស្រាវជ្រាវពីទស្សនៈយល់ឃើញរបស់នាយក និងគ្រូបង្រៀនលើក្របខណ្ឌកម្មវិធីសិក្សាថ្មី។

# ឯកសារយោង


កង ឱម, (២០២០) ការអភិវឌ្ឍកម្មវិធីសិក្សា CURRICULUM DEVELOPMENT, ទាញចេញពី https://ihssacademy.com/2020/04/18/ការអភិវឌ្ឍកម្មវិធីសិក្/ ។

ក្រសួងអប់រំ យុវជន និងកីឡា,(២០១៩) ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ (គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤), ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៩) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា,(២០១៨) កម្មវិធីសិក្សាលម្អិត (គ្រប់មុខវិជ្ជា) កម្រិតមធ្យមសិក្សាទុតិយភូមិ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៨) យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៨-២០២៣, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៧) ស្តង់ដានាយកសាលារៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៦) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៦) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ, ក្រសួងអប់រំ យុវជន និងកីឡា,ភ្នំពេញ,ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៦)ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ, នាយកដ្ឋាបណ្តុះ បណ្តាល និងវិក្រឹតការ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាធម្មនុញ្ញ, (២០១៥) រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ, ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១៤) ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០១២)គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា, (២០០៦-ខ) កម្មវិធីសិក្សាលម្អិតគណិតវិទ្យាសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ, នាយកដ្ឋានស្ថានស្រាវជ្រាវគរុកោសល្យ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា,(២០០៦-ក) កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ,

វិទ្យាស្ថានស្រាវជ្រាវ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។
ក្រសួងអប់រំ យុវជន និងកីឡា, (២០០៤) គោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សា ចំណេះទូទៅនិងអប់រំបច្ចេកទេស ២០០៥-២០០៩, នាយកដ្ឋានស្ថានស្រាវជ្រាវ គរុកោសល្យ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។
គង់ សុខហេង, (២០១១) ពាក្យកម្ចីបរទេស និងលក្ខណៈសម្គាល់ពាក្យបាលីសំស្ក្រឹតក្នុងភាសា ខ្មែរ, ភ្នំពេញ។
ប៉ាន់ វុត្ថា, (២០០៦) ទស្សនវិជ្ជាអប់រំ, ភ្នំពេញ។
ប្រកាសលេខ៧៦១ អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦, ឧបករណ៍វាយតម្លៃនាយក-នាយិកាសាលារៀនល្អ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។
ប្រកាសលេខ៧៦១ អយក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦, ឧបករណ៍វាយតម្លៃគ្រូបង្រៀនល្អ, ក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។
ព្រះរាជក្រម នស/រកម/១២០៧/០៣២, (២០០៧) ច្បាប់ស្តីពីការអប់រំ, ភ្នំពេញ។
លឹម កិត្យា, (២០១៨) និក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់ *ចំណេះដឹងនិងទស្សនៈរបស់គ្រូបង្រៀន នៅវិទ្យាល័យចំពោះកម្មវិធីសិក្សា* ករណីសិក្សា វិទ្យាល័យជាស៊ីមសាមគ្គី, ភ្នំពេញ។
សម្តេចសង្ឃរាជ ជួន ណាត, (១៩៦៧) វចនានុក្រមខ្មែរ, ភ្នំពេញ។
ស៊ន សេងហុក, (២០១៩) ទស្សនវិជ្ជានៃការអប់រំ *ច្បាប់អប់រំនិងគោលនយោបាយអប់រំ*, ភ្នំពេញ។
សៀង សុវណ្ណា, (២០១៩) *ភាពខ្វះចន្លោះរបស់សៀវភៅសិក្សាគោលតីមីវិទ្យាបោះពុម្ពឆ្នាំ១៩៩៦-២០០៣*, ភ្នំពេញ។
ហង់ជួន ណារ៉ុន, (២០១៦) កំណែទម្រង់វិស័យអប់រំនៅកម្ពុជា *មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព*, ភ្នំពេញ។

Angelo, T. (1995). Reassessing (and Defining) Assessment . The AAHE Bulletin, 7-9.

Carl, A. (1997). Teacher Empowerment Through Curriculum Development. Juta and Company Limited: Cape Town.

Carl, A. (2009). Teacher Empowerment Through Curriculum development theory into practice. Juta and Company Ltd.

Chisholm, L. (2000). A South African Curriculum for the 21th century : Report for the review committee on curriculum 2005. Pretoria: Department of Education.

Efficiency. [Def. 1]. (n.d.). In Collins Dictionary Online, Re-trieved Feb 2, 2020 from https://www.collinsdictionary.com/dictionary/english/efficiency

Eisner, E. W. (2005). Reimagining Schools. Retrieved from https://books.google.com.kh/books?id=olvKRiW3oBYC&printsec=frontcover#v=onepage&q&f=false

Giordano, G. (2004). Wartime Schools, How World War II Changed American Education. Retrieved from https://books.google.com.kh/books?id=EX1i7jOs1W4C&printsec=frontcover#v=onepage&q&f=true

Gurol, M. (2004). Ogretimdeplanlamavedegerlendirme. Elazing: University Publishing.

Implementation. (n.d.). In Cambridge Dictionary Online , Re-trieved Feb 2, 2020 from https://dictionary.cambridge.org/dictionary/english/implementation

Implementation. (n.d.). In Dictionary.com Online, Re-trieved Feb 2, 2020 from https://www.dictionary.com/browse/implementation

Implementation. (n.d.). In Merriam-Webster Dictionary Online, Re-trieved Feb 2, 2020 from https://www.merriam-webster.com/dictionary/implementation

Marzano, R. J. (2003). *What Works in Schools.* Retrieved from https://books.google.com.kh/books?id=MVyhsp10SIgC&printsec=frontcover#v=onepage&q&f=false

Odey, O.E and Opoh, A.F. (2015). Teachers perceived problems of curriculum implementation in Tertiary Institutions in Cross River State of Nigera. *Journal of Education and Practice*, 145.

Skilbeck, M. (1984). *School Based Curriculum Development.* Retrieved from https://books.google.com.kh/books?id=OAfajm2j1l4C&printsec=frontcover#v=onepage&q&f=false

Spady, W. and Marshall, k. (1991). Beyond traditional outcome-based education. *Educational Leadership*, 67-72.

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរស្រាវជ្រាវ
## សម្រាប់លោកនាយក លោកនាយករង

ខ្ញុំបាទឈ្មោះ **ភួង ម៉ុន្ថា** ជានិស្សិតវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទបញ្ចប់ការសិក្សាលើប្រធានបទស្តីពី"**ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ**" ។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទប្រមូលទិន្នន័យចំនួន៣វិទ្យាល័យក្នុងខេត្តតាកែវ រួមមាន ៖ វិទ្យាល័យ ហេងសំរិនព្រៃល្វា, វិទ្យាល័យអង្គអណ្តែត ក្នុងស្រុកព្រៃកប្បាស និង វិទ្យាល័យហ៊ុនសែន១មិថុនា ក្នុងស្រុកបាទី។ ការសិក្សាស្រាវជ្រាវនេះ មានបំណងស្វែងរកទិន្នន័យដើម្បីឆ្លើយតបទៅលើ ប្រសិទ្ធភាពនៃការដឹកនាំការអនុវត្តកម្មវិធីសិក្សារបស់នាយកវិទ្យាល័យ ក្នុងខេត្តតាកែវ។

អាស្រ័យហេតុនេះ សូមលោកនាយក លោកនាយករង មេត្តាចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សារបស់ខ្ញុំបាទ ដោយក្តីអនុគ្រោះ។ ការចូលរួមផ្តល់ព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សារបស់ខ្ញុំបាទទៅលើប្រធានបទខាងលើ។ ខ្ញុំបាទសូមធានាថា ទិន្នន័យដែលទទួលបានគឺរក្សាទុកជាការសម្ងាត់ និងត្រូវយកមកប្រើប្រាស់ក្នុងការវិភាគសម្រាប់តែការសិក្សាស្រាវជ្រាវសរសេរនិក្ខេបបទបញ្ចប់ការសិក្សាតែប៉ុណ្ណោះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងប្រអប់☐ និងបំពេញចម្លើយ ដែលត្រូវនឹងស្ថានភាពទូទៅរបស់លោក/លោកស្រី។

១.វិទ្យាល័យកំពុងបម្រើការងារ ៖

☐ វិ.ហាសរព្រៃល្វា ☐ វិ.អង្គអណ្តែត ☐ វិ.ហាស១មិថុនា

២.ភេទ៖ ☐ប្រុស ☐ស្រី

៣.អាយុ៖ ☐ ២០-៣០ឆ្នាំ ☐ ៣១-៤០ ឆ្នាំ ☐៤១-៥០ ឆ្នាំ ☐លើស៥០ ឆ្នាំ

៤. កម្រិតវប្បធម៌ ៖ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ បណ្ឌិត ☐ ផ្សេងៗ..............

៥.មុខវិជ្ជាឯកទេស៖....................................................

៦.មុខវិជ្ជាធ្លាប់បង្រៀន៖.......................................... ថ្នាក់ទី៖ .................................

៧.បទពិសោធន៍ជាគណៈគ្រប់គ្រង៖ ☐ ១-៥ឆ្នាំ ☐ ៦-១០ឆ្នាំ ☐ លើស១០ឆ្នាំ

## ផ្នែកទី២៖ ការដឹកនាំការអនុវត្តកម្មវិធីសិក្សា

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងកម្រិតតែមួយប៉ុណ្ណោះ ដែលត្រូវនឹងការអនុវត្តជាក់ស្តែងពិតប្រាកដរបស់លោក/លោកស្រី ក្នុងតារាងខាងក្រោម។ ក្នុងចំណោមសកម្មភាពខាងក្រោម តើលោក/លោកស្រីបានដឹកនាំការអនុវត្តកម្មវិធីសិក្សានៅសាលារៀនក្នុងកម្រិតចង្អុលបង្ហាញណាមួយ?

កម្រិតចង្អុលបង្ហាញ៖

១ = ១% - ២០% គឺអនុវត្តបានតិចបំផុត

២ = ២១% - ៤០% គឺអនុវត្តបានតិច

៣ = ៤១% - ៦០% គឺអនុវត្តបានមធ្យម

៤ = ៦១% -៨០% គឺអនុវត្តបានច្រើន

៥ = ៨១% - ១០០% គឺអនុវត្តបានច្រើនបំផុត

| ល.រ | បរិយាយ | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **ក.ការគ្រប់គ្រងនិងដឹកនាំការងារបង្រៀន** | | | | | | |
| ១ | ធ្វើការបែងចែកកម្មវិធីសិក្សាសម្រាប់លោកគ្រូ/អ្នកគ្រូតាមកម្រិតថ្នាក់ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | រៀបចំតារាងកាលវិភាគសម្រាប់លោកគ្រូ/អ្នកគ្រូតាមកម្រិតថ្នាក់ | | | | | |
| ៣ | ផ្តល់សម្ភារៈនិង ធនធានសិក្សាសម្រាប់ដំណើរការបង្រៀន ដោយឈរលើស្មារតីច្នៃប្រឌិត | | | | | |
| ៤ | ធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូបង្រៀនអនុវត្ត ផែនការនោះឱ្យបានទៀងទាត់ | | | | | |
| ៥ | ជំរុញគ្រូបង្រៀន បង្រៀនឱ្យទាន់កម្មវិធីសិក្សា | | | | | |
| ៦ | មានកិច្ចប្រជុំក្រុមបច្ចេកទេសមុខវិជ្ជាបានទៀងទាត់ | | | | | |
| ៧ | លើកទឹកចិត្តក្នុងការស្រាវជ្រាវ រកវិធីសាស្រ្តបង្រៀនថ្មី ដើម្បីបង្កើនប្រសិទ្ធភាព | | | | | |
| ៨ | បញ្ជូនគ្រូបង្រៀន ចូលរួមក្នុងវគ្គបំប៉នបច្ចេកទេសវិធីសាស្រ្តថ្មី | | | | | |
| ៩ | លើកទឹកចិត្តគ្រូឱ្យបង្រៀនប្រើចិត្ត-គរុកោសល្យ ក្នុងការសម្របសម្រួលឱ្យសិស្សចូលចិត្តការសិក្សា | | | | | |
| **ខ.ការគ្រប់គ្រងនិងដឹកនាំការងាររៀនសូត្រ** | | | | | | |
| ១០ | ការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនរើសអើង | | | | | |
| ១១ | បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបានប្រកបដោយ ភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់ | | | | | |
| ១២ | ជំរុញឱ្យសិស្សានុសិស្ស មានទឹកចិត្តក្នុងការស្វ័យសិក្សាជាប្រចាំ | | | | | |
| ១៣ | បានរៀបចំបណ្ណាល័យ និងការផ្គត់ផ្គង់សៀវភៅសិក្សាគោល | | | | | |
| **គ.ការពិនិត្យតាមដាន និងវាយតម្លៃ** | | | | | | |
| ១៤ | ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់ តាមមុខវិជ្ជា | | | | | |
| ១៥ | ស្វែងរកកង្វះខាត លើវិធីសាស្រ្តបង្រៀនដើម្បីកែលម្អ | | | | | |
| ១៦ | ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដោយតម្លាភាព | | | | | |
| ១៧ | ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដំណើរការបង្រៀន និងរៀនឱ្យកាន់តែល្អប្រសើរ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨ | វាយតម្លៃការបង្រៀនរបស់គ្រូតាមរយៈការសង្កេតលើដំណើរការបង្រៀន | | | | | |
| **ឃ. ការសហការ និងទំនាក់ទំនង** | | | | | | |
| ១៩ | បានរៀបចំប្រជុំបុគ្គលិក ដើម្បីអភិវឌ្ឍការអនុវត្តកម្មវិធីសិក្សា | | | | | |
| ២០ | បានផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃគ្រូជាផ្លូវការដល់ភាគីពាក់ព័ន្ធ | | | | | |
| ២១ | ផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋាន ទៅនឹងតម្រូវការសហគមន៍ | | | | | |
| ២២ | មានកិច្ចពិភាក្សាលើលទ្ធផលសិក្សារបស់សិស្ស ទាំងសិស្សពូកែ និងសិស្សខ្សោយ | | | | | |

## ផ្នែកទី៣៖ យោបល់

១.តើលោក/លោកស្រីជួបបញ្ហាលំបាកអ្វីខ្លះ ក្នុងការដឹកនាំការអនុវត្តកម្មវិធីសិក្សាបច្ចុប្បន្ននេះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

២.តើលោក/លោកស្រីមានសំណូមពរឬអនុសាសន៍យ៉ាងណាខ្លះ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**សូមអរគុណ**!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

# កម្រងសំណួរស្រាវជ្រាវ
## សម្រាប់គ្រូបង្រៀន

ខ្ញុំបាទឈ្មោះ **ភូច ម៉ុន្ថា** ជានិស្សិតវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរ និក្ខេបបទបញ្ចប់ការសិក្សាលើប្រធានបទស្តីពី**"ការអនុវត្តកម្មវិធីសិក្សានៅវិទ្យាល័យនានាក្នុងខេត្តតាកែវ"**។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទប្រមូលទិន្នន័យចំនួន៣វិទ្យាល័យក្នុងខេត្តតាកែវ រួមមាន៖ វិទ្យាល័យ ហេងសំរិនព្រៃល្វា, វិទ្យាល័យអង្គអណ្តែត ក្នុងស្រុកព្រៃកប្បាស និង វិទ្យាល័យហ៊ុនសែន១មិថុនា ក្នុងស្រុកបាទី។ ការសិក្សាស្រាវជ្រាវនេះ មានបំណងស្វែងរកទិន្នន័យដើម្បីឆ្លើយតបទៅលើ ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូ នៃវិទ្យាល័យក្នុងខេត្តតាកែវ។

អាស្រ័យហេតុនេះ សូមលោកគ្រូ អ្នកគ្រូ មេត្តាចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សារបស់ខ្ញុំបាទ ដោយក្តីអនុគ្រោះ។ ការចូលរួមផ្តល់ព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សារបស់ខ្ញុំបាទទៅលើប្រធានបទខាងលើ។ ខ្ញុំបាទសូមធានាថា ទិន្នន័យដែលទទួលបានគឺរក្សាទុកជាការសម្ងាត់ និងត្រូវយកមកប្រើប្រាស់ក្នុងការវិភាគ សម្រាប់តែការសិក្សាស្រាវជ្រាវសរសេរ និក្ខេបបទបញ្ចប់ការសិក្សាតែប៉ុណ្ណោះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម។

## ផ្នែកទី១៖ ព័ត៌មានទូទៅរបស់លោកគ្រូបង្រៀន

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងប្រអប់☐ និងបំពេញចម្លើយ ដែលត្រូវនឹងស្ថានភាពទូទៅរបស់លោកគ្រូ-អ្នកគ្រូ។

១.វិទ្យាល័យកំពុងបម្រើការងារ ៖

☐ វិ.ហាសរព្រៃល្វា ☐ វិ.អង្គអណ្ដែត ☐ វិ.ហាស១មិថុនា

២.ភេទ៖ ☐ ប្រុស ☐ ស្រី

៣.អាយុ៖ ☐ ពី២០-៣០ឆ្នាំ ☐ ពី ៣១-៤៥ ឆ្នាំ ☐ លើស៤៥ឆ្នាំ

៤.កម្រិតវប្បធម៌ ៖ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ.........................

៥.បទពិសោធន៍បង្រៀន៖ ☐ ពី១-៣ឆ្នាំ ☐ ពី៤-៦ឆ្នាំ ☐ ពី៧-១០ឆ្នាំ ☐លើស១០ឆ្នាំ

៦.មុខវិជ្ជាឯកទេស៖.............................................................................................

៧.មុខវិជ្ជាកំពុងបង្រៀន៖ .......................................................ថ្នាក់ទី៖..............................

## ផ្នែកទី២៖ ការអនុវត្តកម្មវិធីសិក្សា

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងចន្លោះតែមួយប៉ុណ្ណោះក្នុងតារាងសំណួរខាងក្រោម ដែលត្រូវនឹងការអនុវត្តជាក់ស្តែងពិតប្រាកដរបស់លោកគ្រូ-អ្នកគ្រូ។ ក្នុងចំណោមសកម្មភាពខាងក្រោម តើលោកគ្រូ-អ្នកគ្រូបានអនុវត្តបានកម្រិតណា ឆ្លើយតបកម្មវិធីសិក្សានៅក្នុង វិទ្យាល័យ។

កម្រិតចង្អុលបង្ហាញ៖

១ = ១% - ២០% គឺអនុវត្តបានតិចបំផុត

២ = ២១% - ៤០% គឺអនុវត្តបានតិច

៣ = ៤១% - ៦០% គឺអនុវត្តបានមធ្យម

៤ = ៦១% -៨០% គឺអនុវត្តបានច្រើន

៥ = ៨១% - ១០០% គឺអនុវត្តបានច្រើនបំផុត

| ល.រ | បរិយាយ | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **ក. ការអនុវត្តកម្មវិធីសិក្សា** | | | | | | |
| ១ | បានអនុវត្តកម្មវិធីសិក្សាតាមគោលការណែនាំ ស្របតាមកម្រិតថ្នាក់ | | | | | |
| ២ | បានអនុវត្តថ្នាក់និទស្សន៍លើក្របខណ្ឌមុខវិជ្ជាគោល | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | មានកិច្ចតែងការបង្រៀន លើគ្រប់មុខវិជ្ជាគោល | | | | | |
| ៤ | បានបង្រៀនគ្រប់តាមម៉ោងសិក្សាកំណត់ ក្នុងមួយពេលម៉ោង | | | | | |
| ៥ | បានបង្រៀនឱ្យទាន់កម្មវិធីសិក្សា លើគ្រប់មុខវិជ្ជា | | | | | |
| ៦ | ចូលរួមប្រជុំក្នុងក្រុមបច្ចេកទេសមុខវិជ្ជា បានយ៉ាងទៀងទាត់ | | | | | |
| **ខ.រៀបចំដំណើរការបង្រៀន** | | | | | | |
| ៧ | មានសៀវភៅកត់ត្រា ស្របតាមដំណើរការបង្រៀន | | | | | |
| ៨ | មានរៀបចំកិច្ចតែងការ មុនដំណើរការបង្រៀន | | | | | |
| ៩ | មានសម្ភារៈឧបទេស ក្នុងការបង្រៀន | | | | | |
| ១០ | បានផលិតសម្ភារឧបទេសគាំទ្រដល់ការបង្រៀន | | | | | |
| ១១ | វាយតម្លៃលទ្ធផលសិក្សា របស់សិស្សបានត្រឹមត្រូវ | | | | | |
| ១២ | បង្កបរិយាកាសឱ្យសិស្សអាចសិក្សាបាន ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល | | | | | |
| ១៣ | បានកំណត់វិធីសាស្ត្របង្រៀន ទៅតាមមេរៀននីមួយៗ | | | | | |
| **គ.ចំណេះដឹងលើជំនាញ** | | | | | | |
| ១៤ | បានបង្រៀនត្រូវតាមឯកទេសដែលបានសិក្សា ស្របតាមវិជ្ជាជីវៈ | | | | | |
| ១៥ | ចូលរួមធ្វើផែនការអធិការកិច្ច ដើម្បីជួយឱ្យការអនុវត្តផែនការនោះបានល្អ | | | | | |
| ១៦ | បានចូលរួមវគ្គបណ្ដុះបណ្ដាល លើការអភិវឌ្ឍកម្មវិធីសិក្សា | | | | | |
| ១៧ | សរសេរកិច្ចតែងការបង្រៀន ដោយឆ្លុះបញ្ចាំងគ្រប់ឥរិយាបថសិក្សា | | | | | |
| ១៨ | យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមេរៀនមួយទៅមេរៀនមួយ | | | | | |
| **ឃ.វិធីសាស្ត្របង្រៀន** | | | | | | |
| ១៩ | ប្រើប្រាស់វិធីសាស្ត្រ ទៅតាមកម្រិតសិក្សារបស់សិស្ស | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២០ | ការកែលម្អវិធីសាស្ត្របង្រៀន និងស្រាវជ្រាវបន្ថែមលើបច្ចេកទេសបង្រៀនថ្មីៗ | | | | | |
| ២១ | ការរិះរកវិធីសាស្ត្រជួយបង្រៀនបន្ថែមដល់សិស្សរៀនយឺត | | | | | |
| ២២ | ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃ និងមុខវិជ្ជាដទៃ | | | | | |
| **ង.ការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា** | | | | | | |
| ២៣ | ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | | | | | |
| ២៤ | ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស | | | | | |
| ២៥ | ផ្តល់ព័ត៌មានត្រឡប់អំពីសិស្ស ទៅដល់អាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និង ឥរិយាបថរបស់សិស្ស | | | | | |
| ២៦ | រៀបចំដំណើរការប្រឡងសំណេរ ប្រកបដោយតម្លាភាព | | | | | |
| ២៧ | ពិនិត្យតាមដាន ការសិក្សារបស់សិស្សជាប្រចាំ និងដោយឡែក | | | | | |

### ផ្នែកទី៣៖ មតិយោបល់បន្ថែម

១.តើលោកគ្រូ-អ្នកគ្រូជួបនូវបញ្ហាប្រឈមអ្វីខ្លះ ក្នុងការអនុវត្តកម្មវិធីសិក្សានាពេលកន្លងមក?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២.តើលោកគ្រូ-អ្នកគ្រូមានមតិយោបល់ឬសំណូមពរអ្វីខ្លះ ដើម្បីឲ្យការអនុវត្តកម្មវិធីសិក្សា កាន់តែទទួលបានប្រសិទ្ធភាព?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

**សូមអរគុណ**!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: [illegible] អយក.[illegible]

*ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩*

**ជម្រាបមក**
**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវរបស់និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅតាមសាកលវិទ្យាល័យ និងរាជធានី ខេត្ត។
**យោង** ៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា ២០១៩-២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកប្រធានថា៖ និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន១៣នាក់ ដូចមានក្នុងលិខិតឧទ្ទេសនាមជូនភ្ជាប់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរ និក្ខេបបទស្រាវជ្រាវតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកប្រធានទទួលនូវការគោរពអំពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ - ឯកសារ ដែរ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៥៦៣៣ អយក.ក

# លិខិតឧទ្ទេសនាម

**កម្មវត្ថុ៖** ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវ តាមសាកលវិទ្យាល័យ និងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ តាមបំណែងចែកដូចខាងក្រោម៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កូវ ប៊ុន្ថា | ប្រុស | តាកែវ |
| ២ | កែម សុភ័ក | ប្រុស | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣ | ជិន តិរម្យ | ប្រុស | ព្រៃវែង |
| ៤ | ញ៉ែម ជា | ប្រុស | ត្បូងឃ្មុំ កំពង់ចាម ព្រៃវែង |
| ៥ | ឡឿន សុគុណ | ប្រុស | ព្រៃវែង |
| ៦ | ផន ឡេង | ប្រុស | ភ្នំពេញ |
| ៧ | ភោគ ស៊ីផន | ប្រុស | សៀមរាប |
| ៨ | ម៉េត ចាន់ណេត | ប្រុស | កណ្ដាល |
| ៩ | យ៉ុន សុខេន | ប្រុស | ភ្នំពេញ |
| ១០ | វ៉ាន់ លីឆេង | ប្រុស | បាត់ដំបង |
| ១១ | ស្រី ស្មើ | ប្រុស | ភ្នំពេញ |
| ១២ | ហុក វិចិត្រ | ប្រុស | ព្រះវិហារ |
| ១៣ | ឡុង ចំណាន | ប្រុស | កំពង់ចាម |

ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអ.យ.ក រាជធានី-ខេត្តដែលពាក់ព័ន្ធ
  "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ ដេអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh